# កម្រងឯកសារ

## គម្រោងអប់រំគ្រូវិទ្យាសាស្ត្រ

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន

## កម្មវិធីបំប៉នលើកទី៤ សម្រាប់នាយកសាលា និង
## គ្រូឧទ្ទេសវិទ្យាសាស្ត្រមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ



០៤ មេសា ដល់ ១០ មេសា ២០១១

រៀបចំដោយ

**ក្រុមការងារគម្រោង STEPSAM2**

STEPSAM2 Science Teacher Education Project

STEPSAM 2
Science
Teacher Education Project

## អាសយដ្ឋានសម្រាប់ទាក់ទង


**ការិយាល័យ STEPSAM2**
ជាន់ក្រោមនៃមជ្ឈមណ្ឌលអប់រំវិទ្យាសាស្ត្រ និងគណិតវិទ្យា
វិទ្យាស្ថានជាតិអប់រំ
មហាវិថីព្រះសីហនុ កែងមហាវិថីព្រះនរោត្តម ក្រុងភ្នំពេញ កម្ពុជា
ទូរស័ព្ទ/ ទូរសារ: ០២៣-៩៩១-១១០

# គណៈកម្មការនិពន្ធ

## គណៈកម្មការនិពន្ធ
## មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

**រូបវិទ្យា**

លោក ដោ៉ ប៉េងឡុង

លោក ម៉ែន វណ្ណារី

**គីមី**

លោក សិត សេង

លោកស្រី ប៊ុន ជៀនស៊ីផល

**ជីវវិទ្យា**

លោក ម៉ម ចាន់សៀន

កញ្ញា ប៊ុន សុផានី

លោកស្រី ហួ ឃីម

**ផែនដីវិទ្យា**

លោកស្រី ណារ៉េត ប៉ូលីវីន

កញ្ញា គឹម បូរីផល

គ្រូឧទ្ទេសវិទ្យាសាស្ត្រ
មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

## គណៈកម្មការត្រួតពិនិត្យ

លោក សិត សេង

លោក ម៉ម ចាន់សៀន

លោក ដោ៉ ប៉េងឡុង

## គណៈកម្មការរៀបរៀង និងចងក្រង

លោក ស្រី រតនៈ

# អារម្ភកថា

លោកគ្រូ-អ្នកគ្រូ និងប្រិយ៍មិត្តអ្នកអានទាំងអស់ជាទីមេត្រី កម្រងឯកសារដែលលោកគ្រូ-អ្នកគ្រូ និងប្រិយ៍មិត្តអ្នកអានកំពុងកាន់នៅនឹងដៃនេះ គឺជាឯកសារទី៤ដែលចងក្រងបានពីវគ្គបំប៉នគ្រូឧទ្ទេសវិទ្យាសាស្ត្រនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦នៅទូទាំងប្រទេស។ វគ្គបំប៉ននេះបានធ្វើនៅវិទ្យាស្ថានជាតិអប់រំ **ពីថ្ងៃទី ០៤ មេសា ដល់ថ្ងៃទី ០៩ មេសា ឆ្នាំ ២០១១** ក្រោមកិច្ចសហប្រតិបត្តិការរបស់ក្រសួងអប់រំយុវជន និងកីឡា និងគម្រោងអប់រំគ្រូវិទ្យាសាស្ត្រ (STEPSAM2)ក្នុងគោលបំណងពង្រឹងសមត្ថភាពគ្រូឧទ្ទេសបន្ថែមទៀតលើផ្នែក វិធីសាស្ត្របង្រៀន និងរៀនដោយផ្អែកលើការរិះរក ការសិក្សាស្រាវជ្រាវមេរៀន និងជំនាញក្នុងការសង្កេតថ្នាក់ ។

ដើម្បីជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់លោកគ្រូ - អ្នកគ្រូ និងប្រិយ៍មិត្តអ្នកអានទាំងអស់ ក្រុមការងារយើងខ្ញុំបានប្រមូលនូវរាល់ឯកសារទាំងអស់ដែលបានប្រើក្នុងវគ្គបំប៉នសម្រាប់គ្រូ សាលាគរុកោសល្យទាំងអស់មកចងក្រងជាសៀវភៅនេះឡើង។ កម្រងឯកសារនៅក្នុងសៀវភៅនេះគឺ ជាទុនសម្រាប់ជួយលោកគ្រូ-អ្នកគ្រូ អោយអាចកែលម្អការបង្រៀនរបស់ខ្លួនឆ្ពោះទៅរកការបង្រៀន និងរៀនផ្អែកលើការរិះរក ដែលផ្តោតទៅលើការគិតរបស់សិស្សជាចម្បង។ នៅក្នុងកម្រងឯកសារនេះដែរ មានបង្ហាញពីរបៀបរៀបចំឯកសារមួយចំនួន ដើម្បីឲ្យការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូមានសកម្មភាពល្អ ដូចជា កិច្ចតែងការបង្រៀន សន្លឹកកិច្ចការ ប្លង់ក្តារខៀន និងកំណត់សម្គាល់មេរៀនជាដើម។

ក្រុមការងារយើងខ្ញុំសូមអធ្យាស្រ័យនូវរាល់ចំណុចខ្វះខាតទាំងឡាយដែលអាចកើតមានដោយយថាហេតុទាំងខ្លឹមសារ និងបច្ចេកទេសក្នុងការចងក្រងឯកសារនេះ។

ក្រុមការងារយើងខ្ញុំរងចាំទទួលការរិះគន់កែលម្អពីសំណាក់លោកគ្រូ-អ្នកគ្រូ និងប្រិយ៍មិត្តអ្នកអានទាំងអស់ ដើម្បីធ្វើឲ្យកម្រងឯកសារនេះកាន់តែមានសារប្រយោជន៍ដល់ការលើកកម្ពស់ការបង្រៀន និងរៀនថែមទៀត។

គ្រូឧទ្ទេសថ្នាក់ជាតិ
និង
ក្រុមការងារគម្រោងអប់រំគ្រូវិទ្យាសាស្ត្រ (STEPSAM2)

# មាតិកា

គណៈកម្មការនិពន្ធ ..... I

អារម្ភកថា..... II

មាតិកា..... III

## ១. កិច្ចតែងការបង្រៀនគម្រូរបស់គ្រូឧទ្ទេសថ្នាក់ជាតិ

### ១.១. រូបវិទ្យា

១.១.១ លំនឹងនៃអង្គធាតុរឹង ..... 1

១.១.២ ម៉ាញ៉េទិច ..... 7

### ១.២. គីមី

១.២.១ ចំណែកថ្នាក់រូបធាតុ..... 15

១.២.២ ការកំណត់បរិមាណអំបិលក្នុងសូលុយស្យុង ..... 21

### ១.៣. ជីវវិទ្យា

១.៣.១ ពិនិត្យបេះដូងជ្រូក ..... 27

១.៣.២ ការវាស់ថាមពលក្នុងអាហារ..... 36

១.៣.៣ បណ្តូរទឹកក្នុងកោសិកា ..... 43

### ១.៤. ផែនដីវិទ្យា

១.៤.១ សិលា ..... 51

១.៤.២ តារានិករ ឬកញ្ចុំផ្កាយ ..... 56

## ២. កិច្ចតែងការបង្រៀនគម្រូរបស់សិក្ខាកាម

### ២.១. រូបវិទ្យា

២.១.១ រង្វាស់អាំងតង់ស៊ីតេកម្លាំងកកិត..... 61

២.១.២ ចរន្តអគ្គិសនី ..... 69

**២.២. គីមី**

២.២.១ រំហួត ........ 75

២.២.២ ទឹក ........ 81

**២.៣. ជីវវិទ្យា**

២.៣.១ ឥទ្ធិពលគ្រឿងញៀនទៅលើសត្វ ........ 89

២.៣.២ ជំងឺផ្តាសាយបក្សី(ការឆ្លងពីសត្វទៅមនុស្ស) ........ 94

**២.៤. ផែនដីវិទ្យា**

២.៤.១ វដ្តទឹក ........ 103

២.៤.២ ថាមពលកម្តៅ ........ 100

## ៣. ផែនការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅក្នុងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

**៣.១. ខេត្តបាត់ដំបង ........ 117**

**៣.២. ខេត្តកំពង់ចាម ........ 120**

**៣.៣. ខេត្តកណ្តាល ........ 123**

**៣.៤. រាជធានីភ្នំពេញ ........ 126**

**៣.៥. ខេត្តព្រៃវែង ........ 129**

**៣.៦. ខេត្តតាកែវ ........ 135**

## ១. កិច្ចតែងការបង្រៀនគម្រូរបស់គ្រូឧទ្ទេសថ្នាក់ជាតិ

### ១.១. រូបវិទ្យា

#### ១.១.១ លំនឹងនៃអង្គធាតុរឹង

#### ១.១.២ ម៉ាញ៉េទិច

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ រូបវិទ្យា, ថ្នាក់ទី១១, ជំពូកទី១, មេរៀនទី២

២. ប្រធានបទ៖ លំនឹងនៃអង្គធាតុរឹង

៣. វត្ថុបំណង៖

- សិស្សអាចរកឲ្យឃើញនូវល័ក្ខណលំនឹងនៃអង្គធាតុរឹងពីការធ្វើពិសោធន៍ជាក់ស្តែង។
- រៀបចំប្លង់ពិសោធ និងធ្វើពិសោធដើម្បីរកល័ក្ខណលំនឹង នៃអង្គធាតុរឹង ប្រើប្រាស់សម្ភារជាក់ស្តែង។
- សិស្សចូលរៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងយកទៅអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

៤. រយ:ពេល៖ ៥០នាទី

៥.សម្ភារៈឧបទ្ទេស៖

- ជញ្ជីង ឬឌីណាម៉ូម៉ែត្រ, កូនកាំបិត, ខ្សែអំបោះ, ធាងចេក និងបន្ទាត់ក្រិត។

| រយៈពេល | សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|---|
| 5នាទី | រំលឹកមេរៀនចាស់<br>– អ្វីទៅជាកម្លាំង?<br><br><br><br>– អ្វីទៅជាទីប្រជុំទម្ងន់របស់អង្គធាតុ?<br><br><br>– តើទម្ងន់ជាអ្វី? | – កម្លាំងគឺជាបុព្វហេតុដែលធ្វើឲយអង្គធាតុផ្លាស់ប្តូរល្បឿននិងខូចទ្រង់ទ្រាយ<br><br><br>– ទីប្រជុំទម្ងន់របស់អង្គធាតុគឺជាចំនុចដែលអាចទ្រទម្ងន់ទាំងមូលរបស់អង្គធាតុឲ្យមានលំនឹងបាន។<br><br>– ម្ងន់ជាកម្លាំងទំនាញដី។ | – ចលនាសាច់ដុំ<br>– រុញ ឬទាញទៅលើវត្ថុអ្វីមួយ<br>– គឺជាចំនុចកណ្តាលនៃអង្គធាតុ។<br>– ទីប្រជុំទម្ងន់របស់អង្គធាតុគឺជាចំនុចដែលអាចទ្រទម្ងន់ទាំងមូលរបស់អង្គធាតុឲ្យមានលំនឹងបាន។<br>– ទម្ងន់ជាកម្លាំងទាញចុះក្រោម។<br>– ទម្ងន់ជាកម្លាំងទំនាញដី។ |

| | | | |
|---|---|---|---|
| ៥នាទី | មេរៀនថ្មី<br>- ព្យួរផាងចេកជាមួយខ្សែអំបោះឲ្យមានលំនឹងបង្ហាញសិស្សឲ្យសង្កេត។ សួរសិស្ស ហេតុអ្វីបានជាផាងចេកនេះមានលំនឹង? ប្រសិនបើខ្ញុំកាត់ផាងចេកនេះត្រង់ខ្សែចំណងហើយយកទៅថ្លឹងនឹងជញ្ជីងរ៉ឺស័រ។តើផ្នែកទាំងពីរនៃផាងចេកមានទម្ងន់ស្មើគ្នាឬទេ?<br>- អោយសិស្សពីរនាក់កាត់ផាងចេកហើយថ្លឹងវា។<br>- តើអ្នកគិតយ៉ាងដូម្ដេចចំពោះលទ្ធផលនេះ។ | <br> | - សង្កេត<br>- គិត<br>▪ ស្មើគ្នា<br>▪ មិនស្មើគ្នា<br>- សិស្សកាត់ ហើយថ្លឹងសិស្សដទៃទៀតសង្កេត។<br>- ពួកគេឆ្ងល់ ហើយគិត។ |
| **សំណួរគន្លឹះ ហេតុអ្វីបានជាផាងចេកមានលំនឹង បើផាងចេកទាំងសងខាងមានទម្ងន់ខុសគ្នា?** | | | |
| ១០ នាទី | បង្កើតសម្មតិកម្ម<br>- ចែកសិស្សជាក្រុម។<br>-ចែកសន្លឹកកិច្ចការឲ្យសិស្សដើម្បីបំពេញចម្លើយស្មានទុក។<br>- តម្រុយៈ រកទីប្រជុំទម្ងន់នៃផាងចេកទាំងពីរខាង ដោយប្រើចំណេះដឹងនៃកម្លាំងរង្វិល។<br>-ហេតុអ្វីបានជាក្មេងមានម៉ាសខុសគ្នាអាចធ្វើឲ្យមានលំនឹងបាននៅលើ seesaw។ | ផ្នែកទាំងសងខាងនៃអ័ក្សរង្វិលមានតម្លៃផលគុណប្រវែងពីទីប្រជុំទម្ងន់ និងទម្ងន់មានតម្លៃស្មើគ្នាប៉ុន្តែមានទិសដៅរង្វិលផ្ទុយគ្នា ដូច្នេះធ្វើឲ្យវាមានលំនឹង។ | ចម្លើយរំពឹងទុក<br>- អង្គុយពិភាក្សាជាក្រុម។<br>- គិត ព្យាយាមរកចម្លើយដោយប្រើប្រាស់តម្រុយ។<br>- បំពេញចម្លើយក្នុងសន្លឹកកិច្ចកា។ |

| | | | |
|---|---|---|---|
| | - ឲ្យតំណាងក្រុមសិស្សឡើងពន្យល់ហេតុផលរបស់ពួកគេ។<br><br>- សួរសិស្សមានការផ្លាស់ប្តូរគំនិតរបស់ពួកគេទេ។<br><br>- តើធ្វើយ៉ាងដូចម្តេច ដើម្បីផ្ទៀងផ្ទាត់សម្មតិកម្មរបស់អ្នក។<br><br>- សំយោគគំនិតរបស់សិស្ស ដើម្បីបានជាប្លង់ពិសោធន៍រួមមួយ។ | | - តំណាងក្រុមសិស្សឡើងពន្យល់ហេតុផលរបស់ពួកគេដោយប្រើការគិតតាមបែបវិទ្យាសាស្ត្រ។<br><br>- សិស្សមួយចំនួនផ្លាស់ប្តូរគំនិត។<br><br>-ព្យាយាមធ្វើប្លង់ពិសោធនិងបង្ហាញពីគំនិតតាមក្រុម។ |
| ១០ នាទី | ធ្វើពិសោធន៍<br><br>- ពន្យល់ដំណើរការពិសោធន៍ដោយបង្ហាញសម្ភារៈជាក់ស្តែង<br><br>-ចែកសម្ភារៈពិសោធន៍ដល់សិស្ស។ | | - ស្តាប់ និងសង្កេត<br><br>- អានសន្លឹកកិច្ចការហើយធ្វើពិសោធ ព្រមទាំងកត់ត្រាលទ្ធផលចូលក្នុងសន្លឹកកិច្ចការ។ |
| ១៥ នាទី | ប្រមូលទិន្នន័យ និងវិភាគលទ្ធផល<br><br>- គូសតារាងលទ្ធផលលើក្តារខៀន។<br><br>- ជ្រើសរើសលទ្ធផលត្រឹមត្រូវជាងគេ និងលទ្ធផលមិនត្រឹមត្រូវ ហើយឲ្យពួកគេឡើងពន្យល់ពីសកម្មភាពនិងដំណើរការរបស់ពួកគេ។<br><br>- ឲ្យពួកគេស្វែងរកនូវកំហុសរបស់ពួកគេ។ | ផលគុណនៃប្រវែងដៃឃ្នាស់ពីអ័ក្សរង្វិលទៅទីប្រជុំទម្ងន់និងកម្លាំង (ទម្ងន់)ត្រូវបានគេហៅថាម៉ូម៉ង់នៃកម្លាំងបង្វិល។ | - សិស្សតាមក្រុមនីមួយៗបង្ហាញលទ្ធផលរបស់ពួកគេលើក្តារខៀន។<br><br>- ពួកគេឡើងពន្យល់ ពីសកម្មភាពនិងដំណើរការរបស់ពួកគេ និងសិស្សដទៃទៀត។<br><br>- សិស្សព្យាយាមរកនូវកំហុសតាមរយៈការពន្យល់ដំណើរការ។ |

| | | | |
|---|---|---|---|
| | - តាមរយៈលទ្ធផលពិសោធន៍ តើអ្នកបានរកឃើញអ្វីខ្លះពីលទ្ធផលពិសោធន៍?<br><br>- តាមរយៈការរកឃើញរបស់អ្នក តើអ្នកអាចឆ្លើយនឹងសំនួរគន្លឹះបានទេ? | ម៉ូម៉ង់កម្លាំងនៃផ្នែកទាំងពីរមានតម្លៃស្មើគ្នា និងមានទិសដៅផ្ទុយគ្នា។ | - ផលគុណនៃទម្ងន់ និងប្រវែងពីអ័ក្សរង្វិលទៅទីប្រជុំទម្ងន់នៃផ្នែកទាំងពីរមានតម្លៃស្មើគ្នា តែមានទិសដៅផ្ទុយគ្នា។<br><br>- ឆ្លើយតបទៅនឹងសំនួរគន្លឹះ |
| ៥នាទី | សន្និដ្ឋាន<br><br>- សម្របសម្រួលសិស្សដើម្បីឲ្យសិស្សទាញសេចក្ដីសន្និដ្ឋានដោយខ្លួនឯង។<br><br>- សរសេរសេចក្ដីសន្និដ្ឋានសម្រេចលើក្ដារខៀន។ | កម្លាំង និងម៉ូម៉ង់ ជាទំហំវិចទ័រ ដូច្នេះកម្លាំងសរុប និងម៉ូម៉ង់សរុបមានអំពើលើអង្គធាតុនេះមានតម្លៃស្មើសូន្យ។<br><br>អង្គធាតុមួយស្ថិតនៅក្នុងលក្ខណលំនឹង ប្រសិនបើកម្លាំងសរុប និងម៉ូម៉ង់សរុបមានអំពើលើវាស្មើសូន្យ។ | - សិស្សព្យាយាមទាញសេចក្ដីសន្និដ្ឋាន ហើយសរសេរលើក្ដារខៀន។ |

# សន្លឹកកិច្ចការ

**សំនួរគន្លឹះ៖ ហេតុអ្វីបានជាធាងចេកមានលំនឹង បើធាងចេកទាំងសងខាងមានទម្ងន់ខុសគ្នា?**

**សម្មតិកម្ម៖**

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

**តារាងទិន្នន័យ៖**

កម្លាំងឡើងលើ (លំនឹងខ្សែ) (+)……………N

| ផ្នែកទី១ | | | | | ផ្នែកទី២ | | | | |
|---|---|---|---|---|---|---|---|---|---|
| N | 1 | 2 | 3 | តម្លៃមធ្យម | N | 1 | 2 | 3 | តម្លៃមធ្យម |
| ប្រវែង (mm) | | | | | ប្រវែង (mm) | | | | |
| ទម្ងន់ (N) | | | | | ទម្ងន់ (N) | | | | |
| លទ្ធផលនៃទម្ងន់និងប្រវែង (N.mm) | (+) | | | | លទ្ធផលនៃទម្ងន់និងប្រវែង (N.mm) | (–) | | | |
| លទ្ធផលសរុបនៃទម្ងន់និងប្រវែង (N.mm) | | | | | | | | | |
| ទម្ងន់សរុប (N) | (–) | | | | | | | | |
| កម្លាំងសរុប (N) | | | | | | | | | |

តើអ្នករកឃើញអ្វីខ្លះពីលទ្ធផល?

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

តើអ្នកអាចឆ្លើយនឹងសំណួរគន្លឹះបានទេ?

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

សន្និដ្ឋានៈ

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ រូបវិទ្យា, ថ្នាក់ទី៨

២. ប្រធានបទ៖ ម៉ាញេទិច

៣. វត្ថុបំណង៖

- បង្ហាញពីកត្តាដែលអាចធ្វើឲប្រែប្រួលកម្លាំងឆក់ទាញរបស់មេដែកអគ្គិសនីតាមរយៈការធ្វើពិសោធបានត្រឹមត្រូវ។
- បង្កើតមេដែកអគ្គិសនីបានច្បាស់លាស់តាមរយៈការពិសោធជាក់ស្ដែង។
- មានបម្រុងប្រយ័ត្នក្នុងពេលធ្វើពិសោធន៍នៅក្នុងថ្នាក់។

៤. រយៈពេល៖ ៥០នាទី

៥. សម្ភារឧបទ្ទេស៖

- ថ្មពិល, ខ្សែទង់ដែង, ម្ជុលបារាំង, ដែកគោល, ឃ្នាបគាបក្រដាស, របាឈើ និងលោហៈ។

| រយៈពេល | សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|---|
| ២ នាទី | – គ្រូបង្ហាញអំពីប្រភេទមេដែកអចិន្ត្រៃយ៍។<br><br>– តើមានសម្ភារអ្វីខ្លះដែលមេដែកអាចឆក់ទាញបាន និងមិនអាចឆក់ទាញបាន? | **ជំហានទី២**<br><br>– របាមេដែក មេដែករាង **U** មេដែករាងជារង្វង់។<br><br>– សម្ភារដែលមេដែកអាចឆក់ទាញបានមាន៖<br><br>ម្ជុលបារាំង ដែកគោល ឃ្នាបគាបក្រដាស<br><br>– សម្ភារដែលមេដែកមិនអាចឆក់ទាញបានមានរបាឈើ របា<br><br>ទង់ដែង បន្ទះអាលុយមីញ៉ូម ក្រដាស។ | – សង្កេតការបង្ហាញ និងអនុវត្ត។<br><br>– សរសេរចម្លើយលើក្ដារខៀន។ |

| | | | |
|---|---|---|---|
| ៥ នាទី | | ជំហានទី៣ មេរៀនប្រចាំថ្ងៃ<br><br>មេដែក | |
| | - គ្រូបង្ហាញពិសោធដោយប្រើរបុំខ្សែទង់ដែងមានដែកគោលជាស្នូលភ្ជាប់និងចរន្តអគ្គិសនី។ | - របុំខ្សែទង់ដែង ដែកគោល ថ្មពិល៣ដុំ។ | - សង្កេតការពិសោធន៍របស់គ្រូ។ |
| | - តើមានភាពខុសគ្នាអ្វីខ្លះរវាងមេដែក អចិន្ត្រៃយ៍និងមេដែកអគ្គិសនី? | - មេដែកអចិន្ត្រៃយ៍អាចឆក់ទាញម្ជុលដោយ មិនចាំមានចរន្តអគ្គិសនីចំណែកមេដែក អគ្គិសនីអាចឆក់ទាញម្ជុលដោយប្រើចរន្តអគ្គិសនី។<br><br><u>សំនួរគន្លឹះ តើកត្តាអ្វីខ្លះដែលអាចធ្វើឲ្យកម្លាំងឆក់ទាញរបស់មេដែកអគ្គិសនីប្រែប្រួល?</u> | - សិស្សឆ្លើយ មេដែកអចិន្ត្រៃយ៍អាចឆក់ទាញម្ជុលបានច្រើនហើយមេដែកអគ្គិសនីអាចឆក់ទាញម្ជុលដោយប្រើចរន្តអគ្គិសនី។ |
| | - ចែកសន្លឹកកិច្ចការនិងសួរសំនួរគន្លឹះ។<br><br>- ចែកសិស្សជាក្រុម (សិស្សពិភាក្សាតាមក្រុម)។ | - កត្តាដែលអាចធ្វើឲ្យកម្លាំងឆក់ទាញរបស់មេដែកអគ្គិសនីប្រែប្រួលមានៈ<br>- បម្រែបម្រួលចរន្តអគ្គិសនី<br>- បម្រែបម្រួលចំនួនជុំខ្សែទង់ដែង។<br>- ធម្មជាតិនៃស្នូល | - សិស្សសរសេរសម្មតិកម្មក្នុងសន្លឹកកិច្ចការរួច ឡើងសរសេរលើក្តារខៀន<br><br>- សិស្សឡើងពន្យល់តាមក្រុម |
| | - ចែកសម្ភារពិសោធតាមក្រុមនិងបង្ហាញលក្ខខណ្ឌធ្វើពិសោធ។ | - ពិសោធដោយផ្លាស់ប្តូរស្នូល រាប់ចំនួនម្ជុលដែលអាចឆក់បាន។ | - ទទួលសម្ភារពិសោធ។ |
| | - ក្រុម១ ប្រើថ្មពិល៣ដុំ ខ្សែទង់ដែង៥០ជុំ ផ្លាស់ប្តូរស្នូល។ | - ប្រើស្នូលដែកគោលអាចឆក់ម្ជុលបានច្រើន។<br><br>- ប្រើថ្មពិល១ ២ និង៣។ | - កត់ត្រាលទ្ធផលបំពេញក្នុងតារាង។ |

| | | | |
|---|---|---|---|
| | -ក្រុម២ ប្រើស្នូលដែកគោល ខ្សែទង់ដែង៤០ជុំ ផ្លាស់ប្តូរថ្មពិល។<br>- ក្រុម៣ប្រើថ្មពិល៣ជុំស្នូលដែកគោលផ្លាស់ប្តូរចំនួនជុំ។<br>- គ្រូឲ្យសិស្សប្រៀបធៀបលទ្ធផលពិសោធ ជាមួយនិងសម្មតិកម្ម។<br><br>- ឲ្យសិស្សសរសេរសន្និដ្ឋានលើសន្លឹកកិច្ចការនិងសរសេរលើក្តារខៀន។ | - ប្រើថ្មពិល៣ជុំអាចឆក់ម្ជុលបានច្រើន។<br><br>- រុំខ្សែទង់ដែង២០ជុំ ៣០ជុំ និង ៤០ជុំ។<br>- របុំ៤០ជុំអាចឆក់ម្ជុលបានច្រើន។<br><br>- សន្និដ្ឋាន កម្លាំងឆក់ទាញនៃមេដែកអគ្គិសនីអាចប្រែប្រួលបានអាស្រ័យនិង៖<br>- បម្រែបម្រួលចរន្តអគ្គិសនី<br>- បម្រែបម្រួលចំនួនជុំខ្សែទង់ដែង<br>- ធម្មជាតិនៃស្នូល។ | <br><br><br><br><br>- សិស្សប្រៀបធៀបលទ្ធផលពិសោធជាមួយនិងសម្មតិកម្ម។ |
| ៣ នាទី | <br>- តើមានសម្ភារអ្វីខ្លះដែលមេដែកអាចឆក់ទាញបាន និងមិនអាចឆក់ទាញបាន?<br><br><br><br>- តើយើងប្រើសម្ភារអ្វីខ្លះសម្រាប់បង្កើតមេដែកអគ្គិសនី?<br><br>- តើកម្លាំងឆក់ទាញនៃមេដែកអគ្គិសនីអាស្រ័យនិងកត្តាអ្វីខ្លះ? | ជំហានទី៤ ពង្រឹងចំណេះដឹង<br>- សម្ភារដែលមេដែកអាចឆក់ទាញបានមាន៖<br>ម្ជុលបារាំង ដែកគោល ឃ្នាបគាបក្រដាស<br>សម្ភារដែលមេដែកមិនអាចឆក់ទាញបានមានរបាឈើ របាទង់ដែង បន្ទះអាលុយមីញ៉ូម ក្រដាស។<br>- យើងប្រើសម្ភារសម្រាប់បង្កើតមេដែក។<br>អគ្គិសនីមានដូចជា ខ្សែទង់ដែង ដែកគោល ថ្មពិល។<br>- កម្លាំងឆក់ទាញនៃមេដែកអគ្គិសនីអាចប្រែប្រួលបានអាស្រ័យនិង៖ | <br>- សិស្សឆ្លើយ។ |

| | | | |
|---|---|---|---|
| | | – បម្រែបម្រួលចរន្តអគ្គិសនី<br>– បម្រែបម្រួលចំនួនជុំខ្សែ<br>ទង់ដែង<br>– ធម្មជាតិនៃស្នូល។ | |
| ២ នាទី | | ជំហាន៥ កិច្ចការផ្ទះ<br>ចូរស្វែងរកវត្ថុប្រើប្រាស់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដែលប្រើមេដែកអគ្គិសនី។ | |

# សន្លឹកកិច្ចការ

**លំនាំបញ្ហា**

- តើមានសម្ភារអ្វីខ្លះដែលមេដែកអាចឆក់ទាញបាននិងមិនអាចឆក់ទាញបាន?
- តើមានភាពខុសគ្នាអ្វីខ្លះរវាងមេដែកអចិន្ត្រៃយ៍និងមេដែកអគ្គិសនី?
- <u>សំនួរគន្លឹះ</u> ៖ <u>តើកត្តាអ្វីខ្លះដែលអាចធ្វើឲកម្លាំងឆក់ទាញរបស់មេដែកអគ្គិសនីប្រែប្រួល?</u>

សម្មតិកម្មៈ

..........................................................................................................................................................

..........................................................................................................................................................

**ពិសោធន៍**

**ក្រុមទី១**

**សម្ភារៈ** ខ្សែទង់ដែង ដែកគោល ម្ជុលបារាំង ថ្មពិល៣ដុំ

**ដំណើរការៈ** រុំខ្សែទង់ដែងឲ្យបាន២០ជុំ ៣០ជុំ និង៤០ជុំ

**លទ្ធផលៈ**

| ចំនួនជុំ | ចំនួនម្ជុលបារាំង |
|---|---|
| ២០ជុំ | |
| ៣០ជុំ | |
| ៤០ជុំ | |




តើអ្នករកឃើញអ្វីខ្លះពីលទ្ធផលពិសោធរបស់អ្នក?

ក្រុមទី២

**សម្ភារ៖** ខ្សែទង់ដែង ដែកគោល របាដែក របាឈើ របាជ័រ របាទង់ដែង ម្ជុលបារាំង ថ្មពិល

**ដំណើការ៖** រុំខ្សែទង់ដែង៤០ជុំ ថ្មពិល៣ដុំ។

លទ្ធផល

| ធម្មជាតិនៃស្នូល | ចំនួនម្ជុលបារាំង |
|---|---|
| របាដែក | |
| របាឈើ | |
| របាជ័រ | |
| ដែកគោល | |
| របាទង់ដែង | |




តើអ្នករកឃើញអ្វីខ្លះពីលទ្ធផលពិសោធរបស់អ្នក?

ក្រុមទី៣

**សម្ភារ៖** ខ្សែទង់ដែង ដែកគោល  ម្ជុលបារាំង ថ្មពិល៣ដុំ

**ដំណើរការ៖** បង្កើនចំនួនថ្មពិល




លទ្ធផល

| ចំនួនថ្មពិល | ចំនួនម្ជុល |
|---|---|
| ចំនួនថ្មពិល១ដុំ | |
| ចំនួនថ្មពិល២ដុំ | |
| ចំនួនថ្មពិល៣ដុំ | |

តើអ្នករកឃើញអ្វីខ្លះពីលទ្ធផលពិសោធរបស់អ្នក?

តាមរយៈការរកឃើញរបស់អ្នក តើអ្នកអាចសន្និដ្ឋានបានយ៉ាងដូចម្តេច?

សន្និដ្ឋាន៖

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

# ប្លង់ក្តារខៀន

**លំនាំបញ្ហា**

- តើមានសម្ភារអ្វីខ្លះដែលមេដែកអាចឆក់ទាញបាននិងមិនអាចឆក់ទាញបាន?
- តើមានភាពខុសគ្នាអ្វីខ្លះរវាងមេដែកអចិន្ត្រៃយ៍និងមេដែកអគ្គិសនី?
- សំនួរគន្លឹះ ៖ តើកត្តាអ្វីខ្លះដែលអាចធ្វើឲកម្លាំងឆក់ទាញរបស់មេដែកអគ្គិសនីប្រែប្រួល?

**សម្មតិកម្មៈ**

..........................................................................................................................

..........................................................................................................................

**ពិសោធន៍**

លទ្ធផលពិសោធន៍តាមក្រុមនីមួយៗ




សន្និដ្ឋានៈ

តាមរយៈការរកឃើញរបស់អ្នក តើអ្នកអាចសន្និដ្ឋានបានយ៉ាងដូចម្ដេច?

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

-------------------------------------------------------------------------------- ។

--------------------------------------------------------------------------------

## ១.២. គីមី

### ១.២.១ ចំណែកថ្នាក់រូបធាតុ

### ១.២.២ ការកំណត់បរិមាណអំបិលក្នុងសូលុយស្យុង

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ គីមី, ថ្នាក់ទី៧

២. ប្រធានបទ៖ ចំណែកថ្នាក់រូបធាតុ

***ផែនការបង្រៀន***

- **មូលដ្ឋានសិស្ស៖** មកដល់មេរៀននេះ សិស្សត្រូវបានគិតថាមានរៀនរួមមកហើយនូវបញ្ញត្តិជាមូលដ្ឋានស្តីអំពីរូបធាតុ ក្នុងមេរៀនទី១ នៃជំពូកនេះ ដូចជា និយមន័យរបស់រូបធាតុ ភាពរូបរបស់រូបធាតុ ជាដើម។
- **មេរៀនថ្ងៃនេះ** សិស្សនឹងធ្វើការបែងចែករូបធាតុជាក្រុមផ្សេងៗគ្នាអាស្រ័យដោយលក្ខណៈរបស់វា។ ដូចដែលយើងបានដឹងហើយថា គេអាចបែងចែករូបធាតុបានជាច្រើនក្រុម ដោយសារលក្ខណៈរូបរបស់វាខុសៗគ្នា ប៉ុន្តែនៅក្នុងមេរៀននេះ យើងលើកយកលក្ខណៈតែពីរប៉ុណ្ណោះសម្រាប់ឲ្យសិស្សធ្វើការសិក្សាប្រៀបធៀបគឺ ការចម្លងចរន្តអគ្គិសនី និងការលិច ឬអណ្តែតក្នុងទឹក (ដង់ស៊ីតេ)។ រីឯ លក្ខណៈផ្សេងៗទៀត នឹងត្រូវបានផ្តល់ឲ្យសិស្សគិតរកបន្តតាមរយៈកិច្ចការផ្ទះ ដែលសិស្សអាចមានឱកាសរកមើលបន្ថែម តាមរយៈអានសៀវភៅសិក្សា ឬក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។
- **មេរៀនបន្ទាប់៖** សិស្សនឹងរៀនបន្ថែមអំពីលក្ខណៈផ្សេងៗទៀតរបស់រូបធាតុ តាមរយៈការផ្តល់ឱកាសឲ្យសិស្សបានបង្ហាញចម្លើយកិច្ចការផ្ទះរបស់ពួកគេតាមក្រុម ដល់ក្រុមផ្សេងទៀតនៅក្នុងថ្នាក់ និងក្រោមការសម្របសម្រួលរបស់គ្រូ ផ្សារភ្ជាប់ជាមួយនឹងខ្លឹមសារនៅក្នុងសៀវភៅសិក្សា។

៣. វត្ថុបំណង៖ បន្ទាប់ពីរៀនមេរៀននេះ សិស្សនឹងអាច៖

- ពិពណ៌នាលក្ខណៈរូបមួយចំនួនរបស់រូបធាតុបានត្រឹមត្រូវតាមរយៈការសង្កេតពិសោធន៍ និងការពិភាក្សាក្រុម
- ធ្វើការបែបចែករូបធាតុទៅតាមក្រុមសមស្រប ដោយផ្អែកលើលក្ខណៈរូបរបស់វាដែលរកឃើញតាមពិសោធន៍ និងការពិភាក្សារបស់សិស្សតាមក្រុម។
- បង្កើនចំណាប់អារម្មណ៍សិស្សទៅលើការអនុវត្តជាក់ស្តែងរបស់រូបធាតុផ្សេងៗក្នុងជីវភាពប្រចាំថ្ងៃ ដោយផ្អែកលើលក្ខណៈរូបរបស់វា ព្រមទាំងបង្កើនស្មារតីទទួលខុសត្រូវខ្ពស់លើការសហការក្នុងក្រុម រៀនធ្វើការជាមួយគ្នាដើម្បីដោះស្រាយបញ្ហា។

៤. រយៈពេល៖ ៥០នាទី

៥. សម្ភារឧបទេ្ទស៖

- រូបធាតុមួយចំនួន (ដែកគោលគ្មានច្រែះ ដុំឈើ បណ្ដូលខ្មៅដៃ ឆ្នុកជ័រ បំណែកសំបកដបទឹកសុទ្ធ ថ្ម) ឧបករណ៍ចម្លងចរន្ត (ថ្មពិល ខ្សែភ្លើង អំពូល) ទឹកកកន្លះកែវ។

| | សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|---|
| ២ នាទី | គ្រូតពិនិត្យ វិន័យ អនាម័យ និងអវត្តមាន។ | **ជំហានទី១៖ លំនឹងថ្នាក់** | សិស្សអង្គុយតាមក្រុមដែលបានរៀបចំ។ |
| ៣ នាទី | – ប្អូនបានរៀនរួចមកហើយ អំពីរូបធាតុ នៅមេរៀនមុន។ តើអ្វីទៅជារូបធាតុ?<br>– តើរូបធាតុមានភាពរូបអ្វីខ្លះ? | **ជំហានទី២៖ រំឭកមេរៀន**<br>– និយមន័យ និងភាពរូបនៃរូបធាតុ។ | – វត្ថុដែលនៅជុំវិញខ្លួនយើងមានមាឌ និងម៉ាស ហៅថារូបធាតុ។<br>– រូបធាតុមានភាពរូប៣ គឺ រឹង រាវ និងឧស្ម័ន។ |
| ៥ នាទី | – តើប្អូនអាចប្រាប់ឈ្មោះរូបធាតុរឹងដែលប្អូនស្គាល់បានទេ? មានអ្វីខ្លះ?<br>=>*សរសេរចម្លើយទាំងអស់របស់សិស្សលើក្ដារខៀន។*<br>– តើរូបធាតុរឹងទាំងនេះ គេអាចប្រើវាក្នុងគោលបំណងដូចគ្នាបានដែរឬទេ? ហេតុអ្វី? ចូរពន្យល់ និងលើកឧទាហរណ៍។<br>=> *បង្ហើបអំពីលក្ខណៈចម្លងចរន្តរបស់រូបធាតុប្លាស្ទិច និងលោហៈ* | **ជំហានទី៣៖ មេរៀនថ្មី**<br>**សេចក្ដីផ្ដើម**<br><បម្រើបម្រាស់រូបធាតុក្នុងជីវភាពប្រចាំថ្ងៃ>។ | – ឧទាហរណ៍នៃរូបធាតុ៖ សៀវភៅ តុ ប៊ិច ក្រដាស ដែក...។<br>– ទេ គេមិនអាចប្រើរូបធាតុរឹងទាំងអស់ក្នុងគោលបំណងដូចគ្នាទេ ព្រោះវាមានលក្ខណៈខុសគ្នា។ ឧ. គេប្រើលោហៈជាខ្សែភ្លើង រឹងជ័រស្រោបពីក្រៅខ្សែភ្លើង ដើម្បីការពារកុំឲ្យឆក់។ |

| សំណួរគន្លឹះ ៖ តើយើងអាចធ្វើការបែងចែករូបធាតុរឹងជាក្រុមបានយ៉ាងដូចម្តេច? | | | |
|---|---|---|---|
| ១០ នាទី | - សំណួរបំផុសៈ តើលក្ខណៈរូបអ្វីខ្លះដែលប្អូនអាចប្រើដើម្បីចែករូប ធាតុរឹងជាក្រុម?<br>-ឲ្យសិស្សផ្តល់យោបល់ តាមរយៈការពិភាក្សាក្រុម។<br>=>*សរសេររាល់ចម្លើយសិស្សលើក្តារខៀន ។*<br>- ឥឡូវចូរយើងផ្តោតតែទៅលើលក្ខណៈរូបពីរ សម្រាប់ធ្វើការអង្កេតនៅថ្ងៃនេះ គឺៈ ការចម្លងចរន្តអគ្គិសន្នី និងលិច ឬអណ្តែតរបស់រូបធាតុ។ ដូច្នេះចូរ ប្អូនចាត់ក្រុមរូបធាតុទៅតាមភាពរូបទាំងពីរនេះ។ | **សម្មតិកម្មៈ**<br>បំណែងចែករូបធាតុតាមក្រុម ទៅតាមលក្ខណៈរូបដូចគ្នា។<br>- ពិភាក្សាតាមក្រុម និងបំពេញសន្លឹកកិច្ចការ។<br>- បង្ហាញគំនិតរបស់ពួក គេដល់ក្រុមដទៃ និងប្រាប់ពីមូលហេតុ។ | - បំណែងចែកអាចធ្វើឡើងដោយផ្អែកលើលក្ខណៈរូបជាច្រើននៃរូបធាតុដូចជា ពណ៌ រូបរាង របឹង ស្រាល ធ្ងន់ ក្លិន លិច ឬអណ្តែតទឹក។ |
| ៥ នាទី | - តើត្រូវធ្វើដូចម្តេចដើម្បីដឹងថាការគិតរបស់ប្អូនត្រឹមត្រូវ?<br>- សរុបយោបល់សិស្ស និងចែកសម្ភារដែលរៀបចំទុកជាស្រេចដល់សិស្ស។<br>- បញ្ជាក់ឡើងវិញនូវដំណើរការពិសោធន៍ ដែលនឹងត្រូវធ្វើឡើងដោយសិស្ស។ | **ការរៀបចំប្លង់ពិសោធន៍** | - គិតអំពីដំណើរការ និងសម្ភារដែលពួកគេត្រូវប្រើ ដើម្បីបញ្ជាក់លើការប៉ាន់ស្មានរបស់ពួកគេ។<br>- យកសម្ភារពីគ្រូ និងបញ្ជាក់ពីដំណើរការដែលត្រូវធ្វើឡើងវិញ។ |

| | | | |
|---|---|---|---|
| ១៥ នាទី | – គ្រូតពិនិត្យតាមក្រុម ថាតើសិស្សធ្វើពិសោធន៍បានសមស្រប ឬទេ និងជួយពួកគេក្នុងករណីចាំបាច់។ | **ពិសោធន៍**<br>– ចម្លងចរន្តអគ្គិសនី<br>– លិច ឬអណ្តែតក្នុងទឹក | – ធ្វើពិសោធន៍តាមក្រុមនិងកត់ត្រាលទ្ធផលចូលក្នុងសន្លឹកកិច្ចការ។ |
| ១០ នាទី | – ឲ្យសិស្សឡើងបង្ហាញពីអ្វីដែលគេរកឃើញដល់ក្រុមដទៃទៀត។<br>– សង្ខេបលទ្ធផលសិស្ស និងជួយសិស្សឲ្យទាញសេចក្តីសន្និដ្ឋាន។ | **សិស្សបង្ហាញលទ្ធផល** | – បង្ហាញលទ្ធផលដល់ក្រុមដទៃ និង ធ្វើសេចក្តីសន្និដ្ឋាន ដោយឆ្លើយសំណួរនៅក្នុងសន្លឹកកិច្ចការ។ |
| | **សន្និដ្ឋាន៖** រូបធាតុទាំងនោះចែកជាបីក្រុមគឺ ក្រុម១៖ លិចក្នុងទឹក និងចម្លងអគ្គិសនី មាន ដែក និងបណ្តូលខ្មៅដៃ ក្រុម២៖ អណ្តែតលើទឹក និងមិនចម្លងចរន្តអគ្គិសនី មានឈើ និងផ្កុកជ័រ និងក្រុម៣៖ លិចក្នុងទឹក និងមិនចម្លងចរន្តអគ្គិសនី មានថ្ម និងបំណែកដបទឹកសុទ្ធ។ | | |
| ៣ នាទី | – តើយើងអាចប្រើឈើធ្វើជាខ្សែចម្លងអគ្គិសនីបានឬទេ? ហេតុអ្វី?<br>– តើយើងអាចប្រើជ័រសម្រាប់ធ្វើទូកបានឬទេ? ហេតុអ្វី? | **ជំហានទី៤៖ ពង្រឹងពុទ្ធិ** | – ទេ ឈើមិនអាចចម្លងចរន្តអគ្គិសនីបានទេ។<br>– បាទ/ចាំ បាន ព្រោះវាអណ្តែតលើទឹក។ |
| ២ នាទី | - ចែកសំណួរសម្រាប់កិច្ចការផ្ទះដល់សិស្ស។ | **ជំហានទី៥៖ កិច្ចការផ្ទះ**<br>*សំណួរ៖ ក្រៅពីភាពរូបទាំងពីរ តើមានភាពរូបអ្វីខ្លះផ្សេងទៀត ដែលប្អូនអាចប្រើសម្រាប់ធ្វើការបែងចែករូបធាតុជាក្រុមបាន។* | - កត់កិច្ចការដែលត្រូវធ្វើបន្តនៅផ្ទះ។ |

# សន្លឹកកិច្ចការ

## សេចក្តីផ្តើម

អ្វីទៅជា *រូបធាតុ*?

.............................................................................................................................................

.............................................................................................................................................

ចូររកឧទាហរណ៍រូបធាតុរឹងដែលប្អូនស្គាល់៖

.............................................................................................................................................

.............................................................................................................................................

តើគេអាចប្រើរូបធាតុរឹងទាំងនោះក្នុងគោលបំណងដូចគ្នាដែរ ឬទេ? ហេតុអ្វី?

.............................................................................................................................................

.............................................................................................................................................

ចូររកឧទាហរណ៍បញ្ជាក់៖

## សំណួរគន្លឹះ

| |
|---|
| |

**ចម្លើយស្មានទុក៖** (ចូរបំពេញចន្លោះខាងក្រោមដោយគំនិតប្អូនផ្ទាល់)

(1) យើងអាចធ្វើការបែងចែករូបធាតុរឹងជាក្រុមដោយផ្អែកទៅលើលក្ខណៈរបស់វាដូចជា៖

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

(2) ចូរយើងផ្តោតទៅលើលក្ខណៈរូបពីរគឺ (១) *ចម្លងចរន្តអគ្គិសនី* និង (២) *លិចក្នុងទឹក*។ ចូរពិភាក្សាតាមក្រុមដើម្បីញែកវត្ថុដែលបានផ្តល់ឲ្យទៅតាមភាពរូបសមស្រប ដោយបំពេញក្នុងតារាងខាងក្រោមៈ

*សំគាល់ៈ* ចូរប្រើសញ្ញា ✔ សម្រាប់ចម្លើយ *ឯកភាព* និងសញ្ញា X សម្រាប់ចម្លើយ *បដិសេធ*។

| ឈ្មោះវត្ថុ | ចម្លើយប៉ាន់ស្មាន | |
|---|---|---|
| | ចម្លងចរន្តឬទេ? | លិចក្នុងទឹក ឬទេ? |
| ១. | | |
| ២. | | |
| ៣. | | |
| ៤. | | |
| ៥. | | |
| ៦. | | |

**ប្លង់ពិសោធន៍ៈ** *ចូរពិភាក្សាក្នុងក្រុមអំពីសម្ភារ និងដំណើរការពិសោធន៍របស់អ្នក។*

| |
|---|
| *ចូរសរសេរ ឬគូររូបអំពីដំណើរការរបស់អ្នកនៅក្នុងប្រអប់នេះ* |

*ចូរបញ្ជាក់អំពីការបាន់ស្មានរបស់អ្នក!!*

| លទ្ធផលពិសោធន៍ | |
|---|---|
| ចម្លងចរន្តឬទេ? | លិចក្នុងទឹក ឬទេ? |
| | |
| | |
| | |
| | |
| | |
| | |

**ការពិភាក្សា និងសេចក្តីសន្និដ្ឋាន**

1. តើចម្លើយប៉ាន់ស្មានណាខ្លះដែលខុសពីលទ្ធផលពិសោធន៍ជាក់ស្តែង?
   .______________________________________________
2. ដោយផ្អែកលើលទ្ធផលពិសោធន៍ តើប្អូនអាចចែករូបធាតុដែលផ្តល់ឲ្យជាប៉ុន្មានក្រុម? អ្វីខ្លះ?
   .______________________________________________
3. តើគេអាចប្រើលោហៈដែក ជាខ្សែភ្លើងជំនួស លោហៈទង់ដែងបានដែរឬទេ? ហេតុអ្វី?
   .______________________________________________
4. តើគេអាចប្រើលោហៈដែក ជាខ្សែភ្លើងជំនួស លោហៈទង់ដែងបានដែរឬទេ? ហេតុអ្វី?
   .______________________________________________

# កិច្ចតែងការបង្រៀន

**១. មុខវិជ្ជា៖** គីម, ថ្នាក់ទី៨ (កម្មវិធីថ្មី)

**២. ប្រធានបទ៖** ការកំណត់បរិមាណអំបិលសម្លក្នុងសូលុយស្យុង

ក. មុននឹងបង្រៀនមេរៀននេះសិស្សបានរៀនរួចហើយអំពី
- ល្បាយ និងវិធីញែកល្បាយ
- លក្ខណៈនៃសូលុយស្យុង

ខ.មេរៀនដែលត្រូវបង្រៀនពេលនេះគឺ៖
- កំណត់និយមន័យ សូលុយស្យុង
- គណនាបរិមាណជាភាគរយនៃអំបិលសម្ល ក្នុងសូលុយស្យុងអំបិល

**៣. វត្ថុបំណង៖ ក្រោយសិក្សាមេរៀននេះចប់ពួកគេអាច**
- ចំណេះដឹង៖ ពិពណ៌នានិយមន័យសូលុស្យុងរាវ តាមរយៈការសង្កេតពិសោធន៍បានត្រឹមត្រូវ។
- បំណិន៖
  - ទាញយកបរិមាណក្រាមអំបិល (NaCl) ក្នុងសូលុយស្យុងទឹកអំបិល ឬទឹកសមុទ្រ តាមរយៈការធ្វើពិសោធន៍ ជាក្រុមបានត្រឹមត្រូវ។
  - គណនាភាគរយនៃក្រាមអំបិល (Nacl)ក្នុងសូលុស្យុងទឹកអំបិល ឬទឹកសមុទ្រ តាមរយៈការប្រើរូបមន្ត $\%C = \frac{m_1 \times 100}{m_s}$ ជាក្រុមបានត្រឹមត្រូវ។
- ឥរិយាបទ ៖ បង្កើនស្មារតីឆ្លៃប្រឌិត ក្នុងការបន្សុទ្ធអំបិលចេញ ពីទឹកសមុទ្រ និងអំបិលដីកង្វក់បាន ដោយ ប្រុងប្រយ័ត្ន និងការសហការគ្នាធ្វើការជាក្រុម។

**៤. រយៈពេល៖** ៦០នាទី

**៥. សម្ភារឧបទេ្ទស៖**
- ចង្រ្កានហ្គាស ចានដុតកំដៅ ស្លាបព្រា ជញ្ជីង ក្រណាតទ្រនាប់ដៃស្អាត វីកូនកន្សែង ម៉ាស៊ីនគិតលេខ ដបទឹក នាឡិកាក្រិត ដង្កៀបចាប់ ទឹក អំបិល ទឹកសមុទ្រ។

បម្រុងប្រយ័ត្ន ៖ ប្រយ័ត្នរលៀកដៃ ពេលដុតកំដៅ រឺការប្រើចង្រ្កានហ្គាស គឺដូចជា ក្រោយពេលដុត កំដៅចានស្ង. ត្រូវប្រាប់សិស្ស ឱ្យទុកវាប្រមាណ ២–៣នាទី សិនមុននឹងយកទៅថ្លឹង។

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
| --- | --- | --- |
| - អនាម័យថ្នាក់<br>- វត្តមានសិស្ស | ជំហានទី១<br>រដ្ឋបាលថ្នាក់ | - រៀបចំសណ្តាប់ធ្នាប់<br>- ប្រកាសអវត្តមានសមាជិក |
| ១. តើគេអាចញែកល្បាយស្មើសាច់ដោយវិធីណា?<br>២. តើគេអាចគណនាភាគរយអង្គធាតុសុទ្ធមួយក្នុងសមាសធាតុល្បាយ មួយបានដូចម្តេច?<br>ឧទាហរណ៍បញ្ជាក់។ | ជំហានទី២ រំលឹកមេរៀន<br>វិធីញែកល្បាយ<br>អង្គធាតុរលាយ និងរំលាយ | ១. បំណិតប្រភាគ រំហួត ដុតកំដៅ រឺដោយពន្លឺព្រះអាទិត្យ.........។<br>២. យកម៉ាសអង្គធាតុសុទ្ធ គុណនឹង១០០ ចែកម៉ាសល្បាយ ។<br>ឧទា. ល្បាយធ្យូងចំនួន 30g មាន កាបូនសុទ្ធ 6g នោះភាគរយវាគឺ<br>% កាបូនសុទ្ធ = $\frac{6g \times 100}{30g} = 20\%$ |
| ១. បង្ហាញថង់អំបិលសម្ល រួចសួរ តើនេះជាអ្វី? វាមានរូបមន្តដូចម្តេច? បានពីណា? មានផលប្រយោជន៍អ្វីខ្លះ?<br>២. បើយើងយក អំបិលសម្លទៅដាក់ក្នុងកែវទឹក តើមានអ្វីកើតឡើង? | ជំហានទី៣ មេរៀនប្រចាំថ្ងៃ<br>ការកំណត់បរិមាណអំបិលក្នុងស្វ.ទឹកអំបិល<br>១. សង្កេត (៥)<br>- ប្រៀបធៀបស្វូលុយស្យុងទឹកអំបិលសម្លនិងទឹកសមុទ្រ | សិស្សធ្វើការសង្កេតតាមដាន នឹងគិត<br>១. ជាអំបិល មានរូបមន្ត NaCl, បានពីផ្សារសមុទ្រ<br>២. អំបិលរលាយ ក្លាយជាអង្គធាតុរាវ ទឹកមាននាទីជាអង្គធាតុរំលាយ និងអំបិលមាននាទីជាធាតុរលាយ |

| | | |
|---|---|---|
| តើទឹកមាននាទីជាអ្វី? អំបិលមាននាទីជាអ្វី?<br><br>- បង្ហាញដបទឹកដែលមានដាក់ សូលុយស្យុងទឹកអំបិល និងទឹក សមុទ្រ ហើយប្រាប់សិស្សថា ដបទាំងពីរនេះជា សូលុយស្យុងទឹកដែល មានអំបិលដូចគ្នា គ្រាន់តែបរិមាណ វាអាចដូចគ្នា និងអាចខុសគ្នា ។<br><br>- ដោយយើងមិនអាចរកសូលុយស្យុងទឹកសមុទ្រ បានងាយ ក្នុងការអនុវត្តជាក់ស្តែងយើងប្រើ សូលុយស្យុងទឹកអំបិលវាងាយ និង ផ្តល់ជា សំណួរគន្លឹះ។ | | - សិស្សស្តាប់ គិតកត់ត្រាសំណួរគន្លឹះចូលសន្លឹកកិច្ចការ និងធ្វើការទស្សន៍ទាយ ចម្លើយព្រាងទុក ..... |
| ២. សំណួរគន្លឹះ (៣ នាទី) ៖ **តើយើងអាចកំណត់ភាគរយ របស់អំបិលសម្ល (*%NaCl*) ក្នុងសូលុយស្យុងទឹកអំបិល បានដូចម្តេច?** | | |
| - ឱ្យសិស្សគិត និងផ្តល់សំណួរ តើយើងត្រូវប្រើវិធីអ្វីដើម្បីញែកយកអំបិលពីសូលុយស្យុងទឹកអំបិល?<br><br>ត្រើតូវប្រើរូបមន្តអ្វីដើម្បី គណនាកំហាប់ភាគរយអំបិលក្នុងសូ បាន?<br><br>- តើត្រូវប្រើសម្ភារៈអ្វីខ្លះ ក្នុងការធ្វើពិសោធន៍ដើម្បីសម្រេចបានលទ្ធផល ។<br>- ប្រាប់ និង ដើរមើលសិស្សធ្វើការតាមក្រុម នែនាំសិស្សតាមក្រុម ឱ្យចេះស្រង់លទ្ធផល<br>- បំផុសសំណួរឱ្យសិស្សគណនា ភាគរយអំបិល តាមលទ្ធផលពិសោធន៍ | ១. សម្មតិកម្ម(៥នាទី)<br>- វិធី រំហួត រឺ បង្ហួតដោយ ដុតកំដៅ ...<br><br>- គណនាតាមរូបមន្តៈ<br><br>▪ $m_1$= mអំបិល = mចានសូ ទឹក – m ចាន<br><br>▪ $m_s$ = mចានអំបិលស្ងួត – mចាន និង<br><br>$\%C = \frac{m_{អំបិល} \times 100}{m_{សូលុយស្យុង}}$ | សិស្សធ្វើការគិត នឹងឆ្លើយ<br><br>- យកទឹកទៅ រំងាស់ រំហួត ដើម្បី ទាញម៉ាសអំបិល និងគណនាភាគរយ ។<br><br>- សិស្សគិត និង គូសរូប ចូលសន្លឹកកិច្ចការមាន ចានដុត ចង្ក្រាន ជញ្ជីង សូលុយស្យុងទឹកអំបិល ១ដប។<br>- ធ្វើសោធន៍ជាក្រុម សង្កេត និងកត់ត្រាលទ្ធផល គិត គណនា លទ្ធផលចូលតារាង។ |

**- ចូរធ្វើការពិភាក្សានូវសំណួរ**

- គេថាទឹកអំបិលសម្ល (NaCl) ជាសូលុយស្យុង ។ ហេតុអ្វី?

- ចូរកំណត់កំហាប់ ភាគរយនៃអំបិលសម្ល (NaCl)

- ធ្វើការសន្និដ្ឋានពិសោធន៍ខាងលើ ដោយផ្តល់ជាសំណួរ បានតើសូលុយស្យុងជាអ្វី? តើគេអាចកំណត់ភាគរយវាបានដូចម្តេច?

២. ប្លង់ពិសោធន៍(៥នាទី)

- តារាងលទ្ធផល (៥នាទី)

| ម៉ាសគិតជាក្រាម (m(G)) | | |
|---|---|---|
| ចាន(A) | ចាន និងសូ.ទឹក(B) | ចាន និងអំបិលស្ងួត(D) |
| 80.28 | 144.88 | 84.90 |

**- ពិភាក្សា ៖**

១. គេថាទឹកអំបិលសម្ល (NaCl)ជាសូលុយស្យុង។ ហេតុអ្វី?

..ព្រោះវាល្បាយស្មើសាច់ដែលបង្កឡើងដោយធាតុរលាយជាអំបិលសម្ល និង ទឹកជាអង្គធាតុរំលាយ ។

2. ចូរកំណត់កំហាប់ ភាគរយនៃអំបិលសម្ល (NaCl)

- $m_1 = m_E = 84.90 - 80.28 = 4.62g$
- $m_s = m_C = 144.88 - 80.28 = 64.6g$

$$\%C = \frac{m_1 \times 100}{m_s} = \frac{4.62g \times 100}{64.6g} = 7.15\%$$

៥. សន្និដ្ឋាន៖ គេអាចកំណត់ %NaCl ក្នុងសូលុយស្យុងទឹកអំបិលដែលពិសោធន៍ខាងលើ តាមវិធីដុតកំដៅ បង្ហួតទឹក ឱ្យអស់ ដើម្បីបានម៉ាសអំបិលស្ងួត និងគណនារកភាគរយវា តាមរូបមន្ត $\%C = \frac{m_{អំបិល} \times 100}{m_{សូលុយស្យុង}}$

តើដូចម្តេចដែលហៅថាសូលុយស្យុង?

ជំហានទី៤ ពព្រឹងពុទ្ធិ(៥នាទី)

- និយមន័យសូលុយស្យុង
- ការទាញយកអំបិលស្អាតពី អំបិលកង្វក់

- សូលុយស្យុងគឺជាល្បាយស្មើសាច់ដែលកើតឡើងដោយធាតុរលាយ និងធាតុរំលាយ ជាទឹក

| | | |
|---|---|---|
| តើត្រូវធ្វើដូចម្ដេចដើម្បីទាញយកអំបិល ស្អាតពីអំបិលកង្វក់បាន ? | | អំបិលឱ្យរលាយ ក្នុងទឹក ច្រោះយកដី និងសារធាតុកង្វក់ចេញ រួចយកទឹកអំបិលថ្លាទៅរំហួត.....។ |
| ១. តើគេអាចកំណត់បរិមាណស្ករសពីសូលុយស្យុងបានដូចតាមវិធីសូលុយស្យុងអំបិលដែលបានដែររឺទេ?<br>២. គណនាម៉ាសស្ករសដែលមានក្នុងសូលុយស្យុង 150g កំហាប់ 20%។ | ជំហានទី៥ កិច្ចការផ្ទះ (៣នាទី)<br>- វិធីកំណត់បរិមាណស្ករស។<br>- គណនាម៉ាសស្ករសពីសូលុយស្យុងវា។ | សិស្សធ្វើការកត់ត្រាចូលសៀវភៅ។ |

# សន្លឹកកិច្ចការ

១. សង្កេត (៣នាទី) បង្ហាញថង់អំបិលសម្លរួចសួរ

- តើនេះជាអ្វី? វាមានរូបមន្តដូចម្តេច? បានពីណា?

---

- បើយើងយកអំបិលសម្ល ទៅដាក់ក្នុងកែវទឹក តើយើងទទួលបានអ្វី? តើទឹក នឹងអំបិលមាននាទីជាអ្វី?

២. សំណួរគន្លឹះ

៣. សម្មតិកម្មៈ ចូរធ្វើការទស្សន៍ទាយ (៥នាទី)

- តាមវិធីៈ ........................................................................................
- គណនាតាមៈ ...............................................................................

៤. រៀបចំប្លង់ពិសោធន៍ (២៥នាទី)

លទ្ធផលៈ ចូរស្រង់លទ្ធផលពិសោធន៍ ដាក់ចូលក្នុងតារា

| ម៉ាសគិតជាក្រាម (m(G)) | | |
|---|---|---|
| ចាន(A) | ចាន និងសូ.ទឹក(B) | ចាន និងអំបិលស្ងួត(D) |
| | | |

សំណួរពិភាក្សា

១. គេថាទឹកអំបិលសម្ល ជាសូលុយស្យុង។ ហេតុអ្វី

---

២. ចូរកំណត់កំហាប់ភាគរយនៃអំបិល

---

៥. សន្និដ្ឋាន (៥នាទី) តើសូលុយស្យុងជាអ្វី? តើគេកំណត់ភាគរយបានដូចម្តេច?

## ១.៣. ជីវវិទ្យា

### ១.៣.១ ពិនិត្យមើលដូងជ្រូក

### ១.៣.២ ការវាស់ថាមពលក្នុងអាហារ

### ១.៣.៣ បណ្ដូរទឹកក្នុងកោសិកា

# កិច្ចតែងការបង្រៀន

**១. មុខវិជ្ជា៖** ជីវវិទ្យា, ថ្នាក់ទី៨ (កម្មវិធីថ្មី)

**២. ប្រធានបទ៖** ពិនិត្យបេះដូងជ្រូក

៣. វត្ថុបំណង៖

- ចំណេះដឹង
  - កំណត់បានពីថតទាំងបួនរបស់បេះដូងបានត្រឹមត្រូវតាមរយៈការពិនិត្យទម្រង់ ក្នុងបេះដូងជ្រូក។
  - បញ្ជាក់ពីមុខងាររបស់ប្រឹស និងសរសៃឈាមបេះដូងបានត្រឹមត្រូវតាមរយៈការពនិត្យទម្រង់ក្នុង និងទម្រង់ក្រៅរបស់បេះដូងជ្រូក។
- បំណិន
  - វះកាត់ និងពនិត្យបេះដូងបានត្រឹមត្រូវតាមរយៈការណែនាំរបស់គ្រូ។
- ឥរិយាបថ
  - ថែរក្សាប្រដាប់របត់ឈាមបានត្រឹមត្រូវដោយយល់ពីមុខងាររបស់សរសៃឈាម និងបេះដូង។

**៤. រយៈពេល៖** ៥០នាទី

**៥.សម្ភារៈឧបទ្ទេស៖**

- បេះដូងជ្រូក ជ្រុញ កាំបិត ចង្កឹះ ស្រោមដៃ ទឹក។

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| .ស្វាគមន៍សិស្ស<br>.ពិនិត្យមើលក្នុងថ្នាក់ | ជំហានទី១ លំនឹងថ្នាក់ (២–៣នាទី)<br>.ស្វាគមន៍ និងរដ្ឋបាលថ្នាក់ | .ស្វាគមន៍គ្រូ<br>.ស្តាប់គ្រូ |
| .តើដំណឹកនាំនៅក្នុងរុក្ខជាតិ និងសត្វថ្នាក់ទាបប្រព្រឹត្តទៅយ៉ាងដូចម្តេច? | ជំហានទី២ រំលឹកមេរៀនចាស់<br>(៣–៥នាទី)<br>.ដំណឹកនាំចំពោះរុក្ខជាតិ និងសត្វថ្នាក់ទាប | .ប្រព្រឹត្តទៅដោយបន្សាយឆ្លងកាត់ភ្នាសកោសិកា។ |

| | | |
|---|---|---|
| . តើចំពោះមនុស្សដំណឹកនាំ ប្រព្រឹត្តទៅតាមរយៈអ្វី?<br>. តើឈាមត្រូវបានបញ្ជូនទៅ ផ្នែកផ្សេងៗរបស់សារពាង្គកាយយ៉ាងដូចម្ដេច? | .ដំណឹកនាំក្នុងមនុស្ស | . តាមរយៈឈាម<br>. ដោយសារបេះដូងច្របាច់ ហើយបញ្ជូនឈាមទៅផ្នែកទាំងនោះ។ |
| . តើអ្នកស្គាល់ និងធ្លាប់ឃើញបេះដូងឬទេ?<br>. ឲ្យសិស្សគូររូបបេះដូងតាម ដែលគេធ្លាប់មើលឃើញ<br>. ឲ្យសិស្សពន្យល់ពីបេះដូង ហើយសួរសិស្សថាតើវាជាបេះដូងអ្វី? | ជំហានទី៣ មេរៀនប្រចាំថ្ងៃ<br>(៣០–៣៥នាទី)<br>**២. ប្រព័ន្ធដំណឹកនាំក្នុង ខ្លួនមនុស្ស**<br>**ការពិនិត្យបេះដូងជ្រូក**<br>**លំនាំបញ្ហា និងសំណួរគន្លឹះ**<br><br>បេះដូងមនុស្សក៏មានលក្ខណៈដូចគ្នានឹងបេះដូងជ្រូកដែរ។ | . ធ្លាប់ និងស្គាល់<br>. សិស្សគូររូបបេះដូង<br>. បេះដូងមនុស្ស |
| *សូមបញ្ជាក់ពីការគិតរបស់អ្នកដោយធ្វើការពិនិត្យពីទម្រង់ខាងក្រៅ និងទម្រង់ខាងក្នុងបេះដូងជ្រូកដោយផ្ទាល់*!! | | |
| . បិតរូបភាពហើយពន្យល់ពី ផ្នែកខាងឆ្វេង និងផ្នែកខាងស្ដាំបេះដូង។<br>. ពន្យល់ពីដំណើរការវះកាត់ និងដំណើរការសង្កេត។ | **ដំណើរការពិសោធ**<br>*ដំណើរការពិសោធដូចមាន រៀបរាប់នៅក្នុងសន្លឹកកិច្ចការ* | . គិត និងស្ដាប់គ្រូពន្យល់<br>. សិស្សធ្វើការវះកាត់ ហើយពិនិត្យដោយផ្ទាល់។ |

(សិស្សធ្វើការជាដៃគូ)

. បិតរូបភាព ហើយបង្ហាញពីសរសៃឈាមចូលថតបេះដូងទាំង៤។







***សម្គាល់៖*** ១. ថតលើស្តាំ, ២. ថតក្រោមស្តាំ, ៣. ថតលើឆ្វេង, ៤. ថតក្រោមឆ្វេង

<u>លទ្ធផលសង្កេត</u>




*ទម្រង់ខាងក្រៅរបស់បេះដូង*




*ទម្រង់ខាងក្នុងរបស់បេះដូង*

. សិស្សម្នាក់បកស្រាយ ហើយសិស្សដទៃទៀត ស្តាំ ហើយបន្ថែមនូវចំនុចដែលខ្វះខាត។

. ឲ្យសិស្សម្នាក់ឡើងបកស្រាយលទ្ធផលដែលបានពិនិត្យឃើញ។

. សិស្សពិភាក្សាជាដៃគូ ហើយឆ្លើយទៅនឹងសំណួរ ដោយផ្អែកលើការសង្កេតបេះដូងដែលគេបានសង្កេត។

ការវិភាគ និងសន្និដ្ឋាន

.ឲ្យសិស្សឆ្លើយទៅនឹងសំណួរទី១ដល់ទី៤ដោយពិភាក្សាជាដៃគូ

១. តើអ្នកពិនិត្យឃើញអ្វីខ្លះ នៅផ្នែកខាងក្រៅរបស់បេះដូង?

១. នៅផ្នែកខាងក្រៅបេះដូង យើងអាចពិនិត្យឃើញមាន អាកទែអារអក អាកទែសួត វ៉ែនការ វ៉ែនសួត សរសៃ ក្ស៉ូណែ។

១. សាច់ដុំបេះដូង សរសៃឈាម...

| | | |
|---|---|---|
| ២. តើអ្នកពិនិត្យឃើញអ្វីខ្លះ នៅផ្នែកខាងក្នុងរបស់បេះដូង?<br><br>៣. តើថតណារបស់បេះដូងដែលមានកម្រាស់សាច់ដុំក្រាស់បំផុត? ហេតុអ្វី?<br><br>៤. តើអ្នកបានពិនិត្យឃើញ ប្រឹសអ្វីខ្លះ នៅក្នុងបេះដូង? តើវាមាននាទីអ្វី? | ២. នៅផ្នែកខាងក្នុងបេះដូង មានថតលើស្ដាំ ថតក្រោមស្ដាំ ថតលើឆ្វេង ថតក្រោមឆ្វេង ប្រឹសបេះដូង ប្រឹសអាកទែ។<br><br>៣. ថតបេះដូងដែលមាន សាច់ ដុំក្រាស់បំផុតគឺសាច់ ដុំថតក្រោមឆ្វេង។ ពីព្រោះ ថតក្រោមឆ្វេងបញ្ជូនឈាម ទៅគ្រប់ផ្នែកទាំងអស់របស់សារពាង្គកាយ។<br><br>៤. ប្រឹសបេះដូងមានបួនគឺ: ប្រឹសដែលខ័ណ្ឌថតលើនិង ថតក្រោម ហើយនិង ប្រឹស អាកទែទាំងពីរ។ ប្រឹសបេះដូង មាននាទីការពារមិនឲ្យឈាមហូរត្រលប់មកវិញ។ | ២. ថតលើ ថតក្រោម ប្រឹសបេះដូង សរសៃឈាម...<br><br>៣. ថតដែលមានសាច់ដុំក្រាស់ជាងគេគឺថតក្រោម ឆ្វេង។ ពីព្រោះវាមាននាទីបញ្ជូនឈាមទៅកាន់សារពាង្គកាយ។<br><br>៤. ប្រឹសបេះដូងមានពីរគឺ ប្រឹសខ័ណ្ឌថតលើ និងថតក្រោមឆ្វេង និងប្រឹសដែល ខ័ណ្ឌថតលើ និងថតក្រោមស្ដាំ។ |
| . ឲ្យសិស្សបំពេញប្រឡោះ នៅក្នុងសំណួរទី៥ នៅក្នុងសន្លឹកកិច្ចការ។ | ជំហានទី៤ ពង្រឹងពុទ្ធិ (៤–៥នាទី)<br><br> | . បំពេញប្រឡោះដោយ ពិភាក្សាជាដៃគូ ។<br><br>. សិស្សម្នាក់ឡើងបំពេញលើក្ដារខៀននិង បកស្រាយ។ |

| | | |
|---|---|---|
| . យើងបានដឹងហើយថាបេះដូង និងសរសៃឈាមមានសារៈសំខាន់ណាស់ក្នុងការដឹកនាំអុកស៊ីសែន និងអាហារចិញ្ចឹមផ្សេងៗទៀតទៅ ចិញ្ចឹមសារពាង្គកាយទាំងមូល។ ដូចនេះយើងត្រូវថែរក្សាប្រដាប់របត់ឈាមយើង ដោយមិនបរិភោគអាហារ ដែលប៉ះពាល់បេះដូង និងសរសៃឈាម។ | ជំហានទី៥ បណ្តាំផ្ញើ និងកិច្ចការផ្ទះ (២–៣នាទី)<br>សារៈប្រយោជន៍ និងវិធីការពារប្រដាប់របត់ឈាម។ | . ស្តាប់ដោយយកចិត្តទុកដាក់។ |
| . ថ្ងៃនេះយើងបានវះកាត់បេះដូងជ្រូក។ នៅពេលត្រលប់ទៅផ្ទះវិញសូមធ្វើការវះកាត់បេះដូងមាន់។ | . បេះដូងមាន់មានបួនថត ដូចបេះដូងជ្រូក និងមនុស្ស ដែរ។ | . វះកាត់បេះដូងមាន់ ហើយកត់ត្រាចម្លើយឲ្យគ្រូ។ |

## ប្រធានបទ៖ **ការពិនិត្យបេះដូងជ្រូក**

**I. លំនាំបញ្ហា និងសំណួរគន្លឹះ**

(សូមគូរទម្រង់ខាងក្រៅ និងទម្រង់ខាងក្នុងរបស់បេះដូងព្រមទាំងដាក់ឈ្មោះផ្នែកផ្សេងៗ)

*សូមបញ្ជាក់ពីការគិតរបស់អ្នកដោយធ្វើការពិនិត្យពីទម្រង់ខាងក្រៅ និងទម្រង់ខាងក្នុងបេះដូងជ្រូកដោយផ្ទាល់!!*

**II. ដំណើរការពិសោធ**

**ក. ការពិនិត្យមើលពីទម្រង់ខាងក្រៅរបស់បេះដូងជ្រូក**

– យកបេះដូងជ្រូកទាំងមូល (នៅទាំងសរសៃឈាម) ទៅលាងទឹកឲ្យស្អាត។

– ពិនិត្យមើលផ្នែកខាងមុខ និងផ្នែកខាងក្រោយរបស់បេះដូងដើម្បីពិនិត្យមើលពីទម្រង់ទូទៅរបស់បេះដូង។

– ពិនិត្យមើលផ្នែកខាងមុខរបស់បេះដូង ហើយរកមើលសរសៃឈាមក្ឫរ៉ូណែ។ បន្ទាប់មកកំណត់ពីថតក្រោមឆ្វេង ថតក្រោមស្តាំ ថតលើឆ្វេង និងថតលើស្តាំរបស់បេះដូង។

**ខ. ការពិនិត្យមើលពីទម្រង់ខាងក្នុងរបស់បេះដូង**

– ពុះបេះដូងតាមបណ្តោយ (ដោយខិតមកផ្នែកខាងមុខបន្តិច) ពីផ្នែកខាងលើរហូត ដល់ចុងបេះដូង។

– រកមើលសរសៃឈាមដែលចូលថតលើស្តាំ (វ៉ែនការ) និងសរសៃឈាមដែលចូលថតលើឆ្វេង (វ៉ែនសួត)។

– ពិនិត្យមើលសរសៃឈាមដែលចេញពីថតក្រោមស្តាំ (អាកទែសួត) និងសរសៃឈាមដែលចេញពីថតក្រោមឆ្វេង (អាទែអាអក)។ (មើលរូបភាព)

– ពិនិត្យមើលពីកំរាស់សាច់ដុំរបស់ថតនីមួយៗរបស់បេះដូង។




*សម្គាល់ក្នុងរូបភាព* ១. ថតលើស្តាំ, ២. ថតក្រោមស្តាំ, ៣. ថតលើឆ្វេង, ៤. ថតក្រោមឆ្វេង។

III. លទ្ធផលសង្កេត

*ទម្រង់ខាងក្រៅរបស់បេះដូង* *ទម្រង់ខាងក្នុងរបស់បេះដូង*

IV. ការវិភាគ និងសន្និដ្ឋាន

១. តើអ្នកពិនិត្យឃើញអ្វីខ្លះនៅផ្នែកខាងក្រៅរបស់បេះដូង?

……………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

២. តើអ្នកពិនិត្យឃើញអ្វីខ្លះនៅផ្នែកខាងក្នុងរបស់បេះដូង?

……………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

៣. តើថតណារបស់បេះដូង ដែលមានកម្រាស់សាច់ដុំក្រាស់បំផុត? ហេតុអ្វី?

……………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

៤. តើអ្នកបានពិនិត្យឃើញប្រឹសបេះដូងអ្វីខ្លះ? តើវាមាននាទីអ្វី?

……………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

៥. សំណួរពង្រឹងពុទ្ធិ៖ ចូរបំពេញប្រឡោះអំពីលំហូរឈាមឲ្យបានត្រឹមត្រូវ។



# ប្លង់ក្តារខៀន

ប្រធានបទ ការពិនិត្យបេះដូងជ្រូក

I. លំនាំបញ្ហា និងសំណួរគន្លឹះ

រូបបេះដូង

រូបបេះដូង

*សូមបញ្ជាក់ពីការគិតរបស់អ្នកដោយធ្វើការពិនិត្យពីទម្រង់ខាងក្រៅ និងទម្រង់ខាងក្នុងបេះដូងជ្រូកដោយផ្ទាល់!!*

II. ដំណើរការពិសោធ







*សម្គាល់* ១. ថតលើស្តាំ, ២.ថតក្រោមស្តាំ
៣. ថតលើឆ្វេង, ៤. ថតក្រោមឆ្វេង

III. លទ្ធផលសង្កេត



ទម្រង់ខាងក្រៅរបស់បេះដូង



ទម្រង់ខាងក្នុងរបស់បេះដូង

IV. ការវិភាគ និងសន្និដ្ឋាន



# កិច្ចតែងការបង្រៀន

១. **មុខវិជ្ជា៖** ជីវវិទ្យា, ថ្នាក់ទី៨ (កម្មវិធីថ្មី)

២. **ប្រធានបទ៖** ការវាស់ថាមពលក្នុងអាហារ

៣. វត្ថុបំណង៖

- រៀបរាប់ពីសារធាតុចិញ្ចឹមទាំង៦នៅក្នុងអាហារ និងពន្យល់ពីគុណភាពនៃអាហារបានច្បាស់លាស់ តាមរយៈសំនួរបំផុស។
- ពន្យល់ពីរបៀបវាស់ថាមពល និងការផ្តល់បរិមាណថាមពលរបស់អាហារបានច្បាស់លាស់ តាមរយៈ ពិសោធន៍។
- ប្រើប្រាសសម្ភារៈពិសោធន៍បានសមស្របតាមខ្លឹមសារមេរៀន។
- ជ្រើសរើសអាហារដើម្បីសុខភាពបានត្រឹមត្រូវតាមប្រភេទអាហារ។

៤. **រយៈពេល៖** ៥៥នាទី

៥.**សម្ភារៈឧបទ្ទេស៖**

- សំបកកំប៉ុង ទែរម៉ូម៉ែត្រ ដែកលួស ស៊ីរាំង ទឹកធម្មតា ឈើគូស ទៀន ក្រដាសជូតមាត់ គ្រាប់សណ្តែកដីឬគ្រាប់ស្វាយ ចាន់ទី និងប្រេងឆាឬខ្លាញ់ជ្រូករាវ។

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| – ពង្រឹងវិន័យ និងត្រួតពិនិត្យសណ្តាប់ធ្នាប់។ | ជំហានទី១ (រដ្ឋបាលថ្នាក់) | – សិស្សរាយការណ៍ |
| – តើសារធាតុចិញ្ចឹមសំខាន់ៗ ដែលយើងត្រូវការមានអ្វីខ្លះ? <br> – តើសារធាតុចិញ្ចឹមទាំងនេះ គេចែកចេញជាអាហារប្រភេទអ្វីខ្លះ? | ជំហានទី២ (រំលឹកមេរៀនចាស់) | – មាន គ្លុយស៊ីត លីពីត ប្រូតេអ៊ីន វីតាមីន អំបិលខនិជ និងទឹក។ <br> – ចែកចេញជាប្រភេទអាហារថាមពលអាហារស្ថាបនា (សាងសង់) និងអាហារការពារ។ |

| | | |
|---|---|---|
| ថ្ងៃនេះយើងសិក្សាមេរៀនថ្មីអំពី<br><br>- តើប្អូនធ្លាប់ញ៉ាំមី ឬនំកញ្ចប់ទេ?<br><br>-តើប្អូនធ្លាប់បានពិនិត្យមើលលើកញ្ចប់របស់វា គេមានសរសេរអ្វីខ្លះដែលមានសារៈសំខាន់សម្រាប់សុខភាពរបស់យើង?<br><br>(បើសិស្សខ្លះអត់ ខ្លះធ្លាប់យើងចែកកញ្ចប់នំដែលយើងរៀបចំរួចឲ្យសិស្សសង្កេតមើល ហើយសួរគេម្តងទៀត គេមានសរសេរអ្វីខ្លះដែលមានសារៈសំខាន់សម្រាប់សុខភាពរបស់យើង?) | ជំហានទី៣ មេរៀនថ្មី<br><br>**របបអាហារ និងថាមពល**<br><br>**១. តុល្យភាពនៃអាហារ**<br><br>ប្រភេទអាហារ និងបរិមាណអាហារដែលយើងបរិភោគមានសារៈសំខាន់ណាស់។ អាហារដែលមានផ្ទុកបរិមាណគ្លុយស៊ីតលីពីត ប្រូតេអ៊ីន វីតាមីន អំបិលខនិជ និងទឹកត្រឹមត្រូវ ជាអាហារមានតុល្យភាព។<br><br>**២. សំនួរគន្លឹះ** | - ធ្លាប់<br><br>- ខ្លះអត់ ខ្លះធ្លាប់<br><br>- បរិមាណថាមពល |
| តើគេអាចវាស់ថាមពលដែលបានមកពីអាហារយ៉ាងដូចម្តេច? តើអាហារខុសគ្នាមានបរិមាណស្មើគ្នាផ្តល់បរិមាណថាមពលដូចគ្នាដែរឬទេ? | | |
| ឲ្យសិស្សបង្កើតសម្មតិកម្ម និងពន្យល់ហេតុផល។<br><br>-តើសណ្តែកដី១ក្រាមបង្កើនសីតុណ្ហភាពបានប៉ុន្មានអង្សាសេ?<br><br>និងប្រេងឆា១ ក្រាមបង្កើនសីតុណ្ហភាពបានប៉ុន្មានអង្សាសេ?<br><br>រៀបរាប់សម្ភារៈនិងដំណើរការពិសោធ។<br><br>ពន្យល់ពីរបៀបគណនាថាមពល | - គ្រាប់សណ្តែកដី១ក្រាមបង្កើនសីតុណ្ហភាពបាន២១ អង្សាសេ។<br><br>- ប្រេងឆា១ក្រាមបង្កើនសីតុណ្ហភាពបាន២៩ អង្សាសេ ។<br><br>**៣ ធ្វើពិសោធន៍**<br><br>- សម្ភារៈ<br><br>- ដំណើរការពិសោធន៍<br><br>ពន្យល់ពីរបៀបគណនាថាមពល<br><br>$Q = DH_2O .V .T$ | សិស្សបង្កើតសម្មតិកម្ម និងពន្យល់ហេតុផល។<br><br>សិស្សអានសន្លឹកកិច្ចការ និងធ្វើពិសោធន៍។ |

$= DH_2O \cdot V[ml] \cdot \triangle T$

$= DH_2O \cdot V[ml] \cdot (t_1 - t_o)$

$= 1 \cdot V[ml] \cdot (t_1 - t_o)$

$DH_2O$ = ដង់ស៊ីតេទឹកស្មើ១

V = មាឌទឹកគិតជា ml

T = សីតុណ្ហភាពគិតជា $^oC$

Q=បរិមាណថាមពលគិតជាកាល់ឡូរី (cal)

* លំនាំការគណនាពី កាល់ឡូរី (cal) ទៅជាគីឡូស៊្សូល (kJ) ÷

១ cal = 0.0៤២ kJ

១ kJ = ១000 J(ស៊្សូល)

១ cal = ៤.២ J

**៤ លទ្ធផល**

ចូរបំពេញលទ្ធផលក្នុងតារាង

តារាងលទ្ធផល

| ប្រភេទអាហារ | មាឌទឹក V(ml) | $T_0$ ($^0C$) | $T_1$ ($^0C$) | $T_1 - T_0$ ($^0C$) | Q (cal) |
|---|---|---|---|---|---|
| គ្រាប់សណ្ដែកដី | ១០០ | ២៧ | ៤៨ | ២១ | ២១០០ |
| ប្រេងឆា | ១០០ | ២៧ | ៥៦ | ២៩ | ២៩០០ |

តាមរយៈការពិសោធ និងលទ្ធផលខាងលើ ចូរទាញសេចក្ដីសន្និដ្ឋាន

១. តើគេអាចវាស់ថាមពលដែលបានមកពីអាហារយ៉ាងដូចម្ដេច?

២. ចូរទាញសេចក្ដីសន្និដ្ឋានអំពីការផ្ដល់ថាមពលរបស់អាហារ។

**៥ សន្និដ្ឋាន**

**តាមរយៈលទ្ធផលខាងលើ យើងសង្កេតឃើញថា៖**

បង្ហាញតារាងតម្រូវការថាមពលគិតជាមធ្យម

**– គេអាចវាស់ថាមពលអាហារបានតាម ការធ្វើ ចំហេះសព្វអាហារ។ កាលណា អាហារ**

<table>
<tr>
<td>
<table>
<tr><th>អាហារ</th><th>%</th><th>កាឡូរី</th><th>ក្រាម</th></tr>
<tr><td>គ្លុយស៊ីត</td><td>៥៥</td><td></td><td></td></tr>
<tr><td>ប្រូតេអ៊ីន</td><td>១៥</td><td></td><td></td></tr>
<tr><td>លីពីត<br>(ខ្លាញ់)</td><td>៣០</td><td></td><td></td></tr>
<tr><td>បរិមាណ<br>សរុប</td><td>១០០</td><td>២៥០០</td><td>៥២១</td></tr>
</table>
</td>
<td>ឆេះសព្វ បង្កើនសីតុណ្ហភាពទឹក១ក្រាម (១០០មីលីលីត្រ) កើនបាន១អង្សាសេ មានន័យថាអាហារនោះផ្តល់ថាមពលបាន ១កាឡូរី។ ថាមពលគីមីក្នុងអាហារបាន បំលែងទៅជាថាមពលកម្តៅ។<br><br>-គ្រាប់សណ្តែកដីផ្តល់បរិមាណថាមពលទាប ហើយប្រេងឆាផ្តល់បរិមាណថាមពលខ្ពស់។ ដូចនេះយើងអាចសន្និដ្ឋានថា អាហារខុសគ្នាក្នុងបរិមាណដូចគ្នាផ្តល់បរិមាណថាមពលខុសគ្នា។ លីពីតផ្តល់បរិមាណថាមពលខ្ពស់ជាងគ្លុយស៊ីត។</td>
<td></td>
</tr>
<tr>
<td>១. តាមរយៈតារាងនេះតើអ្នកត្រូវបរិភោគអាហារយ៉ាងដូចម្តេច ដើម្បីឲ្យអ្នកមានសុខភាពល្អ និងមិនឡើងទម្ងន់?<br><br>២. បាយសម្លមួយចាននិងបាយឆាមួយចានដូចគ្នាតើមួយណាផ្តល់ថាមពលខ្ពស់ជាង?ហេតុអ្វី?</td>
<td>ជំហានទី៤ ពង្រឹងពុទ្ធិ</td>
<td>យើងត្រូវបរិភោគអាហារដែលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ក្នុងបរិមាណត្រឹមត្រូវ។<br><br>បាយឆាមួយចានផ្តល់ថាមពលខ្ពស់ជាង ពីព្រោះបាយឆាមានខ្លាញ់។</td>
</tr>
<tr>
<td>ចូរវាស់ថាមពលអាហារផ្សេងទៀតក្រៅពីនេះដែលប្អូនអាចធ្វើបាន។</td>
<td>ជំហានទី៥<br><br>បណ្តាំផ្ញើ<br><br>កិច្ចការផ្ទះ</td>
<td></td>
</tr>
</table>

# សន្លឹកកិច្ចការ

១ សំនួរគន្លឹះ

| |
|---|
| តើគេអាចវាស់ថាមពលដែលបានមកពីអាហារយ៉ាងដូចម្តេច? តើអាហារខុសគ្នាមាន បរិមាណស្មើគ្នាផ្តល់បរិមាណថាមពលដូចគ្នាដែរឬទេ? |

២ សម្មតិកម្ម

តើសណ្តែកដី១ក្រាមបង្កើនសីតុណ្ហភាពបានប៉ុន្មានអង្សាសេ?

និងប្រេងឆា១ ក្រាមបង្កើនសីតុណ្ហភាពបានប៉ុន្មានអង្សាសេ?

– គ្រាប់សណ្តែកដី ១ក្រាម …………………………………………..

– ប្រេងឆា ១ក្រាម ………………………….……………………….

៣ ពិសោធន៍

+ សម្ភារៈ

–សំបកកំប៉ុង ទែរម៉ូម៉ែត្រ ដែកលួស ស៊ីរាង ទឹកធម្មតា ឈើគូស ទៀន ក្រដាសជូតមាត់ គ្រាប់សណ្តែកដី ឬគ្រាប់ស្វាយចាន់ទី និងប្រេងឆាឬខ្លាញ់ជ្រូករាវ។

+ ដំណើរការពិសោធ

–កាត់កំប៉ុងជាពីរកំណាត់ មួយកំណាត់សម្រាប់ដាក់ដាំទឹក និងមួយកំណាត់ទៀតចោះប្រហោងដើម្បីធ្វើជាចង្ក្រាន។

– វាល់ទឹក១០០មីលីលីត្រដាក់ចូលកំណាត់កំប៉ុងដែលកាត់រួច ហើយដាក់ទែរម៉ូម៉ែត្រទៅក្នុងទឹក នោះដើម្បីវាស់សីតុណ្ហភាពដើមរបស់ទឹកមុនពេលដាំ រួចកត់ដាក់ ក្នុងតារាង លទ្ធផល។

–កាត់ដែកលួសប្រវែង២០សង់ទីម៉ែត្រ រួចដោតគ្រាប់សណ្តែកដីថ្មមៗកុំឲ្យបែក ហើយលៃយ៉ាងណាឲ្យគ្រាប់សណ្តែកដីជាប់នឹងដែកលួសបានល្អ។

–ដុតគ្រាប់សណ្តែកដីនឹងភ្លើងទៀនឲ្យឆេះល្អទើបដាក់ចូលទៅក្នុងកំប៉ុងចង្ក្រាន។




– ប្រើភ្លើងគ្រាប់សណ្តែកដីនេះដាំទឹករហូតដល់គ្រាប់សណ្តែកដីឆេះអស់។ បន្ទាប់ពីគ្រាប់សណ្តែកដីឆេះអស់សូមពិនិត្យមើលទែរម៉ូម៉ែត្រម្តងទៀត ដើម្បីមើលសីតុណ្ហភាពទឹកឡើងបានប៉ុន្មានអង្សាសេរួចកត់ចូលក្នុងតារាងលទ្ធផល (ទែរម៉ូម៉ែត្រត្រូវដាក់នៅក្នុងកំប៉ុងទឹកដាំនោះរហូតនៅពេលកំពុងដាំត្រូវយកទែរម៉ូម៉ែត្រនោះកូរទឹកថ្មមៗ ដោយមិនឲ្យប៉ះនឹងបាតកំប៉ុងទេ)។

– ចំពោះប្រេងឆា វាល់ប្រេងចំនុះ១មីលីលីត្រដាក់ទៅក្នុងបាតកំប៉ុងរួចដាក់ក្រដាសជូតមាត់បន្តិចដើម្បីដុតប្រេងឲ្យឆេះ រួចដាក់ដាំទឹក ១០០មីលីលីត្រធ្វើដូចគ្នានឹងដំណើរការដុតសណ្តែកដីដែរ។

ក្រោយពីទទួលបានលទ្ធផលសូមគណនាថាមពលចំហេះសព្វរបស់គ្រាប់សណ្តែកដី និងប្រេងឆាតាមរូបមន្តខាងក្រោម៖

$$Q = D_{H_2O} .V .T$$
$$= D_{H_2O} .V[ml] .\triangle T$$
$$= D_{H_2O} .V[ml] .(t_1 - t_o)$$
$$= 1. V[ml] .(t_1 - t_o)$$

- $D_{H_2O}$ = ដង់ស៊ីតេទឹកស្មើ១
- V = មាឌទឹកគិតជា ml
- T = សីតុណ្ហភាពគិតជា °C
- Q= បរិមាណថាមពលគិតជាកាល់ឡូរី (Cal)

* លំនាំការគណនាពី កាល់ឡូរី (Cal) ទៅជាគីឡូស៊ូល (KJ) ÷

១ KJ = ១000 J(ស៊្ញូល)

១ Cal = ៤,២ J

១ Cal = 0.00៤២ KJ

៤ លទ្ធផល

ចូរបំពេញលទ្ធផលក្នុងតារាងខាងក្រោម

| ប្រភេទអាហារ | មាឌទឹកV(ml) | $T_0$ | $T_1$ | $T_1 - T_0$ | Q |
|---|---|---|---|---|---|
| គ្រាប់សណ្តែកដី | | | | | |
| ប្រេងឆា | | | | | |

៥ សន្និដ្ឋាន

តាមរយ:លទ្ធផលខាងលើ

១ តើគេអាចវាស់ថាមពលដែលបានមកពីអាហារយ៉ាងដូចម្តេច?

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

២ ចូរទាញសេចក្តីសន្និដ្ឋានអំពីការផ្តល់ថាមពលរបស់អាហារ

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

# ប្លង់ក្តារខៀន

១ សំនួរគន្លឹះ

| |
|---|
| តើគេអាចវាស់ថាមពលដែលបានមកពីអាហារយ៉ាងដូចម្តេច?<br>តើអាហារខុសគ្នាមានបរិមាណស្មើគ្នាផ្តល់បរិមាណថាមពលដូចគ្នាដែរឬទេ? |

២ សម្មតិកម្ម

តើសណ្តែកដី១ក្រាមបង្កើនសីតុណ្ហភាពបានប៉ុន្មានអង្សាសេ?

និងប្រេងឆា១ ក្រាមបង្កើនសីតុណ្ហភាពបានប៉ុន្មានអង្សាសេ?

- គ្រាប់សណ្តែកដី ១ក្រាម បង្កើនសីតុណ្ហភាពបាន ២១ អង្សាសេ។
- ប្រេងឆា ១ក្រាម បង្កើនសីតុណ្ហភាពបាន ២៩ អង្សាសេ។

៣ ពិសោធន៍

÷ សម្ភារ: សំបកកំប៉ុង ទែរម៉ូម៉ែត្រ ដែកលួស ស៊ីរាង ទឹកធម្មតា ឈើគូស ទៀន ក្រដាសជូតមាត់ គ្រាប់សណ្តែកដី ឬគ្រាប់ស្វាយចាន់ទី និងប្រេងឆាឬខ្លាញ់ជ្រូករាវ។

÷ ដំណើរការពិសោធ

- រៀបរាប់ពីដំណើរការពិសោធន៍ (ដោយឲ្យសិស្សអានសន្លឹកកិច្ចការ)
- ក្រោយពីទទួលបានលទ្ធផលសូមគណនាថាមពលចំហេះសព្វរបស់គ្រាប់សណ្តែកដី និងប្រេងឆាតាមរូបមន្តខាងក្រោម

$$Q = D_{H_2O}.V.T$$
$$= D_{H_2O}.V_{[ml]}.\triangle T$$
$$= D_{H_2O}.V_{[ml]}.(t_1 - t_o)$$
$$= 1.V_{[ml]}.(t_1 - t_o)$$

- $D_{H_2O}$ = ដង់ស៊ីតេទឹកស្មើ១
- V = មាឌទឹកគិតជា ml
- T = សីតុណ្ហភាពគិតជា °C
- Q= បរិមាណថាមពលគិតជា កាល់ឡូរី (cal)

* លំនាំការគណនាពីកាល់ឡូរី (cal) ទៅជាគីឡូស៊ូល (KJ) ÷

១ KJ = ១000 J(ស៊ូល) ១ cal = ៤.២ J ១ cal = 0.0៤២ KJ

៤ លទ្ធផល ចូរបំពេញលទ្ធផលក្នុងតារាងខាងក្រោម

| ប្រភេទអាហារ | មាឌទឹកV(ml) | $T_0$ | $T_1$ | $T_1 - T_0$ | Q(cal) |
|---|---|---|---|---|---|
| គ្រាប់សណ្តែកដី | ១០០(ml) | ២៧ | ៤៨ | ២១ | ២១០០ |
| ប្រេងឆា | ១០០(ml) | ២៧ | ៥៦ | ២៩ | ២៩០០ |

៥ សន្និដ្ឋាន

តាមរយ:លទ្ធផលខាងលើ យើងសង្កេតឃើញថា គេអាចវាស់ថាមពលអាហារបានតាមការធ្វើចំហេះសព្វអាហារ។ កាលណា ចំហេះសព្វអាហារ បង្កើនសីតុណ្ហភាពទឹក ១ក្រាម (១០០មីលីលីត្រ) កើនបាន១អង្សាសេ មានន័យថាអាហារនោះផ្តល់ថាមពលបាន១កាឡូរី។ ថាមពលគីមីក្នុងអាហារបានបំលែងទៅជាថាមពលកម្តៅ។

គ្រាប់សណ្តែកដីផ្តល់បរិមាណថាមពលទាប ហើយប្រេងឆាផ្តល់បរិមាណថាមពលខ្ពស់។ ដូចនេះយើងអាចសន្និដ្ឋានថា អាហារខុសគ្នាក្នុងបរិមាណដូចគ្នាផ្តល់បរិមាណថាមពលខុសគ្នា។ លីពីតផ្តល់បរិមាណថាមពលខ្ពស់ជាងគ្លុយស៊ីត។

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ ជីវវិទ្យា, ថ្នាក់ទី៨ (កម្មវិធីថ្មី)

២. ប្រធានបទ៖ បណ្តូរទឹកក្នុងកោសិកា

៣. វត្ថុបំណង៖

- ការសង្កេតពីប្លាស្មូលីស ដេប្លាស្មូលីស នៃកោសិកាខ្ទឹមបារាំងត្រឹមត្រូវតាមរយៈពិសោធ។
- រៀបរាប់ពីលំនាំចលនាទឹកចេញចូលក្នុងកោសិកាបានត្រឹមត្រូវ តាមរយៈពិសោធ។
- រៀបចំដំណើរការពិសោធន៍ដើម្បីពន្យល់ពីបាតុភូត។

៤. រយៈពេល៖ ៥០នាទី

៥.សម្ភារៈឧបទ្ទេស៖

- សន្លឹកកិច្ចការពិសោធន៍
- សម្ភារៈពិសោធន៍មាន៖ សូលុយស្យុងអំបិល ១៥% ខ្ទឹមបារាំង ទឹកស្អាត កែវជ័រ កូនកាំបិត មីក្រូទស្សន៍ បន្ទះឡាម បន្ទះឡាមែ ដង្កៀប ឡាមកោពុកមាត់។

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យសណ្តាប់ ធ្នាប់សិស្ស ពង្រឹងវិន័យ | ជំហានទី១<br>រដ្ឋបាលថ្នាក់ | -សិស្សរាយការណ៍ |
| -ដូចម្តេចហៅថាបន្សាយ?<br><br>-តើផ្លែត្រសក់មានសភាពប្រែប្រួល ដូចម្តេច បើដាក់ក្នុងទឹកអំបិល? | ជំហានទី២<br>**រំលឹកមេរៀនចាស់**<br>-បន្សាយជាចលនាម៉ូលេគុលទឹមពី តំបន់ដែលមានកំហាប់ខ្ពស់ទៅតំបន់ ដែលមានកំហាប់ទាប។ | -បន្សាយជាចលនារបស់ម៉ូលេគុលទឹក ពី តំបន់ដែលមានកំហាប់ខ្ពស់ទៅតំបន់ដែល មានកំហាប់ទាប។ ផ្លែត្រសក់រួមតូច។<br>-ផ្លែត្រសក់រួមតូច។ |

| | | |
|---|---|---|
| -តើការរួមតូចស្វិតរបស់ផ្លែត្រសក់បណ្តាលមកពីអ្វី?<br><br>ថ្ងៃនេះយើងនឹងសិក្សាមេរៀនបន្តគឺ៣.បណ្តូរទឹកក្នុងកោសិកា។ | - ចលនានៃម៉ូលេគុលទឹកពីតំបន់មានបរិមាណទឹកច្រើនទៅតំបន់មានបរិមាណទឹកតិចដោយឆ្លងកាត់ភ្នាសអឌ្ឍជ្រាបហៅថាអូស្មូស។ | - បណ្តាលមកពីទឹកចេញពីកោសិកាត្រសក់។ |
| -អ្នកលក់បន្លែស្ពៃ សាឡាដ... ចូលចិត្តប្រោះទឹកលើបន្លែទាំងនោះ ដើម្បីអ្វីដែរ?<br><br>-តើបណ្តាលមកពីអ្វីបានជាបន្លែនោះស្រស់?<br><br>- ចូរសង្កេតមើល តើកោសិកាទាំងនេះមានសភាពដូចម្តេច?<br><br>- ផ្តល់សន្លឹកកិច្ចការដល់សិស្សដើម្បីកត់ត្រាចម្លើយព្រាងទុក។<br><br>- បង្ហាញរូបទម្រង់កោសិកាធម្មតាដល់សិស្ស។<br><br>ដើម្បីដឹងថាចម្លើយនេះត្រូវឬទេយើងត្រូវធ្វើពិសោធន៍។<br><br>- ចែកសិស្សជាក្រុម<br><br>- ណែនាំសិស្សពីលំនាំនៃការពិសោធ និងឲ្យអានបន្ថែមលើសន្លឹកកិច្ចការ។ | **ជំហានទី៣**<br><br>**បណ្តូរទឹកក្នុងកោសិកា**<br><br>**សំណួរគន្លឹះ:**<br><br>**តើបណ្តូរទឹកក្នុងកោសិការុក្ខជាតិប្រព្រឹត្តទៅយ៉ាងដូចម្តេច?**<br><br>**សម្មតិកម្ម**<br><br><br><br><br><br><br>**ទម្រង់កោសិការុក្ខជាតិ**<br><br>**ពិសោធន៍**<br><br>- កាត់កោសិកាខ្ទឹមបារាំងទំហំ1cm$^2$ ហើយផ្ដិះយកស្រទាប់ភ្នាសស្តើងកោសិកាដាក់លើបន្ទះឡាម ហើយបន្តក់ទឹក បន្ទាប់មកគ្របបន្ទះឡាមែពីលើ និងពិនិត្យមើលក្នុងមីក្រូទស្សន៍ | - ដើម្បីឲ្យបន្លែស្រស់។<br><br>- ប្រហែលមកពីទឹកចូលក្នុងទៅក្នុងស្លឹកបន្លែ។<br><br>- ក្នុងកែវទី1៖ កោសិកាមានសភាពប៉ោង<br><br>- ក្នុងកែវទី2៖ កាមានសភាព ប៉ោងដែរ។<br><br>- ក្នុងកែវទី3៖កោសិកាមានសភាពផតស្វិត។<br><br>- ស្តាប់ការណែនាំរបស់គ្រូ និងធ្វើពិសោធន៍តាមក្រុម។ |

| | | |
|---|---|---|
| - ដើរពិនិត្យមើលសកម្មភាពសិស្សតាមក្រុម។<br><br>- ឲ្យសិស្សគូររូបធំៗ ដាក់លើក្រដាសមួយសន្លឹករូបមួយ។<br><br>- រួចយករូបមកបិតលើក្ដារខៀន<br><br>- ឆ្លងតាមការសន្និដ្ឋានគ្រូបញ្ជាក់បន្ថែមលើគំនិតដែលរកឃើញដោយសិស្ស៖ | - ធ្វើដូចពិសោធន៍លើកមុន បន្ទាប់មកបន្តក់ទឹកអំបិលទុក រយៈពេល 3-5នាទី ពិនិត្យមើលក្នុងមីក្រូទស្សន៍។<br><br>**លទ្ធផល**<br><br>កោសិកាក្នុងទឹក<br><br><br><br>កោសិកាក្នុងទឹកអំបិល<br><br>**វិភាគនិងសន្និដ្ឋាន**<br><br>- កោសិការីកប៉ោង បណ្ដាលមកពីកំហាប់ស្វ.ក្រៅកោសិកាទាបជាងកំហាប់ក្នុងកោសិកា។<br><br>- កោសិការួមតូចបណ្ដាលមកពីកំហាប់ស្វ.ក្រៅកោសិកាខ្ពស់ជាងកំហាប់ក្នុងកោសិកា។<br><br>បញ្ញត្តិ៖<br><br> | - ក្រុមសិស្សពិនិត្យមើលកោសិកាក្នុងមីក្រូទស្សន៍និងគូររូបដាក់ក្នុងកិច្ចការព្រមគូររូបធំៗដាក់លើក្រដាសស។<br><br>-បិតរូបលើក្ដារខៀន<br><br>ក.កោសិកាមានសភាពប៉ោង។<br><br>ខ.កោសិកាមានសភាពជតស្វិត។<br><br>សិស្សធ្វើការសន្និដ្ឋាន<br><br>- កោសិកាក្នុងកែវទឹកមានសភាពប៉ោង ។<br><br>- កោសិកាក្នុងទឹកអំបិល មានសភាពរួមស្វិត។ |

<table>
<tr>
<td></td>
<td>– ពេលទឹកចូលក្នុងកោសិកាធ្វើឲ្យកោសិការីកប៉ោងហៅថា ប្លាស្មូលីស<br><br>– ពេលទឹកចេញពីកោសិកាធ្វើឲ្យកោសិការួមតូចហៅថាដេប្លាស្មូលីស<br><br>– ពេលទឹកចេញចូលក្នុងកោសិកាស្មើគ្នាធ្វើឲ្យកោសិកាមានទំហំធម្មតា ហៅថា ទូសេសង់។</td>
<td></td>
</tr>
<tr>
<td>– ឲ្យសិស្សឡើងមកប៉ះកោសិកាដែលត្រាំក្នុងកែវទាំងបី(ក្នុងសម្មតិកម្ម)រួចឆ្លើយនឹងសំណួរ<br><br>– តើកោសិកាមានលក្ខណៈដូចម្ដេច?<br><br>– ឲ្យសិស្សគូររូបកោសិកា ព្រមទាំងបញ្ជាក់ពីបណ្ដូរទឹកក្នុងកោសិកា។</td>
<td>ជំហានទី៤<br><table>
<tr><td>ទឹក</td><td>0%</td><td>15%</td></tr>
<tr><td>លក្ខណៈ: របស់កោសិកា</td><td>កោសិកា លក្ខណៈ: ធម្មតា</td><td>កោសិកា លក្ខណៈ: ស្វិត</td></tr>
</table></td>
<td>– សិស្សប៉ះស្ទាបកោសិការួចគិត និងឆ្លើយ។</td>
</tr>
<tr>
<td>ផ្តល់កិច្ចការផ្ទះដល់សិស្ស។</td>
<td>ជំហានទី៥<br><br>ហេតុអ្វីបានជាក្រោយពេលធ្លាក់ឈាមដ៏ច្រើន ឬអ្នកអត់ទឹកយូរ គេមិនឲ្យផឹកទឹកច្រើនភ្លាម?</td>
<td>កត់ត្រាកិច្ចការផ្ទះ។</td>
</tr>
</table>

# សន្លឹកកិច្ចការ

ប្រធានបទ៖ បណ្តូរទឹកក្នុងកោសិការុក្ខជាតិ

សំណួរគន្លឹះ៖  តើបណ្តូរទឹកក្នុងកោសិការុក្ខជាតិប្រព្រឹត្តទៅយ៉ាងដូចម្តេច?

សម្មតិកម្ម៖



កោសិកាធម្មតា+ទឹក          កោសិកាស្វិត+ទឹក          កោសិកាធម្មតា+ទឹកអំបិល

ចូរសង្កេតមើល តើកោសិកាទាំងនេះមានសភាពដូចម្តេច?

--------------------------------------------------------------------------------

--------------------------------------------------------------------------------

ដំណើរការពិសោធនិ ៖

+សម្ភារៈ ៖ សូលុយស្យុងអំបិល15% ខ្ទឹមបារាំង ទឹកស្អាត កែវជ័រ កូនកាំបិត មីក្រូទស្សន៍ បន្ទះឡាម  បន្ទះឡាមែដង្កៀប  ឡាមកោពុកមាត់ បំពង់ពីប៉ែតជ័រ

+ដំណើរការ៖

–រៀបចំកែវ២ ដោយកែវមួយដាក់ទឹក ហើយកែវមួយទៀតដាក់សូលុយស្យុងអំបិល15%

–កាត់កោសិកាខ្ទឹមបារាំងទំហំ មួយសង់ទីម៉ែតការ៉េ($1cm^2$) ហើយឆ្កឹះយកស្រទាប់ភ្នាសស្តើងកោសិកាដាក់លើបន្ទះឡាម ហើយបន្តក់ទឹក  បន្ទាប់មកគ្របបន្ទះឡាមែពីលើ និងពិនិត្យមើលក្នុងមីក្រូទស្សន៍។

–ឆ្កឹះយកស្រទាប់ភ្នាសស្តើងកោសិកា ទំហំ$1cm^2$ ថ្មីទៀតដាក់លើបន្ទះឡាម បន្ទាប់មកបន្តក់ សូលុយស្យុងអំបិលទុករយៈពេល 3–5នាទី ហើយធ្វើដូចពិសោធន៍លើកមុន។

–ការសង្កេតមើលកោសិកាខ្ទឹមបារាំង ដោយមីក្រូទស្សន៍ ត្រូវមើលពីលេខតូចទៅលេខធំ

លទ្ធផលៈ សូមគូររូបកោសិកាឲ្យបានត្រឹមត្រូវ

| ទឹក | ០% | ១៥% |
|---|---|---|
| លក្ខណៈកោសិកា | | |

**វិភាគ និងសន្និដ្ឋានៈ**

ក.តើកោសិកាខ្ទឹមបារាំងក្នុងកែវទី១ មានសភាពដូចម្តេច?

.......................................................................................................................

ខ.តើកោសិកាខ្ទឹមបារាំងក្នុងកែវទី២ មានសភាពដូចម្តេច?

.......................................................................................................................

ចូរធ្វើការសន្និដ្ឋានលើលទ្ធផលរបស់អ្នកៈ

.......................................................................................................................

.......................................................................................................................

.......................................................................................................................

# ប្លង់ក្តារខៀន

**សំណួរគន្លឹះ៖**

| តើបណ្តូរទឹកក្នុងកោសិការុក្ខជាតិ ប្រព្រឹត្តទៅយ៉ាងដូចម្តេច? |
|---|




កោសិកាធម្មតា+ ទឹក　　កោសិកាស្វិត+ ទឹក　　កោសិកាធម្មតា+ទឹកអំបិល

ចូរសង្កេតមើល តើកោសិកាទាំងនេះមានសភាពដូចម្តេច?

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

**លទ្ធផល៖**

| ទឹក | ០% | ១៥% |
|---|---|---|
| លក្ខណៈកោសិកា | | |

**សន្និដ្ឋាន៖**

-កោសិការីកប៉ោង បណ្តាលមកពីកំហាប់ក្រៅកោសិកាទាបជាងកំហាប់ក្នុងកោសិកា។

-កោសិការួមតូច បណ្តាលមកពីកំហាប់ក្រៅកោសិកាខ្ពស់ជាងកំហាប់ក្នុងកោសិកា។

**បញ្ញត្តិ៖**

- *ពេលទឹកចូលក្នុងកោសិកាធ្វើឲ្យកោសិការីកប៉ោង ហៅថា ប្លាស្មូលីស*
- *ពេលទឹកចេញពីកោសិកាធ្វើឲ្យកោសិការួមតូច ហៅថា ដេប្លាស្មូលីស*
- *ពេលទឹកចេញចូលក្នុងកោសិកាស្មើគ្នា ធ្វើឲ្យកោសិកាមានទំហំធម្មតា ហៅថា ទួសេសង់។*

## ១.៤. ផែនដីវិទ្យា

### ១.៤.១ សិលា

### ១.៤.២ តារានិករ ឬកញ្ចុំផ្កាយ

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ ផែនដីវិទ្យា, ថ្នាក់ទី៨ (កម្មវិធីថ្មី)

២. ប្រធានបទ៖ សិលា

៣. វត្ថុបំណង៖

- ពន្យល់បានពីប្រភេទរ៉ែមួយចំនួនដែលមាននៅក្នុងសិលាក្រនីត បានច្បាស់លាស់ តាមរយៈការធ្វើពិសោធ។
- គូររូបភាពភាគល្អិតៗ ដែលមាននៅក្នុងសិលាក្រានីតដូចជារ៉ែក្វាត ផែលស្ប៉ាត និងមីកា បានត្រឹមត្រូវតាមរយៈការសង្កេតដោយប្រើកែវពង្រីកនិងមីក្រូទស្សន៍។
- យកចិត្តទុកដាក់និងចូលរួមអភិរក្សធនធានធម្មជាតិ ដោយការប្រើប្រាស់សម្ភារៈផ្សេងៗក្នុងជីវភាពរស់នៅដោយសន្សំសំចៃ។

៤. រយៈពេល៖ ៥០នាទី

៥.សម្ភារៈឧបទ្ទេស៖

- រូបភាព, សិលាម៉ាក់ម៉ា, ក្រដាសប្រោះ, កែវពង្រីក, មីក្រូទស្សន៍, មេដែក,ក្រដាសធំ, ជ្រក់, គម្រូរ៉ែ ដូចជា៖ មីការ, ក្វាតផែលស្ប៉ាត។

<table>
<tr><th>សកម្មភាពគ្រូ</th><th>ខ្លឹមសារមេរៀន</th><th>សកម្មភាពសិស្ស</th></tr>
<tr><td></td><td>ជំហានទី១ (១នាទី)<br>. រដ្ឋបាលថ្នាក់: វិន័យ បទបញ្ជាផ្ទៃក្នុង វត្តមាន</td><td>. ប្រធានថ្នាក់ឡើងរាយការណ៍</td></tr>
<tr><td>ខ្ញុំមានរូបភាពថតបានជិតទីនេះ<br>១.តើរូបនេះបង្ហាញពីអ្វី?<br><table><tr><td>រូបចម្លាក់</td><td>កៅអី</td><td>រូបសសរ របង</td></tr></table><br>២.តើរបស់ដែលយើងឃើញនេះធ្វើចេញពីអ្វី?</td><td>ជំហានទី២ (៧នាទី)<br>រំលឹកមេរៀននិងសំណួរបំផុស<br>បង្ហាញរូបភាព និងអ្វីដែលគេស្គាល់ច្បាស់ រួចទាញសំណួរគន្លឹះ</td><td>១. រូបភាពរូបចម្លាក់ កៅអីសាធារណៈ និង រូបសសររបងវិទ្យាស្ថានជាតិអប់រំ។<br>២.វាធ្វើពី សិលា ស៊ីម៉ង់ត៍ ខ្សាច់ ទឹក។</td></tr>
</table>

| សំណួរគន្លឹះ៖ តើមានអ្វីខ្លះនៅក្នុងសិលា? | | |
|---|---|---|
| ១.ចែកសន្លឹកកិច្ចការ<br>២.តើអ្នកធ្លាប់ស្គាល់ជ្រក់ដែរឬទេ?<br>តើជ្រក់ធ្វើពីអ្វី?<br>បន្លែជាច្រើនរួមផ្សំគ្នា កើតបានជាជ្រក់។ (បង្ហាញរូបជ្រក់)<br>៣.តើមានអ្វីផ្សំគ្នា បង្កើតបានជា សិលា?<br>៤.ផ្តល់គម្រូដុំសិលាមួយចំនួន ឲ្យសិស្សកាន់ ពិនិត្យ ភ្លក្ស(លាបទឹកលើសិលាដើម្បីឲ្យមើលកាន់តែច្បាស់ | ជំហានទី៣ (៣៣នាទី)<br>មេរៀន រ៉ែ<br>រូបភាព ជ្រក់<br>ធ្វើសកម្មភាពងាយៗ លើអ្វីដែលសិស្សជួបជាញឹកញាប់ក្នុងជីវភាពប្រចាំថ្ងៃ | ១.ទទួលសន្លឹកកិច្ចការ<br>២.ស្គាល់<br>ជ្រក់ធ្វើពី ការ៉ុត ល្ហុង ត្រសក់ មើមខ្ទឹម<br>សិស្សធ្វើការទស្សន៍ទាយ<br>៣.ដុំសិលាតូចៗ, ធាតុគីមី, ត្បូង មិនទាន់ច្នៃ<br>៤. យកដុំសិលាមកស្ទាប ពិនិត្យ និង ភ្លក្ស ហើយប្រាប់នូវអ្វីដែលគេទើបរកឃើញ |
| **ចូរសង្កេតសិលា ដោយប្រើកែវពង្រីក និងមីក្រូទស្សន៍!** (រយៈពេល ២០នាទី) | | |
| ៥.នេះជាសិលាដែលខ្ញុំទើបយកមកពីភ្នំបាសិដ្ឋ ជាប្រភេទសិលាដូចគ្នានឹងសិលាដែលមានក្នុងដៃអ្នក។ពន្យល់ និងបិទសេចក្តីណែនាំពីដំណើរការពិសោធ។<br>(គ្រូដាសជូនភ្ជាប់និងរូបភាពផង)<br>ចែកសិស្សជា៤ក្រុម | ដំណើរការពិសោធ<br>លក្ខណៈរបស់គ្រាមក្នុងសិលាគ្រានីតមានពណ៌ខ្មៅ ស សថ្លា មានរាងមូលមានភ្ជាប់គ្នា ជាស្រទាប់ស្តើងៗ | ៥. ស្តាប់តាមការណែនាំ និងចាប់ផ្តើមការពិសោធតាម ក្រុមក្រោមការសម្របសម្រួលរបស់គ្រូ ដោយការបំពេញក្នុងសន្លឹកកិច្ចការ និងគូរូប ហើយបញ្ជាក់លក្ខណៈរបស់គ្រាម។ |
| ១.ពន្យល់បង្ហាញពីលក្ខណៈប្រភេទគ្រាមបី ប្រភេទដែលមានភាគច្រើនក្នុងសិលាគ្រានីត ដោយបង្ហាញរូបភាពនិងរូបសំណាកពិតៗនៃរ៉ែក្វាត ផែលស្ប៉ាត និងមីកា។ | ជំហានទី៤ ពង្រឹងពុទ្ធិ (៨នាទី)<br> | ១. ស្តាប់និងពិនិត្យមើលតាមការណែនាំរបស់គ្រូ ហើយធ្វើការកត់ចំណាំគិតដល់គ្រាមដែលគេទើបបានសង្កេត។ |

| | | |
|---|---|---|
| ២. ឲ្យតំណាងក្រុមសិស្សបិទរូបរបស់ខ្លួនលើក្តារខៀន ហើយធ្វើការពន្យល់តាមគំនិតរបស់ក្រុមគេ<br><br>៣. ឲ្យសិស្សបំពេញសេចក្តីសន្និដ្ឋាន និង គ្រូដើរកត់ត្រា រួចសំយោគសេចក្តីសន្និដ្ឋានរបស់សិស្ស | <br><br><br><br>សន្និដ្ឋានៈ សិលាមួយចំនួន កើតចេញពីការរួមផ្សំនៃក្រាម ប្រភេទខុសៗគ្នាជាច្រើន។ ក្រាមទាំងនោះមានឈ្មោះថា រ៉ែ។ | ២. បិទរូបរបស់ ខ្លួនលើក្តារ ខៀន ហើយធ្វើការពន្យល់ តាមគំនិតរបស់ក្រុមគេ<br><br>៣. បំពេញសេចក្តីសន្និដ្ឋាន |
| ១. សូមបំពេញបញ្ចប់លើសន្លឹកកិច្ចការ ហើយផ្តល់ឲ្យខ្ញុំនៅម៉ោងក្រោយ<br><br>២. របស់ដែលយើងប្រើប្រាស់សព្វថ្ងៃភាគច្រើនធ្វើពីវត្ថុធាតុដើមជារ៉ែ ដែលជាធនធានធម្មជាតិមានតម្លៃ ដូចនេះ យើងគួរគប្បីប្រើប្រាស់ដោយសន្សំសំចៃ ដើម្បីឲ្យវាមាននិរន្តរភាព។ | ជំហានទី៥ (១នាទី) កិច្ចការផ្ទះ<br><br>បំផុសស្មារតីយកចិត្តទុកដាក់រៀនសូត្រ និងចូលរួមអភិរក្ស ធនធានធម្មជាតិ ដោយការប្រើប្រាស់សម្ភារៈផ្សេងៗ ក្នុងជីវភាពរស់នៅដោយសន្សំសំចៃ។ | ១. កត់ត្រាកិច្ចការផ្ទះ ៖ បំពេញសន្លឹកកិច្ចការផ្ទះ កំណត់ចំណាំ<br><br>២. ស្តាប់ពិចារណា និងអនុវត្តតាមការណែនាំរបស់គ្រូ |

## លំនាំពិសោធន៍



១. ដាក់កម្ទេចសិលាតូចៗមួយស្លាបព្រាកាហ្វេ ក្នុងចាន

២. ចាក់ទឹកចូល យកមេដៃកូរឲ្យសព្វរួចចាក់ទឹកល្អក់ចេញ ធ្វើដដែលៗរហូតទឹកថ្លា





៣. យកកម្ទេចសិលាក្នុងចំនួនសមល្មមងាយសង្កេត មកដាក់លើក្រដាសច្រោះ

៤. ពិនិត្យ សង្កេតគ្រាប់ក្រាមនៃកម្ទេចសិលា ដោយប្រើកែវពង្រីក និងមីក្រូទស្សន៍

៥. គូររូបក្រាមនៃកម្ទេចសិលា ដាក់ក្នុងសន្លឹកកិច្ចការ



៦. គូររូបដដែលដាក់ក្នុងក្រដាសចែកឲ្យ (ដោយប្រើហ្វឺត ដើម្បីងាយស្រួលមើល)

៧. ប្រើមេដែកពិនិត្យមើលឲ្យដឹងថាតើក្នុងកម្ទេចសិលានោះមានធាតុដែកឬទេ

# សន្លឹកកិច្ចការ

កាលបរិច្ឆេទៈ ............................ ម៉ោងៈ............................

ឈ្មោះ ...................................

សំណួរគន្លឹះ៖

សម្មតិកម្ម៖

---

---

---

កំណត់ចំណាំ

---

---

---

ចូរសង្កេតដោយប្រើកែវពង្រីក និងមីក្រូទស្សន៍! (រយៈពេល ២០នាទី)

ចូរគូររូបភាព៖

សន្និដ្ឋាន៖

---

---

---

# ប្លង់ក្តារខៀន

| | | | | |
|---|---|---|---|---|
| រូបចម្លាក់ | កៅអី | សរសេរ | រូបជ្រក់ | រូបរ៉ែ ក្នុង សិលា ក្រានីត |

- សិលា - សិលា - សិលា

- ស៊ីម៉ង់ត៍ - ស៊ីម៉ង់ត៍ - ស៊ីម៉ង់ត៍

- ខ្សាច់ - ខ្សាច់ - ខ្សាច់

សំណួរគន្លឹះ៖

**តេមានអ្វីខ្លះនៅក្នុងសិលា**

សម្មតិកម្ម៖

. ដុំសិលាតូចៗ

. ធាតុគីមីផ្សេងៗ

. ត្បូងមិនទាន់ឆ្អែ

**ចូរសង្កេតសិលា ដោយប្រើកែវពង្រីក និងមីក្រូទស្សន៍!**

**រូបភាពរ៉ែ ក្វាត មីកា ផែលស្ប៉ាត**



| | | | |
|---|---|---|---|
| រូប តំណាង ក្រុម១ | រូប តំណាង ក្រុម២ | រូប តំណាង ក្រុម៣ | រូប តំណាង ក្រុម៤ |

សន្និដ្ឋាន៖

សិលាមួយចំនួនកើតចេញពីការរួមផ្សំនៃក្រាម ប្រភេទខុសៗគ្នាជាច្រើន។ ក្រាមទាំងនោះមានឈ្មោះថារ៉ែ។

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ ផែនដីវិទ្យា, ថ្នាក់ទី៨ (កម្មវិធីថ្មី)

២. ប្រធានបទ៖ តារានិករ ឬកញ្ចុំផ្កាយ

៣. វត្ថុបំណង៖

- ពន្យល់បានពីមូលហេតុនៃការមើលឃើញកញ្ចុំផ្កាយខុសៗគ្នានៅតាមខែនីមួយៗ។
- រាប់ឈ្មោះកញ្ចុំផ្កាយដែលធ្លាប់ស្គាល់បានច្បាស់លាស់។
- យកចិត្តទុកដាក់សង្កេតកញ្ចុំផ្កាយនៅពេលយប់។

៤. រយៈពេល៖ ៦០នាទី

៥.សម្ភារៈឧបទ្ទេស៖

- ភូគោល គំរូព្រះអាទិត្យ ផែនទីតារា រូបភាពកញ្ចុំផ្កាយ។
- ពាក្យគន្លឹះ កញ្ចុំផ្កាយ រង្វិលជុំ រង្វិលខ្វាល់ ទីតាំងព្រះអាទិត្យ សមរាត្រី ស៊ុលស្ទីស។

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | ជំហានទី១(២នាទី) | |
| ១.តើធ្លាប់មើលផ្ទៃមេឃនៅពេលយប់ដែរឬ ទេ?<br>២.តើឃើញមានអ្វីខ្លះនៅលើមេឃពេលយប់? | ជំហានទី (៣នាទី)<br>. នៅពេលយប់មេឃស្រឡះ យើងអាចមើលឃើញផ្កាយរាប់លានដួង។ ជួនកាលមើលឃើញព្រះច័ន្ទមួយចំណិតជួនកាលពេញវង់។ | ១. ធ្លាប់មើលនៅពេលមេឃស្រឡះគ្មានពពក។<br>២. មានផ្កាយ កញ្ចុំផ្កាយ ព្រះច័ន្ទមួយចំណិត ឬពេញវង់។ |
| ១. តើធ្លាប់ស្គាល់កញ្ចុំផ្កាយអ្វីខ្លះ?<br>. ចែកសិស្សជាក្រុមតូចៗ ហើយចែកផែនទីតារា១<br><br>២. តាមការពិនិត្យផែនទីតារា១ តើស្គាល់កញ្ចុំផ្កាយ អ្វីខ្លះ? | ជំហានទី៣ (៣៥នាទី)<br>. កញ្ចុំផ្កាយ ឬតារានិករ ជាក្រុមផ្កាយ ឬបណ្តុំតារា ដែលលេចឡើងជាទ្រង់ទ្រាយផ្សេងៗ (សត្វ មនុស្ស ឬវត្ថុ) តាមការគិតរបស់តារាវិទូ<br>. កញ្ចុំផ្កាយដែលប្រជាជនខ្មែរស្គាល់ច្បាស់គឺ ផ្កាយយាម ផ្កាយក្រពើ | ១. កញ្ចុំផ្កាយយាម ផ្កាយក្រពើ ផ្កាយកូនមាន់។<br><br>២. មិនច្បាស់ |

| | | |
|---|---|---|
| . ចែកផែនទីតារា២<br>៣. តើស្គាល់កញ្ចុំផ្កាយអ្វីខ្លះ នៅក្នុងផែនទីតារា២?<br>. ចែកផែនទីតារា៣ ៤ និង៥<br>៤. តើស្គាល់កញ្ចុំផ្កាយអ្វីខ្លះនៅក្នុងផែនទីតារា៣ ៤ និង៥?<br>៥. តើផែនទីតារា២ ៣ ៤ និង៥ ដូចគ្នាឬខុសគ្នា? ហេតុអ្វី?<br>៦. រង្វិលជុំផែនដី ធ្វើឱ្យកញ្ចុំផ្កាយប្រែប្រួលដូចម្តេច?៕ | ផ្កាយកូនមាន់ ផ្កាយ ខ្យាដំរី... | ៣. ផ្កាយយាម ផ្កាយក្រពើ ផ្កាយសឹង្ហ<br>៤. ផ្កាយយាម ផ្កាយក្រពើ ផ្កាយសឹង្ហ ផ្កាយខ្យាដំរី ផ្កាយសេះមានស្លាប<br>៥. ខុសគ្នា ដោយសាររង្វិលខ្វាល់ផែនដី<br>៦.... |

| កញ្ចុំផ្កាយ | ៤ មេសា, ១៩pm | ៥មេសា, ០០ am | ៥មេសា, ៥ pm | 5មេសា, ១២pm |
|---|---|---|---|---|
| ផ្កាយយាម | | | | |
| ផ្កាយសិង្ហ | | | | |
| ផ្កាយខ្យាដំរី | | | | |
| ផ្កាយសេះមានស្លាប | | | | |

សំណួរគន្លឹះ៖ តើកញ្ចុំផ្កាយដែលយើងមើលឃើញប្រែប្រួលបានយ៉ាងដូចម្តេច?

បង្ហាញរូបចលនារង្វិលជុំនៃផែនដី ហើយឱ្យសិស្សទស្សន៍ទាយ។

. តើយើងអាចមើលឃើញ




សម្មតិកម្ម
- A
- B
- C
- D

ចូរបង្ហាញពីការប្រែប្រួលនៃកញ្ចុំផ្កាយនៅតាមខែនីមួយៗ។

ដំណើរការ

–ដាក់គំរូព្រះអាទិត្យ នៅលើតុកណ្តាលថ្នាក់រៀន សិស្ស ៤ នាក់កាន់រូបភាពកញ្ចុំផ្កាយ ឈរនៅជ្រុងថ្នាក់ទាំងបួន សិស្សម្នាក់កាន់ភូគោលតំណាង ផែនដី ហើយធ្វើចលនាជុំវិញព្រះអាទិត្យ ហើយឈប់នៅចំពីមុខរូបកញ្ចុំផ្កាយទាំងបួន ដោយបែរខ្នងមករកព្រះអាទិត្យ។

. បិតតារាងលទ្ធផលលើក្តារខៀន ហើយឱ្យក្រុមសិស្សឡើង

សកម្មភាព (២០ នាទី) សិស្ស ៥នាក់ធ្វើសកម្មភាព សិស្សផ្សេងៗទៀតចាំសង្កេត ហើយកត់ត្រា។



<table>
<tr>
<td colspan="2">បំពេញ:<br>ក្រុម ១ ចំណុច A<br>ក្រុម ២ ចំណុច B<br>ក្រុម ៣ ចំណុច C<br>ក្រុម ៤ ចំណុច D</td>
<td>ជំហានទី៤ (៧នាទី)<br>លទ្ធផល៖<br>
<table>
<tr><td>ខែ</td><td>កញ្ចុំផ្កាយម៉ោង 00am</td><td>កញ្ចុំផ្កាយ</td></tr>
<tr><td>ចំណុច A (ធ្នូ)</td><td>កញ្ចុំផ្កាយយាម</td><td>កញ្ចុំផ្កាយ</td></tr>
<tr><td>ចំណុច B (មីនា)</td><td>កញ្ចុំផ្កាយសីង្ហ</td><td>កញ្ចុំផ្កាយ</td></tr>
<tr><td>ចំណុច C (មិថុនា)</td><td>កញ្ចុំផ្កាយខ្យាដំរី</td><td>កញ្ចុំផ្កាយ</td></tr>
<tr><td>ចំណុច D (កញ្ញា)</td><td>កញ្ចុំផ្កាយសេះមានស្លាប</td><td>កញ្ចុំផ្កាយ</td></tr>
</table>
សន្និដ្ឋាន<br>✓ យើងអាចមើលឃើញកញ្ចុំផ្កាយខុសៗគ្នានៅតាមខែនីមួយៗ ដោយសារ រង្វិលជុំរបស់ផែនដី។<br>✓ ពេលវេលាខុសគ្នា យើងអាចមើលឃើញទីតាំងកញ្ចុំផ្កាយខុសគ្នាដោយសាររង្វិលខ្វាល់របស់ផែនដី។</td>
</tr>
<tr>
<td>. ចូរសង្កេតកញ្ចុំផ្កាយយប់នេះនៅផ្ទះ។ តើមានកញ្ចុំផ្កាយអ្វីខ្លះដែលយើងអាចមើលឃើញ?</td>
<td>ជំហានទី៥ (៣នាទី) កិច្ចការផ្ទះ<br>. យកចិត្តទុកដាក់សង្កេតកញ្ចុំផ្កាយនៅពេលយប់ និងប្រាប់ឈ្មោះកញ្ចុំផ្កាយដែលបានមើលឃើញ។</td>
<td>. ជ្រើសរើសផែនទីតារាដែលត្រូវសង្កេតនៅយប់នេះ។</td>
</tr>
</table>

# សន្លឹកកិច្ចការ

ឈ្មោះ ..............................................

១. ចូរសរសេរឈ្មោះកញ្ចុំផ្កាយដែលអ្នកស្គាល់តាមការសង្កេតនៅលើផែនទីតារា។

| កញ្ចុំផ្កាយ | ៤ មេសា, ១៩pm | ៥មេសា, 00 am | ៥មេសា, ៥ pm | 5មេសា, ១២pm |
|---|---|---|---|---|
| ផ្កាយយាម | | | | |
| ផ្កាយសិង្ហ | | | | |
| ផ្កាយខ្យាដំរី | | | | |
| ផ្កាយសេះមានស្លាប | | | | |

២. ចូរបង្ហាញពីការប្រែប្រួលនៃកញ្ចុំផ្កាយនៅតាមខែនីមួយៗ និងបំពេញឈ្មោះកញ្ចុំផ្កាយនៅក្នុងប្រអប់ខាងក្រោម។



លទ្ធផល៖

| ខែ | កញ្ចុំផ្កាយម៉ោង 00 am | កញ្ចុំផ្កាយម៉ោង ១២ pm |
|---|---|---|
| ចំណុច A (ធ្នូ) | | |
| ចំណុច B (មីនា) | | |
| ចំណុច C (មិថុនា) | | |
| ចំណុច D (កញ្ញា) | | |

សន្និដ្ឋាន៖

-----------------------------------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------------------------------

# ប្លង់ក្តារខៀន

| កញ្ចុំផ្កាយ | ៨ មេសា ១៩pm | ៥មេសា ០០ am | ៥មេសា ៥ pm | 5មេសា ១២pm |
|---|---|---|---|---|
| ផ្កាយយាម | | | | |
| ផ្កាយសិង្ហ | | | | |
| ផ្កាយខ្យាដំរី | | | | |
| ផ្កាយសេះមានស្លាប | | | | |

សំណួរគន្លឹះ៖ តើកញ្ចុំផ្កាយដែលយើងមើលឃើញប្រែប្រួលបានយ៉ាងដូចម្តេច?




.ចូរបង្ហាញពីការប្រែប្រួលនៃកញ្ចុំផ្កាយនៅតាមខែនីមួយៗ។

| ខែ | កញ្ចុំផ្កាយម៉ោង ០០ am | កញ្ចុំផ្កាយម៉ោង ១២ pm |
|---|---|---|
| ចំណុច A (ធ្នូ) | កញ្ចុំផ្កាយយាម | កញ្ចុំផ្កាយខ្យាដំរី |
| ចំណុច B (មីនា) | កញ្ចុំផ្កាយសឹង្ហ | កញ្ចុំផ្កាយសេះមានស្លាប |
| ចំណុច C (មិថុនា) | កញ្ចុំផ្កាយខ្យាដំរី | កញ្ចុំផ្កាយយាម |
| ចំណុច D (កញ្ញា) | កញ្ចុំផ្កាយសេះមានស្លាប | កញ្ចុំផ្កាយសឹង្ហ |

សន្និដ្ឋាន ៖

- ✓ យើងអាចមើលឃើញកញ្ចុំផ្កាយខុសៗគ្នានៅតាមខែនីមួយៗ ដោយសារ វង្វិល ជុំរបស់ផែនដី។
- ✓ ពេលវេលាខុសគ្នា យើងអាចមើលឃើញទីតាំងកញ្ចុំផ្កាយខុសគ្នា ដោយសាររង្វិលខ្វាល់របស់ផែនដី។

# ២. កិច្ចតែងការបង្រៀនគម្រូរបស់សិក្ខាកាម

## ២.១. រូបវិទ្យា

### ២.១.១ ទ្វាស់អាំងតង់ស៊ីតេកម្លាំងកកិត

### ២.១.២ ចរន្តអគ្គិសនី

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ រូបវិទ្យា, ថ្នាក់ទី៨ (កម្មវិធីថ្មី)

២. ប្រធានបទ៖ រង្វាស់អាំងតង់ស៊ីតេកម្លាំងកកិត

៣. វត្ថុបំណង៖

- ពន្យល់ពីអាំងតង់ស៊ីតេកម្លាំងកកិតបានត្រឹមត្រូវតាមរយៈការពិសោធ។
- វាស់អាំងតង់ស៊ីតេកម្លាំងកកិតបានត្រឹមត្រូវតាមរយៈការពិសោធ។
- ប្រៀបធៀបអាំងតង់ស៊ីតេកម្លាំងកកិតបានត្រឹមត្រូវតាមរយៈការពិសោធ ។
- មានបម្រុងប្រយ័ត្នខ្ពស់ក្នុងការធ្វើពិសោធ។

៤. រយៈពេល៖ ៥០នាទី

៥.សម្ភារៈឧបទ្ទេស៖

- សៀវភៅសិស្សរូបវិទ្យាថ្នាក់ទី៨ថ្មី។
- ឌីណាម៉ូម៉ែត្រ ដុំឈើបន្ទះកញ្ចក់រាប បន្ទះក្តា ខ្មៅដៃរាងស៊ីឡាំង។

| សកម្មភាពសិស្ស | ខ្លឹមសារមេរៀន | សកម្មភាពគ្រូ |
|---|---|---|
| . ពិនិត្យអវត្តមានសិស្ស<br>. ពិនិត្យសណ្តាប់ធ្នាប់ អនាម័យថ្នាក់រៀន។ | ជំហានទី១ (៣នាទី)<br>រដ្ឋបាលថ្នាក់រៀន | ប្រធានថ្នាក់ឡើងរាយការណ៍<br>. អង្គុយយ៉ាងស្ងៀមស្ងាត់ |
| . ដូចម្តេចដែលហៅថាកម្លាំងកកិត?<br>. តើអ្វីទៅជាអាំងតង់ស៊ីតេកម្លាំង? | ជំហានទី២(៥នាទី)<br>រំលឹកមេរៀនចាស់<br>. និយមន័យកម្លាំង<br>. អាំងតង់ស៊ីតេកម្លាំង | .ជាកម្លាំងដែលមានអំពើលើអង្គធាតុកំពុងមានចលនា តែមានទិសដៅផ្ទុយពីទិសដៅនៃចលនា។<br>. ជាទំហំនៃកម្លាំង ឬអាំងតង់ស៊ីតេនៃកម្លាំងវាស់ដោយឌីណាម៉ូម៉ែត្រ។ |
| . លំនាំបញ្ហា<br>ឱ្យសិស្សសង្កេតការពិសោធងាយរបស់គ្រូ(ឱ្យសិស្សម្នាក់ទាញសិស្សម្នាក់ទៀត លើកទី១សិស្សដែលត្រូវ | ជំហានទី៣(៣៥នាទី)<br>មេរៀនប្រចាំថ្ងៃ<br>កម្លាំងកកិត<br>២.៥–រង្វាស់អាំងតង់ស៊ីតេកម្លាំងកកិត | . សិស្សសង្កេត |

| | | |
|---|---|---|
| គេទាញមិនពាក់ចង់ថ្លា និង លើកទី ២ សិស្សដែលត្រូវគេទាញពាក់ចង់ថ្លា )។ | | |
| សំនួរគន្លឹះ៖ តើអាំងតង់ស៊ីតេកម្លាំងកកិតអាស្រ័យនឹងកត្តាអ្វីខ្លះ? | | |
| ការបង្កើតសម្មតិកម្ម<br>. ចែកសន្លឹកកិច្ចការឱ្យសិស្ស។<br>. ឱ្យតំណាងក្រុមបង្ហាញ ពីលទ្ធផលដែលបានពិភាក្សា ហើយពន្យល់ហេតុផល។<br>. ឱ្យសិសសបញ្ចេញយោបល់ផ្សេងៗបើមាន។<br><br>ដំណើរការពិសោធន៍:<br>. ផ្តល់សម្ភារៈតាមក្រុម។<br>. ពន្យល់ដំណើរការពិសោធន៍ដោយបង្ហាញឧបករណ៍ជាក់ស្តែង។<br>. ត្រួតពិនិត្យសិស្សគ្រប់ក្រុម។ | . កម្លាំងកកិតអាស្រ័យនឹងធម្មជាតិនៃផ្ទៃប៉ះ ទម្ងន់ និងប្រភេទនៃកកិត និងមិនអាស្រ័យនឹងទំហំនៃផ្ទៃប៉ះទេ។<br><br>ដំណើរការពិសោធន៍<br>១–ភ្ជាប់ឌីណាម៉ូម៉ែត្រនឹងដុំឈើតាន់មួយដុំរួចលើកតាមខ្សែឈរ។<br><br>២–ភ្ជាប់ឌីណាម៉ូម៉ែត្រនឹងដុំឈើមួយដុំដដែលរួចទាញវាលើបន្ទះកញ្ចក់រាបស្មើលើប្លង់ដេក។ដុំឈើមានចលនាស្មើពេលនោះឌីណាម៉ូម៉ែត្រចង្អុលអាំតង់ស៊ីតេកម្លាំងទាញ.......N។<br><br>៣.ភ្ជាប់ឌីណាម៉ូម៉ែត្រនឹងដុំឈើមួយដុំដដែលរួចទាញវាលើបន្ទះក្តារលើប្លង់ដេក។នៅពេលដុំឈើមានចលនាស្មើយើងឃើញឌីណាម៉ូម៉ែត្រចង្អុល....... N។<br><br>៤–ភ្ជាប់ឌីណាម៉ូម៉ែត្រនឹងដុំឈើមួយដុំដដែលប៉ុន្តែប្តូរផ្ទៃប៉ះរបស់វាឱ្យតូចជាងមុនរួចទាញលើបន្ទះក្តារលើប្លង់ដេក។ នៅពេលដុំឥដ្ឋមានចលនាស្មើយើងឃើញឌីណាម៉ូម៉ែត្រចង្អុល...N។ | ចម្លើយស្មានទុក<br>. ពិភាក្សា និងសរសេរចម្លើយស្មានទុកក្នុងសន្លឹកកិច្ចការ(កម្លាំងកកិតអាស្រ័យនឹងធម្មជាតិនៃផ្ទៃប៉ះ ទម្ងន់ និងប្រភេទនៃកកិត និងមិនអាស្រ័យនឹងទំហំនៃផ្ទៃប៉ះទេ ។<br>. សិស្សស្តាប់ ហើយសង្កេត<br>. ទទួលសម្ភារៈពីគ្រូ។<br><br>. សិស្សអានសន្លឹកកិច្ចការ ហើយធ្វើពិសោធន៍យ៉ាងយកចិត្តទុកដាក់។<br><br><br><br> |

<table>
<tr>
<td></td>
<td>៥–ភ្ជាប់ឌីណាម៉ូម៉ែត្រនឹងដុំឈើមួយដុំដដែលប៉ុន្តែកល់ខ្មៅដៃពីខាងក្រោម រួចទាញលើបន្ទះក្ដារលើប្លង់ដេក។នៅពេលដុំឈើមានចលនាស្មើយើង ឃើញឌីណាម៉ូម៉ែត្រចង្អុល.......N។<br><br>៦–ភ្ជាប់ឌីណាម៉ូម៉ែត្រនឹងដុំឈើពីរដុំ រួចទាញលើបន្ទះក្ដារលើប្លង់ដេក។នៅពេលដុំឈើមានចលនាស្មើយើង ឃើញឌីណាម៉ូម៉ែត្រចង្អុល.......N។<br><br>ប្រមូលទិន្នន័យ និងវិភាគលទ្ធផល</td>
<td>5<br><br>6<br></td>
</tr>
<tr>
<td>ប្រមូលទិន្នន័យ និងវិភាគលទ្ធផល<br><br>តាមរយៈលទ្ធផលពិសោធន៍ តើអ្នកទទួលបានលទ្ធផលយ៉ាងដូចម្ដេច?</td>
<td><table><tr><th>ពិសោធ<br>ក្រុម</th><th>១</th><th>២</th><th>៣</th><th>៤</th><th>៥</th><th>៦</th></tr><tr><td>១</td><td></td><td></td><td></td><td></td><td></td><td></td></tr><tr><td>២</td><td></td><td></td><td></td><td></td><td></td><td></td></tr><tr><td>៣</td><td></td><td></td><td></td><td></td><td></td><td></td></tr><tr><td>៤</td><td></td><td></td><td></td><td></td><td></td><td></td></tr></table></td>
<td>. តំណាងក្រុមនីមួយៗលើងបង្ហាញលទ្ធផលរបស់ពួកគេ<br><table><tr><th>ពិសោធ<br>ក្រុម</th><th>១</th><th>២</th><th>៣</th><th>៤</th><th>៥</th><th>៦</th></tr><tr><td>១</td><td></td><td></td><td></td><td></td><td></td><td></td></tr><tr><td>២</td><td></td><td></td><td></td><td></td><td></td><td></td></tr><tr><td>៣</td><td></td><td></td><td></td><td></td><td></td><td></td></tr><tr><td>៤</td><td></td><td></td><td></td><td></td><td></td><td></td></tr></table></td>
</tr>
<tr>
<td>. តើកម្លាំងលើកអង្គធាតុតាមខ្សែឈរធំជាងឬតូចជាងកម្លាំងទាញអង្គធាតុតាមខ្សែដេកត្រង់ស្មើ?<br>. ចំពោះអង្គធាតុតែមួយបើយើងប្ដូរផ្ទៃប៉ះនៃអង្គធាតុតើអាំងតង់ស៊ីតេកម្លាំងកកិតរបស់អង្គធាតុផ្លាស់ប្ដូរ ឬទេ?<br>. តើកម្លាំងកកិតដោយរមៀលមានអាំងតង់ស៊ីតេតូចជាងឬធំជាងកម្លាំងកកិតដោយរអិល?<br>. តើកម្លាំងកកិតដោយរអិលនៅពេលអង្គធាតុមានចលនាស្មើមានអាំងតង់ស៊ីតេតូចជាងឬធំជាងកម្លាំងកកិតនៅពេលអង្គធាតុនៅនឹងថ្កល់?</td>
<td>. កម្លាំងលើកអង្គធាតុតាមខ្សែឈរធំជាងកម្លាំងទាញ<br>អង្គធាតុតាមខ្សែដេកត្រង់ស្មើ<br>. ចំពោះអង្គធាតុតែមួយបើយើងប្ដូរផ្ទៃប៉ះនៃអង្គធាតុអាំងតង់ស៊ីតេកម្លាំងកកិតរបស់អង្គធាតុផ្លាស់ប្ដូរ<br>. កម្លាំងកកិតដោយរមៀលមានអាំងតង់ស៊ីតេធំជាងកម្លាំងកកិតដោយរអិល។<br>. កម្លាំងកកិតដោយរអិលនៅពេលអង្គធាតុមានចលនាស្មើមានអាំងតង់ស៊ីតេតូចជាងកម្លាំងកកិតនៅពេលអង្គធាតុនៅនឹងថ្កល់។</td>
<td>. កម្លាំងលើកអង្គធាតុតាមខ្សែឈរធំជាងកម្លាំងទាញអង្គធាតុតាមខ្សែដេកត្រង់ស្មើ។<br><br>. ផ្លាស់ប្ដូរ<br><br>. កម្លាំងកកិតដោយរមៀលមានអាំងតង់ស៊ីតេធំជាងកម្លាំងកកិតដោយរអិល។<br>. តូចជាង</td>
</tr>
<tr>
<td>. ឱ្យសិស្សទាញសន្និដ្ឋាន<br>. សូមសរសេរសេចក្ដីសន្និដ្ឋាននៅលើក្ដាខៀន។</td>
<td>សន្និដ្ឋាន<br>. កម្លាំងកកិតអាស្រ័យនឹងធម្មជាតិនៃផ្ទៃប៉ះ ទម្ងន់ និងប្រភេទនៃកកិត និងមិនអាស្រ័យនឹងទំហំនៃផ្ទៃប៉ះទេ។</td>
<td></td>
</tr>
</table>

| | | |
|---|---|---|
| . ឈើមួយដុំរាងប្រលេពីប៉ែតកែង ដំបូងអ្នកអូសវាដោយឱ្យខាងដែលធំខ្លាំងប៉ះនឹងផ្ទៃគ្រួចឱ្យផ្ទៃខាងដែលប៉ះផ្ទៃគ្រុ។ចូរអ្នកប្រៀបធៀបកម្លាំង ដែលបញ្ចោញក្នុងករណីនីមួយៗខាងលើ។<br><br>.ហេតុអ្វីបានជាអ្នកពាក់ស្បែកជើងមានកង់ គ្រាន់តែបញ្ចោញកំលាំងតូចល្មមអ្នកអាចផ្លាស់ទីលើទឹកកកបាន? | ជំហានទី៤(៥នាទី) ពង្រឹងចំណេះដឹង<br>ប្រៀបធៀបកម្លាំងកកិត | . កម្លាំងដែលបញ្ចោញក្នុងករណីដាក់ផ្ទៃខាងតូចឱ្យប៉ះនឹងផ្ទៃគ្រុតូចជាងករណីដាក់ផ្ទៃខាងធំឱ្យប៉ះនឹងផ្ទៃគ្រុ<br><br>. ព្រោះកម្លាំងកកិតដោយរមៀលតូចជាងកម្លាំងកកិតដោយរអិល។ |
| . តើកកិតមានប្រយោជន៍ឬទេ? ហេតុអ្វី.? | ជំហានទី៥(២នាទី)<br>កិច្ចការផ្ទះ<br>ដាក់សំនួរឱ្យសិស្សពិចារណានៅផ្ទះ។ | . កត់សំណួរយកទៅគិតនៅផ្ទះ។ |

# សន្លឹកកិច្ចការ

សំណួរគន្លឹះ ៖

សម្មតិកម្មៈ

---

---

ដំណើរការពិសោធៈ

១. ភ្ជាប់ឌីណាម៉ូម៉ែត្រ នឹងដុំឈើមួយដុំ រួចលើកវាតាមខ្សែឈរ។



២.ភ្ជាប់ឌីណាម៉ូម៉ែត្រ នឹងដុំឈើមួយដុំដដែល រួចទាញវាលើបន្ទះ



កញ្ចក់រាបស្មើលើប្លង់ដេក។ ដុំឈើមានចលនាស្មើ ពេលនោះឌីណាម៉ូម៉ែត្រចង្អុល។

៣.ភ្ជាប់ឌីណាម៉ូម៉ែត្រ នឹងដុំឈើមួយដុំដដែលរួចទាញវាលើបន្ទះក្ដារលើប្លង់ដេក។ នៅពេលដុំឈើមានចលនាស្មើយើង ឃើញឌីណាម៉ូម៉ែត្រចង្អុល.......N។



៤.ភ្ជាប់ឌីណាម៉ូម៉ែត្រ នឹងដុំឈើមួយដុំដដែលប៉ុន្តែប្តូរផ្ទៃប៉ះរបស់វាឱ្យតូចជាង



មុនរួចទាញលើបន្ទះក្ដារលើប្លង់ដេក។ នៅពេលដុំឥដ្ឋមានចលនាស្មើយើង

ឃើញឌីណាម៉ូម៉ែត្រចង្អុល.......N ។

5



៥.ភ្ជាប់ឌីណាម៉ូម៉ែត្រនឹងដុំឈើមួយដុំដដែលប៉ុន្តែកល់ខ្មៅដៃពីខាងក្រោម

រួចទាញលើបន្ទះក្ដារលើប្លង់ដេក។នៅពេលដុំឈើ មានចលនាស្មើ

យើងឃើញឌីណាម៉ូម៉ែត្រ។

6



៦.ភ្ជាប់ឌីណាម៉ូម៉ែត្រនឹងដុំឈើពីរដុំរួចទាញលើបន្ទះក្ដារលើប្លង់ដេក។

នៅពេលដុំឈើមានចលនាស្មើ យើងឃើញឌីណាម៉ូម៉ែត្រចង្អុល.......N។

វិភាគលទ្ធផលៈ

. តើកម្លាំងលើកអង្គធាតុតាមខ្សែឈរធំជាងឬតូចជាងកម្លាំងទាញអង្គធាតុតាមខ្សែដេកត្រង់ស្មើ?

. ចំពោះអង្គធាតុតែមួយបើយើងប្តូរផ្ទៃប៉ះនៃអង្គធាតុអាំងតង់ស៊ីតេកម្លាំងកកិតរបស់អង្គធាតុផ្លាស់ប្តូរឬទេ?

. តើកម្លាំងកកិតដោយរមៀលមានអាំងតង់ស៊ីតេតូចជាងឬធំជាងកម្លាំងកកិតដោយរអិល?

. តើកម្លាំងកកិតដោយរអិលនៅពេលអង្គធាតុមានចលនាស្មើមានអាំងតង់ស៊ីតេតូចជាងឬធំជាងកម្លាំងកកិតនៅពេលអង្គធាតុនៅនឹងថ្កល់?

សន្និដ្ឋានៈ

------------------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------------------

# ប្លង់ក្តារខៀន

សំណួរគន្លឹះ ៖

តើអាំងតង់ស៊ីតេកម្លាំងកកិតអាស្រ័យនឹងកត្តាអ្វីខ្លះ?

សម្មតិកម្ម ៖

កម្លាំងកកិតអាស្រ័យនឹងធម្មជាតិនៃផ្ទៃប៉ះ ទម្ងន់ និងប្រភេទនៃកកិត និងមិនអាស្រ័យនឹងទំហំនៃផ្ទៃប៉ះទេ ។

ពិសោធ ៖









5



6



ប្រមូលទិន្នន័យ ៖

| ពិសោធ | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |

. កម្លាំងលើកអង្គធាលុតាមខ្សែឈរធំជាងកម្លាំងទាញអង្គធាតុតាមខ្សែដេកត្រង់ស្មើ

. ចំពោះអង្គធាតុតែមួយបើយើងប្តូរផ្ទៃប៉ះនៃអង្គធាតុតើអាំងតង់ស៊ីតេកម្លាំងកកិតរបស់អង្គធាតុផ្លាស់ប្តូរ។

. កម្លាំងកកិតដោយរមៀលមានអាំងតង់ស៊ីតេធំជាងកម្លាំងកកិតដោយរអិល–កម្លាំងកកិតដោយរអិលនៅពេលអង្គធាតុមានចលនាស្មើមានអាំងតង់ស៊ីតេតូចជាងកម្លាំងកកិតនៅពេលអង្គធាតុនៅនឹងថ្កល់។

សន្និដ្ឋាន៖

. កម្លាំងកកិតអាស្រ័យនឹងធម្មជាតិនៃផ្ទៃប៉ះ ទម្ងន់ និងប្រភេទនៃកកិត និងមិនអាស្រ័យនឹងទំហំនៃផ្ទៃប៉ះទេ ។

លក្ខណវិនិច្ឆ័យលើការវាយតម្លៃ

| លក្ខណវិនិច្ឆ័យ | ពិន្ទុពីគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក | | | | យោបល់ពីគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| ទំនាក់ទំនងរវាគោលបំណងមេរៀន និងលទ្ធផលនៃអ្នកសិក្សា | | | | | ការបង្រៀនសម្រេចវត្ថុបំណងមេរៀនបាន ព្រោះតាមរយៈលទ្ធផលពិសោធសិស្សអាចទាញសេចក្តីសន្និដ្ឋានដែលឆ្លើយ និងសំណួរគន្លឹះ។<br>ពិសោធន៍មានភាពងាយស្រួលដែលសិស្សអាចអនុវត្តបាន។ |
| ដំណើរការនៃការរៀនមេរៀនវិទ្យាសាស្ត្រ | | | | | ពិសោធបានធ្វើឲ្យសិស្សមានបម្រុងប្រយ័ត្ន ក្នុងការប្រមូលទិន្នន័យដើម្បីវិភាគលទ្ធផល។ |
| ឱកាសនៃការសិក្សា | | | | | សិស្សគិតពីដំណើរពិសោធន៍ សម្ភារពិសោធន៍ដូចជាបន្ទះក្តារដុំឈើ ការភ្ជាប់ឌីណាម៉ូម៉ែត និងទាញ។<br>លំនាំបញ្ហាធ្វើឲ្យសិស្សគិតពីភាពរអិល ដែលទាក់ទង និង ការរិះគិត។ |

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ រូបវិទ្យា, ថ្នាក់ទី៧

២. ប្រធានបទ៖ ចរន្តអគ្គិសនី

៣. វត្ថុបំណង៖

- កំនត់ និងឲ្យនិយមន័យអង្គធាតុចម្លង និងអ៊ីសូឡង់អគ្គិសនីបានត្រឹមត្រូវតាមរយៈធ្វើពិសោធ។
- ញែកអង្គធាតុចម្លង និងអ៊ីសូឡង់អគ្គិសនីបានត្រឹមត្រូវតាមរយៈការធ្វើពិសោធ។
- មានបម្រុងប្រយ័ត្ននៅពេលប្រើប្រាស់ចរន្តអគ្គិសនី និងគ្រឿងអគ្គិសន្ទីផ្សេងៗ

៤. រយៈពេល៖ ៦០នាទី

៥.សម្ភារៈឧបទ្ទេស៖

- សៀវភៅសិស្សរូបវិទ្យាថ្នាក់ទី៧ (២០០៩)
- កំណាត់ឈើស្ងួត ទង់ដែង ដែក ខ្សែភ្លើង អំពូល ថ្មពិល ប្លាស្ទិច ជ័រលុប កាបូន ទឹងអំបិល។

| សកម្មភាព | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . គ្រូតពិនិត្យ អវត្តមាន សណ្តាប់ធ្នាប់ផ្សេងៗ។ | ជំហានទី១ (លំនឹងថ្នាក់) (៣នាទី) | . ប្រធានថ្នាក់ឡើងរាយការណ៍ និងត្រៀមចាប់ផ្តើមរៀន។ |
| . តើឧបករណ៍ដែលយើងប្រើប្រាស់រាល់ថ្ងៃដូចជា ទូរទស្សន៍ ម៉ាញ៉េ ទូទឹកកក ម៉ាស៊ីនត្រជាក់មានដំណើរការទៅបានដោយសារអ្វី?<br>. តើចរន្តអគ្គិសនីមានប្រភពមកពីណាខ្លះ? | ជំហានទី២ (រំលឹកមេរៀន) (៥នាទី) | . មានដំណើរការទៅបានដោយសារចរន្តអគ្គិសនី (ភ្លើង) ឬថាមពលអគ្គិសនី។<br>. ចរន្តអគ្គិសនីមានប្រភពមកពីថ្មពិល អាគុយ ឌីណាម៉ូ រោងចក្រអគ្គិសន្ទី ចរន្តទឹក ចរន្តខ្យល់។ |
| . តើខ្សែភ្លើងផ្សំឡើងអំពីអ្វីខ្លះ?<br>. តើគេយកជ័រទៅធ្វើអ្វី? និងទង់ដែង | ជំហានទី៣ (មេរៀនថ្មី) )(៣៥នាទី)<br>ក. បំផុសបញ្ហា<br><br>. គេយកជ័រធ្វើស្រោម និងទង់ដែងធ្វើបណ្តូលដើម្បីការពារកុំអោយឆក់។ | . ខ្សែភ្លើងផ្សំឡើងពីជ័រ នឹងទង់ដែង។ |

ទៅធ្វើអ្វី?
. តើអ្នកដឹងទេ តើមូលហេតុអ្វីបានជាគេចាំបាច់ធ្វើដូច្នោះ?
. ដូចនេះថ្ងៃនេះយើងចូលមេរៀនទី២ គឺចរន្តអគ្គិសនី
. ឥឡូវនេះខ្ញុំមានថ្មពិល២គ្រាប់ ខ្សែភ្លើង៣ខ្សែ និងអំពូល។ តើអ្នកទាំងអស់គ្នាត្រូវតដូចម្តេចដើម្បីឲ្យអំពូលនេះភ្លឺ?
. បើអ្នកគ្រូដកដង្កៀបនេះចេញ តើប្អូនគិតដូចម្តេច? ឬអ្នកគ្រូយកដង្កៀបទៅចាប់ខ្យល់? ចាប់អង្គធាតុផ្សេងៗទៀតដូចជាបំពង់បឺត ទឹក ....
តើប្អូនមានចម្លើយ ឬទេ?

មេរៀនទី២៖ ចរន្តអគ្គិសនី



ខ. សំណួរគន្លឹះ៖

. គេយកទង់ដែងទៅធ្វើបណ្តូល នឹងជ័រទៅធ្វើស្រោម។
. ដើម្បីការពារកុំឲ្យឆក់។
. សិស្សត និងពន្យល់ប្រាប់មិត្តភក្តិ



. សិស្សគិត និងឆ្លល់ថា តើអង្គធាតុខ្លះធ្វើឲ្យអំពូលភ្លឺ និងអង្គធាតុណាខ្លះធ្វើអោយអំពូលមិនភ្លឺ?

តើអង្គធាតុណាខ្លះធ្វើអោយអំពូលភ្លឺ និងអង្គធាតុណាខ្លះធ្វើអោយអំពូលមិនភ្លឺ?

. ចូរអ្នកទាំងអស់គ្នាសាកល្បងទស្សន៍ទាយទៅមើល? ហើយឡើងសរសេរលើក្តារខៀន?
. អោយសិស្សឡើងបង្ហាញប្លង់ពិសោធន៍ ហើយគ្រូធ្វើការវាយតម្លៃ ដើម្បី បូកសរុបប្លង់ពិសោធមួយដែលល្អ។
. អញ្ជើងសូមអ្នកទាំងអស់គ្នាយកឧបករណ៍ទាំងនេះទៅធ្វើពិសោធ (៧ នាទី)
. ពិសោធន៍រួចរាល់ហើយ សូមអ្នកទាំងអស់គ្នាយកឧបករណ៍ពិសោធន៍មកទុក និងឡើងកត់លទ្ធផលពិសោធន៍នៅលើក្តារខៀន។

គ. បង្កើតសម្មតិកម្ម

| អំពូលភ្លឺ | អំពូលមិនភ្លឺ |
|---|---|
| . កូនសោ | . បំពង់ទឹក |
| . របាស្តាន់ | . ឈើស្ងួត |
| . ទឹកអំបិល | . ប្លាស់ស្ទិច |
| . ឃ្នាបក្រដាស | . ជ័រលុប |
| . ទង់ដែង | . កាបូន |
| . ដែក | . សំណ....... |

ឃ. ពិសោធន៍
ប្លង់ពិសោធន៍



. យកកំណាត់ឈើស្ងួត ដែក ទង់ដែង ប្លាស់ស្ទិច ទឹកអំបិលទៅភ្ជាប់ និងដង្កៀប និងសាកល្បង ជាមួយ ឧបករណ៍ផ្សេងៗទៀតបាន។

. តំណាងក្រុមនីមួយៗ ឡើងសរសេរការទស្សន៍ទាយលើក្តារខៀន។

សិស្ស គិតប្លង់ពិសោធន៍



. សិស្សចាប់ផ្តើមធ្វើពិសោធ
. តំណាងក្រុមយកសម្ភារៈពិសោធន៍ទុក និងបង្ហាញលទ្ធផលលើក្តារខៀន។

<table>
<tr>
<td>. បើលទ្ធផលពិសោធន៍ដូចគ្នា ឬដូចក្រុមដទៃពុំចាំបាច់កត់ទេ តែបើខុសគ្នាសុំប្រាប់គ្រូ និងកត់ផ្សេងមួយទៀត។</td>
<td>ង. លទ្ធផលពិសោធ
<table>
<tr><th>អង្គធាតុ</th><th>ភ្លឺ</th><th>មិនភ្លឺ</th></tr>
<tr><td>ទង់ដែង</td><td>✓</td><td></td></tr>
<tr><td>ជ័រលុប</td><td></td><td>✓</td></tr>
<tr><td>កូនសោ</td><td>✓</td><td></td></tr>
<tr><td>របាស្គាន់</td><td>✓</td><td></td></tr>
<tr><td>បំពង់ទឹក</td><td></td><td>✓</td></tr>
<tr><td>គំរបប៊ិច</td><td></td><td>✓</td></tr>
<tr><td>កាបូន</td><td>✓</td><td></td></tr>
<tr><td>ឃ្នាប</td><td>✓</td><td></td></tr>
<tr><td>ទឹកអំបិល</td><td>✓</td><td></td></tr>
<tr><td>ឈើស្ងួត</td><td></td><td>✓</td></tr>
<tr><td>Al</td><td>✓</td><td></td></tr>
<tr><td>………</td><td>………</td><td>……….</td></tr>
</table>
</td>
<td>
<table>
<tr><th>អង្គធាតុ</th><th>ភ្លឺ</th><th>មិនភ្លឺ</th></tr>
<tr><td>ទង់ដែង</td><td>✓</td><td></td></tr>
<tr><td>ជ័រលុប</td><td></td><td>✓</td></tr>
<tr><td>កូនសោ</td><td>✓</td><td></td></tr>
<tr><td>របាស្គាន់</td><td>✓</td><td></td></tr>
<tr><td>បំពង់ទឹក</td><td></td><td>✓</td></tr>
<tr><td>គំរបប៊ិច</td><td></td><td>✓</td></tr>
<tr><td>កាបូន</td><td>✓</td><td></td></tr>
<tr><td>ឃ្នាប</td><td>✓</td><td></td></tr>
<tr><td>ទឹកអំបិល</td><td>✓</td><td></td></tr>
<tr><td>ឈើស្ងួត</td><td></td><td>✓</td></tr>
<tr><td>Al</td><td>✓</td><td></td></tr>
<tr><td>………</td><td>………</td><td>……….</td></tr>
</table>
</td>
</tr>
<tr>
<td>. សូមប្អូនទាំងអស់គ្នាសន្និដ្ឋានអោយឆ្លើងតបទៅនឹង សំណួររបស់យើង។<br>. ធ្វើការបូកសរុបចម្លើយរបស់សិស្ស និងប្រាប់ថាអង្គធាតុមិនចម្លងចរន្តអគ្គិសនីហៅថា អ៊ីសូឡង់អគ្គិសនី<br>. តើអ្វីទៅជាអង្គធាតុចម្លងចរន្តអគ្គិសនី?<br><br>. តើអ្វីទៅជាអ៊ីសូឡង់អគ្គិសនី?</td>
<td>ច. សន្និដ្ឋាន<br>. អង្គធាតុដែលធ្វើឲ្យអំពូលភ្លឺ គេហៅថា អង្គធាតុចម្លងអគ្គិសន្នី<br>. អង្គធាតុដែលធ្វើឲ្យអំពូលមិនភ្លឺ គេហៅថា អង្គធាតុមិនចម្លងអគ្គិសន្នី ឬ អ៊ីសូឡង់អគ្គិសន្នី។<br>. អង្គធាតុចម្លងអគ្គិសនីជាអង្គធាតុដែលអាចឲ្យចរន្តអគ្គិសនីឆ្លងកាត់បាន។<br>. អ៊ីសូឡង់អគ្គិសន្នីជាអង្គធាតុដែលមោនអាចអោយចរន្តអគ្គិសនីឆ្លងកាត់បាន។</td>
<td>. អង្គធាតុដែលធ្វើឲ្យអំពូលភ្លឺ គេហៅថា អង្គធាតុចម្លង។<br>. អង្គធាតុដែលធ្វើឲ្យអំពូលមិនភ្លឺ គេហៅថា អង្គធាតុមិនចម្លង។<br><br>. អង្គធាតុចម្លងចរន្តអគ្គិសនីជាអង្គធាតុដែលអាចអោយចរន្តអគ្គិសនីឆ្លងកាត់បាន។</td>
</tr>
<tr>
<td>.ដូចម្តេចដែលហៅថាអង្គធាតុចម្លងចរន្តអគ្គិសនី?<br><br>. ដូចម្តេចដែលហៅថាអ៊ីសូឡង់អគ្គិសនី?</td>
<td>ជំហានទី៤ (ពង្រឹងពុទ្ធិ) (៥នាទី)</td>
<td>. អង្គធាតុចម្លងចរន្តអគ្គិសនីជាអង្គធាតុដែលអាចឲ្យចរន្តអគ្គិសនីឆ្លងកាត់បាន។<br>. អ៊ីសូឡង់អគ្គិសន្នីជាអង្គធាតុដែលមោនអាចអោយចរន្តអគ្គិសនីឆ្លងកាត់បាន។</td>
</tr>
</table>

| | | |
|---|---|---|
| . តើអង្គធាតុចម្លងចរន្តអគ្គិសនី និងអ៊ីសូឡង់អគ្គិសនីត្រូវបានគេយកទៅប្រើប្រាស់ក្នុងឧបករណ៍ណាខ្លះ? | | . គេយកទៅប្រើប្រាស់ក្នុងឧបករណ៍អគ្គិសនី។ |
| . ចូរប្អូនកត់សំណួរខាងក្រោមនេះទុកស្រាវជ្រាវនៅផ្ទះ។<br>. ដូចម្តេចដែលហៅថាចរន្តអគ្គិសនី?<br>. តើចរន្តអគ្គិសនី និងបន្ទុកអគ្គិសនីខុសគ្នា និងដូចគ្នាយ៉ាងដូចម្តេចខ្លះ? | ជំហានទី៥(បណ្តាំផ្ញើ) (២នាទី) | សិស្សកត់ត្រាសំណួរទុកធ្វើនៅផ្ទះ។ |

# សន្លឹកកិច្ចការ

១. បំផុសបញ្ហា ៖





ខ្សែភ្លើងផ្សំឡើងពី ..................................................... ..................................................

២. សំណួរគន្លឹះ ៖

៣. បង្កើតសម្មតិកម្មៈ

- អង្គធាតុធ្វើឲ្យអំពូលភ្លឺមានៈ........................................................................................................................

- អង្គធាតុមិនធ្វើឲ្យអំពូលភ្លឺមានៈ...................................................................................................................

៤. ដំណើរការពិសោធន៍

- ប្លង់ពិសោធន៍

៥. លទ្ធផលពិសោធន៍

| អង្គធាតុ | ទង់ដែង | Al | របាស្ពាន់ | ស្លាបព្រា | បំពង់បឺត | គំរបប៊ិច | កាបូន | ទឹក | ឈើស្ងួត | ឃ្នាប |
|---|---|---|---|---|---|---|---|---|---|---|
| ភ្លឺ | | | | | | | | | | |
| មិនភ្លឺ | | | | | | | | | | |

តាមរយៈលទ្ធផលពិសោធន៍ ចូរឆ្លើយនឹងសំណួរគន្លឹះ

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

៦. សន្និដ្ឋាន

- តើអ្វីជាអង្គធាតុចម្លងអគ្គិសន្នី? ..........................................................................................................

- តើអ្វីជាអង្គធាតុមិនចម្លងអគ្គិសន្នី? ...................................................................................................

លក្ខណវិនិច្ឆ័យលើការវាយតម្លៃ

| លក្ខណវិនិច្ឆ័យ | ពិន្ទុពីគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក | | | | យោបល់ពីគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| ទំនាក់ទំនងរវាគោលបំណងមេរៀន និងលទ្ធផលនៃអ្នកសិក្សា | | | | | វត្ថុបំណងច្បាស់លាស់ ដែលធ្វើឲ្យសិស្សយល់ខ្លឹមសារមេរៀន និងការអនុវត្តជាក់ស្តែង។<br>សំណួរគន្លឹះងាយយល់<br>សម្ភារងាយៗ សម្រាប់ពិសោធន៍ |
| ដំណើរការនៃការរៀនមេរៀនវិទ្យាសាស្ត្រ | | | | | សិស្សរកឃើញពីសារប្រយោជន៍ នៃអង្គធាតុ និងអ៊ីសូឡង់អគ្គិសនីក្នុងការប្រើប្រាស់។<br>គ្រូប្រើប្រាស់សំណួរបានសមស្រប និងកម្រិតរបស់សិស្ស។ |
| ឱកាសនៃការសិក្សា | | | | | សិស្សគិតអំពីរបៀបពិសោធន៍ ដើម្បីញែកអង្គធាតុដែលធ្វើឲ្យអំពូលភ្លឺ និង មិនភ្លឺ។ |

## ២.២. គីមី

### ២.២.១ រំហួត

### ២.២.២ ទឹក

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ គីមី, ថ្នាក់ទី៨

២. ប្រធានបទ៖ រំហួត

៣. វត្ថុបំណង៖

- ប្រាប់ពីប្រភេទល្បាយដែលអាចញែកបានតាមវិធីរំហួតបានត្រឹមត្រូវតាមរយៈការពិសោធ។
- ជ្រើសរើសវិធីញែកល្បាយបានសមស្របនិងត្រឹមត្រូវទៅតាមប្រភេទល្បាយ។
- មានបម្រុងប្រយ័ត្នក្នុងពេលធ្វើពិសោធន៍។

៤. រយៈពេល៖ ៥០នាទី

៥.សម្ភារៈឧបទេ្ទស៖

- ចង្ក្រានហ្គាស បន្ទាសអាំងត្រី ចានអាលុយមីញ៉ូម កែវបេស៊ែ សីរ៉ាំង ទឹកអំបិល ទឹកស្ករ ស្រាស។

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| – ពិនិត្យអវត្តមាន<br>– ពិនិត្យអនាម័យ<br>– សំណេះសំណាល | ជំហានទី១៖ លំនឹងថ្នាក់<br>រដ្ឋបាលថ្នាក់រៀន | – សិស្សស្វាគមន៍ |
| – ដូចម្តេចដែលហៅថា<br>ល្បាយ?<br><br>– ដើម្បីញែកធាតុបង្កល្បាយ គេប្រើវិធីអ្វីខ្លះ? | ជំហានទី២៖ រំលឹកមេរៀន | – ល្បាយ៖ រូបធាតុដែលបង្កឡើងដោយសារធាតុពីរឬច្រើននៅលាយឡំគ្នាដោយមិនរងប្រតិកម្មគីមី។<br>– វិធីញែកល្បាយមាន៖<br>+ ចំរោះ<br>+ រំហួត<br>+ កំនក្រាម<br>+ បំនិត<br>+ ពណ៌វិធី រឺ ក្រូម៉ាតូក្រាភី |
| – គ្រូបង្ហាញ ការលាយទឹក និងអំបិល<br>, ទឹក និងស្ក, ទឹក និងស្រា។ | ជំហានទី២៖ មេរៀនថ្មី<br>មេរៀនទី៣៖ វិធីញែកល្បាយ<br>ប្រធានបទ៖ រំហួត | – សិស្សអង្កេត |

| | | |
|---|---|---|
| – តើល្បាយដែលទទួលបានជាប្រភេទល្បាយអ្វី? | ១. សេចក្តីផ្តើម<br><br>២.សំណួរគន្លឹះ | – ល្បាយស្មើសាច់ |
| ក្នុងចំណោមល្បាយស្មើសាច់ទាំងបី តើល្បាយណាដែលគេអាចញែកធាតុបង្កបានតាមវិធីរំហួត? | | |
| – ឲ្យសិស្សគិត និងសរសេរសម្មតិកម្មរបស់ គេលើក្តារខៀន<br><br>– គ្រូបង្ហាញសម្ភារសម្រាប់ពិសោធន៍ "ចូរធ្វើប្លង់ពិសោធន៍"<br><br>– ឲ្យសិស្សឡើងបង្ហាញប្លង់ពិសោធន៍<br><br>– តំណាងក្រុមឡើងយក សម្ភារពិសោធន៍<br>❋ហាមប៉ះពាល់សម្ភារក្នុងពេលកំពុងក្តៅ❋<br>– ដើរមើលតាមក្រុម និងជួយ ក្នុងករណីចាំបាច់<br>– ឲ្យសិស្សសរសេរលទ្ធផល ក្នុងតារាង តាមក្រុមនីមួយៗ<br>–សំយោគលទ្ធផលរបស់ សិស្ស<br>ផ្ទៀងផ្ទាត់សម្មតិកម្ម | ៣. សម្មតិកម្ម<br>– ទឹកអំបិល ប្រើវិធីរំហួតបាន<br>– ទឹកស្ករ និងទឹកស្រា មិនអាចប្រើវិធីរំហួតបានទេ។<br><br>៤. ប្លង់ពិសោធន៍<br><br>៥. ពិសោធន៍<br><br>៦. សន្និដ្ឋាន | + ទឹកអំបិល និងទឹកស្ករ អាចត្រូវបានញែកអង្គធាតុបង្ករបស់វាតាមវិធីរំហួតបាន ព្រោះវាផ្សំពីការរំលាយអង្គធាតុរឹងជាមួយទឹក តែទឹកស្រាមិនអាញែកតាមវិធីនេះបានទេ ព្រោះវាផ្សំឡើងតែពីអង្គធាតុរាវ។<br>+ ឬថា ល្បាយទាំងបីខាងលើអាចញែកធាតុបង្កបានដោយវិធីបង្ហួត។<br><br>– សិស្សគូសប្លង់ពិសោធន៍<br><br>– សិស្សឡើងបកស្រាយប្លង់<br><br>– តំណាងក្រុមឡើងយកសម្ភារ និងធ្វើពិសោធន៍<br><br>– កត់ត្រាលទ្ធផលចូលក្នុងតារាង<br>– ឡើងបង្ហាញលទ្ធផលពិសោធន៍របស់ក្រុមខ្លួន<br>– សិស្សឡើងសន្និដ្ឋាន |

ល្បាយទឹកអំបិលអាចញែកបានដោយវិធីរំហួត ព្រោះក្រោយពីរំហួតគេសង្កេតឃើញក្រាមអំបិលនៅសល់។ ចំណែកឯល្បាយទឹកស្ករ និងស្រា មិនអាចប្រើវិធីនេះទេ ព្រោះយើងមិនអាចទទួលបានស្ករ និងស្រាវិញទេ ក្រោយពេលរំហួត។ ដូច្នេះ វិធីរំហួតមិនសុទ្ធតែអាចត្រូវបានប្រើដើម្បីញែកល្បាយស្មើសាច់នោះទេ។

| | | |
|---|---|---|
| - ក្នុងចំណោមល្បាយ ខាងក្រោមនេះ តើល្បាយណាដែលអាចញែកធាតុបង្កបានដោយប្រើវិធីរំហួត?<br>ក. កូកាកូឡា<br>ខ. ទឹកត្រី<br>គ. ទឹកខ្មេះ<br>ឃ. ស្រាបៀ | ជំហានទី៤ (ពង្រឹងពុទ្ធិ) | - ឆ្លើយ "ខ" |
| + ពេលប្អូនត្រលប់ទៅផ្ទះវិញសូមឆ្លើយនិងសំណួរខាងក្រោម<br>"តើគេត្រូវធ្វើដូចម្តេច ដើម្បីញែកយកស្ករស ចេញពីទឹកស្ករ" | ជំហានទី៥ (កិច្ចការផ្ទះ) | - កត់ត្រាកិច្ចការផ្ទះ |

# សន្លឹកកិច្ចការ

សង្កេត ៖ បង្ហាញសិស្សពីការលាយទឹកអំបិល ទឹកស្ករ និងស្រា

តើល្បាយដែលទទួលបានជាប្រភេទល្បាយអ្វី?

______________________________

______________________________

**សំណួរគន្លឹះ**

| |
|---|
| |

សម្មតិកម្ម ៖ ចូរសរសេរចម្លើយព្រាងទុករបស់អ្នកៈ

១) រំហួតអាចប្រើដើម្បីញែកល្បាយ.

..............................................................................

ពីព្រោះ. ..............................................................

២) រំហួតអាចប្រើដើម្បីញែកល្បាយ

..............................................................................

ពីព្រោះ...............................................................

**ប្លង់ពិសោធន៍ៈ** ចូររៀបប្លង់ពិសោធន៍ និងគូររូបដើម្បីបញ្ជាក់នូវចម្លើយរបស់អ្នក។

| |
|---|
| |

| |
|---|
| ចូរធ្វើពិសោធន៍ដើម្បីបញ្ជាក់ការព្រាងទុករបស់អ្នក |

*បម្រុងប្រយ័ត្នៈ កុំប៉ះពាល់សម្ភារដែលកំពុងក្ដៅ ព្រោះវាបណ្ដាលឲ្យរលាក*

**លទ្ធផលពិសោធន៍ៈ**

| ល្បាយ | លទ្ធផល |
|---|---|
| ទឹកអំបិល | |
| ទឹកស្ក | |
| ស្រា | |

**សន្និដ្ឋានៈ**

ល្បាយ______________អាចញែកបានដោយវិធីរំហួត ព្រោះ ______

_____________________________________________។

ចំណែកឯល្បាយ________________________________ មិនអាចប្រើវិធីនេះ

ទេ ព្រោះ__________________________________________________

__________________________________________________________

___________________ ។ ដូច្នេះវិធីរំហួតមិនសុទ្ធតែ_________________

___________________ល្បាយស្មើសាច់នោះទេ។

# ប្លង់ក្ការខៀន

សង្កេត ៖

បង្ហាញសិស្សពីការលាយទឹកអំបិល ទឹកស្ករ និងស្រាតើល្បាយដែលទទួលបាន ជាប្រភេទល្បាយអ្វី?

ល្បាយស្មើសាច់ .........................................................................................

**សំណួរគន្លឹះ ៖**

| |
|---|
| ក្នុងចំណោមល្បាយស្មើសាច់ទាំងបី តើល្បាយណាដែលគេអាចញែកធាតុបង្ក របស់វាតាមវិធីរំហួត? |

**សម្មតិកម្ម ៖** ចូរសរសេរចម្លើយព្រាងទុករបស់អ្នកៈ

+ ទឹកអំបិល និងទឹកស្ក អាចត្រូវបាន ញែកអង្គធាតុបង្ករបស់វាតាមវិធីរំហួត បាន ព្រោះវាផ្សំពីការរំលាយអង្គធាតុរឹងជាមួយទឹក តែទឹកស្រាមិនអាញែកតាម វិធីនេះបានទេ ព្រោះវាផ្សំឡើងតែពីអង្គធាតុរាវ។

+ ឬថា ល្បាយទាំងបីខាងលើអាចញែកធាតុបង្កបានដោយវិធីបង្ហូត។

**ប្លង់ពិសោធន៍ៈ** ចូររៀបប្លង់ពិសោធន៍ និងគូរូបដើម្បីបញ្ជាក់នូវចម្លើយព្រាងទុក របស់អ្នក។



| |
|---|
| ចូរធ្វើពិសោធន៍ដើម្បីបញ្ជាក់ការព្រាងទុករបស់អ្នក |

**លទ្ធផលពិសោធន៍ៈ**

| សូលុយស្យុង | លទ្ធផល |
|---|---|
| ទឹកអំបិល | មានក្រាមអំបិលក្រោយរំហួត |
| ទឹកស្ក | មានផ្សុងកាបូនក្រោយរំហួត |
| ស្រា | មានក្លិនពេលរំហួត និងគ្មានអ្វីក្រោយពេលរំហួត |

**សន្និដ្ឋានៈ**

| |
|---|
| ល្បាយទឹកអំបិលអាចញែកបានដោយវិធីរំហួត ព្រោះក្រោយពីរំហួតគេសង្កេតឃើញក្រាមអំបិលនៅសល់។ ចំណែកឯល្បាយទឹកស្ករ និងស្រា មិនអាចប្រើវិធីនេះទេ ព្រោះយើងមិនអាចទទួលបានស្ករ និងស្រាវិញទេក្រោយពេលរំហួត។ ដូច្នេះ វិធីរំហួតមិនសុទ្ធតែអាចត្រូវបានប្រើដើម្បីញែកល្បាយស្មើសាច់នោះទេ។ |

លក្ខណវិនិច្ឆ័យទៅលើការវាយតម្លៃ

| លក្ខណវិនិច្ឆ័យ | ពិន្ទុពីគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក | | | | យោបល់ពីគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| ទំនាក់ទំនងរវាគោលបំណងមេរៀន និងលទ្ធផលនៃអ្នកសិក្សា | | | | | វត្ថុបំណងមិនសូវច្បាស់ទេ តែយើងអាចកែលម្អឲ្យបានសមស្របទៅនឹងខ្លឹមសារមេរៀនជាងនេះ។ |
| ដំណើរការនៃការរៀនមេរៀនវិទ្យាសាស្ត្រ | | | | | សំណួរគន្លឹះពិបាកយល់ និងសម្ភារដែលប្រើមិនងាយស្រួល តែយើងអាចកែលម្អបានឲ្យសមស្របសម្រាប់សិស្ស។ |
| ឱកាសនៃការសិក្សា | | | | | សិស្សមានការយល់ច្រឡំចំពោះការរកឃើញរបស់គេ ព្រោះលំនាំនៃការរៀបរបស់ពួកគេហាក់ដូចជាមានភាពសាំញ៉ាំ។ |

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ គីមី, ថ្នាក់ទី៨

២. ប្រធានបទ៖ ទឹក

៣. វត្ថុបំណង៖

- ប្រាប់ពីភាពរូបទាំងបីរបស់ទឹកនៅលើផែនដី បានត្រឹមត្រូវ តាមរយៈការសង្កេតលំនាំពិសោធន៍។
- ពន្យល់និងគូសកំនូងតាងពីវដ្តរបស់ទឹកនៅលើផែនដី បានត្រឹមត្រូវតាមរយៈយោបល់របស់ក្រុម។
- បណ្តុះស្មារតីដល់ឲ្យជួយសន្សំសំចៃក្នុងបម្រើបម្រាស់ទឹកលើផែនដី។

៤. រយៈពេល៖ ៦០នាទី

៥.សម្ភារៈឧបទ្ទេស៖

- កំសៀវទឹក ទុយោ ចង្ក្រានហ្គាស កំប៉ុងហ្គាស កែវទឹក ផ្ទាំងប្លង់ពិសោធ បំពង់សាក ទឹកកក ទឹក អំបិល។

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យវត្តមាន និង អនាម័យថ្នាក់ | ជំហានទី១ (២នាទី)<br>រដ្ឋបាលថ្នាក់ និង លំនឹងថ្នាក់រៀន | ប្រធានថ្នាក់ រាយការណ៍ពីវត្តមាន និងអវត្តមាន |
| – រូបធាតុទាំងអស់ស្ថិតក្នុងភាពរូបប៉ុន្មានយ៉ាង អ្វីខ្លះ?<br>– តើសារធាតុអ្វី ដែលភាវរស់ត្រូវការដូចគ្នា និងចាំ បាច់ | ជំហានទី ២ (៥នាទី)<br>រំលឹកមេរៀនចាស់<br>– ភាពរូបនៃរូបធាតុ | –៣ យ៉ាង គឺ រឹង រាវ និង ឧស្ម័ន (ចម្លើយជាបុគ្គល)<br>–គឺទឹក (ចម្លើយជាបុគ្គល) |

| | | |
|---|---|---|
| មិនអាចអត់បាន ។<br>**លំនាំបញ្ហា**<br>ឲ្យសិស្សសង្កេតផ្ទៃខាងក្រៅនៃកែវទឹកកក ។<br>-តើទឹកនៅលើផែនដីមាននៅទីណាខ្លះ?<br>-ចែកសន្លឹកកិច្ចការឲ្យសិស្ស<br><br>**សំណួរគន្លឹះ** | ជំហានទី៣មេរៀនប្រចាំថ្ងៃ (៣៥ នាទី)<br><br>មេរៀនទី១ទឹក (ត)<br>**២-វដ្តនៃទឹកនៅលើផែនដី** | -ទឹកមាននៅលើដី ក្នុងដី ក្នុងភាវរស់ និងក្នុងបរិយាកាស |

**តើទឹកនៅលើផែនដី មានការប្រែប្រួលភាពរូបដូចម្ដេច ?**

| | | |
|---|---|---|
| **សម្មតិកម្ម**<br>យើងមានអំណះអំណាងយ៉ាងណាដើម្បីបញ្ជាក់ថាវាប្រែប្រួល ៖<br>- ពីរាវទៅឧស្ម័ន<br>- ពីឧស្ម័នទៅរាវ<br>- ពីរាវ ទៅអង្គធាតុរឹង<br>**រៀបចំប្លង់ពិសោធ និង ពិសោធន៍**<br>- បង្ហាញដំណើរការពិសោធដល់សិស្ស | សោធទី១ ( បំលែងភាពរូបរបស់ទឹក )<br> | -ពីរាវទៅឧស្ម័ន<br>-ពីឧស្ម័នទៅរាវ<br>-ពីរាវ ទៅអង្គធាតុរឹង<br>-សង្កេតការពន្យល់ និងការណែនាំអំពីដំណើរ ពិសោធ (ការងារក្រុម)<br><br>-សង្កេត និង ដំណើរការពិសោធន៍ ប្រមូលគំនិតរបស់សមាជិកក្រុមសរសេរចូលក្នុង តារាង |

<table>
<tr>
<td>– តាមលំនាំពិសោធន៍នេះតើទឹកនៅក្នុងភពផែនដី ស្ថិតក្នុងភាពរូបអ្វីខ្លះ ? ចូរសរសេរ ក្នុងតារាង</td>
<td>
<table>
<tr><td colspan="2">ភាពរូបរបស់ទឹក</td><td></td></tr>
<tr><td>ពេលរំពុះ</td><td>ជាឧស្ម័ន</td><td></td></tr>
<tr><td>ពេលចុះត្រជាក់</td><td>ជាអង្គធាតុរាវ</td><td></td></tr>
<tr><td>ពេលចុះត្រជាក់ខ្លាំង</td><td>ជាអង្គធាតុរឹង</td><td></td></tr>
</table>
</td>
<td>– ក្រុមសិស្សរៀបរាប់ដំណើរវិវត្តរបស់ទឹក ។</td>
</tr>
<tr>
<td><u>សន្និដ្ឋាន</u><br>– ជាទូទៅនៅវាលស្រែនារដូវវស្សាតែងតែមានទឹក ឯនៅរដូវប្រាំងវាគ្មានទឹកទេ<br>តើទឹកនោះវាបាត់បង់ទៅណា ?</td>
<td><u>វដ្តរបស់ទឹក</u><br>ទឹកលើផែនដីពេលត្រូវកំដៅមួយចំនួនបានប្លែង ទៅក្នុងអាកាស ជាចំហាយទឹក ចំហាយទាំងនោះផ្តុំគ្នា បង្កើតជាពពក ពពកទាំងនោះបានកំណជាតំណក់ទឹកភ្លៀងកាលណាវាចុះត្រជាក់ហើយធ្លាក់មកលើផែនដីវិញ។<br>–នៅតំបន់ខ្លះនៃផែនដីដែលមានអាកាសធាតុត្រជាក់ខ្លាំង ទឹកនឹងកកក្លាយទៅជាអង្គធាតុរឹង យើងហៅថាទឹកកក។<br>ឧទាហរណ៍ នៅតំបន់ប៉ូលជាដើម ។</td>
<td>– ក្រុមសិស្សគូសគំនូសបំពេញវដ្តនៃទឹក</td>
</tr>
<tr>
<td>–ចូរប្អូនគូសគំនូសបំពេញប្រាប់ពីដំណើរវិវត្តរបស់ទឹក។</td>
<td></td>
<td></td>
</tr>
</table>

| | | |
|---|---|---|
| - តើនៅលើផែនដីទឹកស្ថិតក្នុងភាពរូប ប៉ុន្មានយ៉ាង? អ្វីខ្លះ?<br>- តើកត្តាអ្វីដែលធ្វើឲ្យទឹកមានការប្រែប្រួល ភាពរូប?<br><br>- ចូររៀបរាប់អំពីវដ្តនៃទឹកក្នុងធម្មជាតិ។ | ជំហានទី៤ (៣នាទី)<br>ពង្រឹងចំណេះដឹង | - នៅលើផែនដីទឹកស្ថិតក្នុងភាពរូប៣យ៉ាង គឺរឹង រាវ និង ឧស្ម័ន ។<br>- ការប្រែប្រួលសីតុណ្ហភាពធ្វើឲ្យទឹកនៅលើផែនដី មាន ការប្រែប្រួលភាពរូប<br>- ទឹកនៅលើផែនដី ហួតដោយកំដៅទៅក្នុង បរិយាកាស ហើយបង្គជាពពក រួចក្លាយជាភ្លៀង ធ្លាក់មកលើផែនដី វិញ ។ |
| - តើពពកជាអ្វី?<br>- ហេតុអ្វីបានជាមានភ្លៀង? | ជំហានទី៥ (២នាទី)<br>កិច្ចការផ្ទះ | - សិស្សកត់សំណួរ |

# សន្លឹកកិច្ចការ

សង្កេត៖

តើទឹកនៅលើផែនដីមាននៅទីណាខ្លះ?

------------------------------------------------------------

------------------------------------------------------------

សង្កេតការដាំទឹក៖

------------------------------------------------------------

------------------------------------------------------------

សំណួរគន្លឹះ៖

សម្មតិកម្ម៖

------------------------------------------------------------

------------------------------------------------------------

ប្លង់ពិសោធន៍៖

លទ្ធផលពិសោធ៖

| ភាពរូបរបស់ទឹក | |
|---|---|
| ពេលរំពុះ | |
| ពេលចុះត្រជាក់ | |
| ពេលចុះត្រជាក់ខ្លាំង | |

គូសវដ្តនៃទឹក៖

សន្និដ្ឋាន៖

# ប្លង់ក្តារខៀន

តើទឹកនៅលើផែនដីមាននៅទីណាខ្លះ?(បង្ហាញពីទឹកក្នុងខ្យល់)



សង្កេតការដាំទឹក

-បើយើងបន្តដាំទឹកក្នុងកំសៀវ តើយើងនឹងបានអ្វី ?

---------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------

សំណួរគន្លឹះ៖

**តេទឹកនៅលើផែនដី មានការប្រែប្រួលភាពរូបដូចម្តេច** ?

<u>សម្មតិកម្ម</u>

ទឹកនៅលើផែនដី មានការប្រែប្រួល៖

–ពីរាវទៅឧស្ម័ន

–ពីឧស្ម័នទៅរាវ

–ពីរាវ ទៅអង្គធាតុរឹង

<u>ប្លង់ពិសោធន៍ និង លទ្ធផលពិសោធ</u>



| ភាពរូបរបស់ទឹក | |
|---|---|
| ពេលរំពុះ | ជាឧស្ម័ន |
| ពេលចុះត្រជាក់ | ជាអង្គធាតុរាវ |
| ពេលចុះត្រជាក់ខ្លាំង | ជាអង្គធាតុរឹង |

សន្និដ្ឋាន៖

–ទឹកលើផែនដីពេលត្រូវកំដៅមួយចំនួនបានប្លែង ទៅក្នុងអាកាស ជាចំហាយទឹក ចំហាយទាំងនោះផ្តុំគ្នាបង្កើតជាពពក ។ ពពកទាំងនោះបានកំណជាតំណត់ទឹកភ្លៀង វិញកាលណាវាចុះត្រជាក់ ហើយធ្លាក់មកលើផែនដី ។

-នៅតំបន់ខ្លះនៃផែនដីដែលមានអាកាសធាតុត្រជាក់ ខ្លាំង ទឹកនឹងកកក្លាយទៅជាអង្គធាតុរឹង ដែលហៅថាទឹកកក ។

គូសវដ្តទឹក៖



លក្ខណវិនិច្ឆ័យទៅលើការវាយតម្លៃ

| លក្ខណវិនិច្ឆ័យ | ពិន្ទុពីគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក | | | | យោបល់ពីគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| ទំនាក់ទំនងរវាគោលបំណងមេរៀន និងលទ្ធផលនៃអ្នកសិក្សា | | | | | វត្ថុបំណងមិនសម្រេចបានពេញលេញទេ ដោយសារតែគ្រូបញ្ចូលនូវសកម្មភាព និងខ្លឹមសារច្រើនពេក ហើយសកម្មភាព និងខ្លឹមសារទាំងនោះហាក់ដូចជាមិនមានទំនាក់ទំនងគ្នាល្អទៀតផង។ |
| ដំណើរការនៃការរៀនមេរៀនវិទ្យាសាស្ត្រ | | | | | មានសកម្មភាពច្រើនពេក។ ដូច្នេះ គួរតែកាត់សកម្មភាពទាំងនោះចោលពាក់កណ្តាលចេញ រួចផ្តោតតែទៅលើវដ្តនៃទឹកតែមួយបានហើយ។ |
| ឱកាសនៃការសិក្សា | | | | | វាអាចធ្វើឲ្យសិស្សយល់ច្រឡំ ដោយសារសកម្មភាពពុំមានទំនាក់ទំនងគ្នារលូនពីមួយទៅមួយ។ |

## ២.៣. ជីវវិទ្យា

### ២.៣.១ ឥទ្ធិពលគ្រឿងញៀនទៅលើសត្វ

### ២.៣.២ ការឆ្លងពីសត្វទៅមនុស្ស

# កិច្ចតែងការបង្រៀន

**១. មុខវិជ្ជា៖ ជីវវិទ្យា, ថ្នាក់ទី៩**

**២. ប្រធានបទ៖ ឥទ្ធិពលគ្រឿងញៀនទៅលើសត្វ**

៣. វត្ថុបំណង៖

- រៀបរាប់ពីសារធាតុក្នុងបារី មានឥទ្ធិពលលើសត្វបានត្រឹមត្រូវ តាមរយៈសំណួរបំផុស
- បកស្រាយពីសារធាតុពុលក្នុងបារីបានច្បាស់លាស់តាមរយៈការពិសោធន៍
- ថែរក្សាសុខភាពបានល្អដោយមិនប្រើគ្រឿងញៀន(មិនជក់បារី)

**៤. រយៈពេល៖ ៥០នាទី**

**៥.សម្ភារៈឧបទ្ទេស៖**

- ត្រីក្រឹមរស់ បារី ចានជ័រធំ ឬកែវជ័រ។

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពង្រឹងវិន័យ និងត្រួតពិនិត្យសណ្តាប់ធ្នាប់ វត្តមាន អវត្តមាន | ជំហានទី១<br>រដ្ឋបាលថ្នាក់ | សិស្សរាយការណ៍ |
| – អ្វីទៅជាថ្នាំ ?<br><br>– ថ្នាំបែងចែកជាប៉ុន្មានប្រភេទ ? អ្វីខ្លះ ?<br>– ថ្នាំស្របច្បាប់មានអ្វីខ្លះ ?<br><br>– អញ្ចឹងក្នុងចំណោមថ្នាំស្របច្បាប់ បារីក៏ជាថ្នាំស្របច្បាប់<br>ដែរ ដូចនេះយើងគួរជក់បារី ទាំងអស់គ្នាទេ ?<br>– ហេតុអ្វីបានជាមិនគួរជក់បារី ? | ជំហានទី២<br>រំលឹកមេរៀន<br>– ជាសារធាតុគីមីដែលកាលណាយើងស្រូបវាចូលក្នុងសារពាង្គកាយវាធ្វើឲ្យមានការបម្រែបម្រួលក្នុងខ្លួន ។<br>– មានថ្នាំស្របច្បាប់ និងថ្នាំដែលមិនស្របច្បាប់។<br>– ឱសថ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ស្រា បារី<br>– មិនគួរជក់បារីទេ<br><br>– មានសារធាតុពុលជាច្រើនក្នុងនោះមានជាតិនីកូទីនជាជាតិញៀន ជ័រថា CO ។ | –ជាសារធាតុគីមីដែលគេផ្សំសម្រាប់ប្រឆាំងទប់ទល់នឹងមេរោគ ។<br><br>–ពីរប្រភេទ : ស្របច្បាប់ និងមិនស្របច្បាប់<br>–ឱសថ ស្រា បារី ជាដើម<br><br>–មិនជក់ទេ<br><br>–មានជាតិពុលច្រើនប្រភេទ ដូចជា ជ័រថា CO នីកូទីនជាដើម ។ |

| | | |
|---|---|---|
| - សំនួរបំផុស<br>ប្អូនធ្លាប់ឃើញចាស់ៗនៅតាមផ្ទះគាត់ចិញ្ចឹមសត្វ ហើយសត្វនោះមានដំបៅ គាត់យក ថ្នាំជក់ ទៅបិទលើដំបៅ ដែលមានដង្កូវ  ពេលនោះ តើសង្កេតឃើញដង្កូវនោះយ៉ាងដូចម្តេច? | ជំហានទី៣<br>មេរៀនប្រចាំថ្ងៃ « **ថ្នាំ** »<br>**២- គ្រឿងញៀន**<br>**"ឥទ្ធិពលគ្រឿងញៀនទៅលើ សត្វ "**<br>- ពេលបិទថ្នាំដង្កូវជ្រុះចេញពីដំបៅ។<br>១-សំណួរគន្លឹះ : | - ដង្កូវជ្រុះ |
| **តើសារធាតុក្នុងបារីមានឥទ្ធិពលលើសត្វយ៉ាងដូចម្តេច?** | | |
| យើងមានកែវ២គឺកែវ Aទឹកធម្មតា ឯកែវBទឹកបារី រួចដាក់ត្រីចូលក្នុងកែវទាំងពីរ។<br>ចូរសង្កេតមើល  តើត្រីក្នុងកែវទាំងពីរមានលក្ខណៈយ៉ាងដូចម្តេច ?<br>- ដើម្បីឲ្យដឹងច្បាស់ថាក្នុងបារីមានសារធាតុធ្វើឲ្យប៉ះពាល់ ដល់សុខភាពមនុស្ស ឬសត្វ ដូច្នេះតើយើងត្រូវធ្វើដូចម្តេច?<br>- ចែកសិស្សជាក្រុម<br>- ណែនាំសិស្សឲ្យអានដំណើរការពិសោធន៍ក្នុងសន្លឹកកិច្ចការ<br>- បញ្ជាក់បន្ថែមពេលសិស្សមិនច្បាស់<br>- ដើរមើលសកម្មភាពសិស្សតាមក្រុម។ | **២-សម្មតិកម្ម** :<br><br>**៣-ពិសោធន៍** :<br>- សម្ភារៈត្រីក្រឹមរស់ បារី កែវជ័រ ឬចានជ័រ ។<br>- ដំណើរការពិសោធន៍ :<br>1- បកបារីយកថ្នាំជក់៦ដើម លាយទឹក ៥០០ ml កូរឲ្យសព្វ រួចទុក ២០ នាទី ។<br>2- យកកែវជ័រមួយ(កែវ A) ចាក់ ទឹកធម្មតាកន្លះកែវ ដាក់ត្រីចូលក្នុងកែវនោះ។<br>3- យកកែវមួយទៀត(កែវ B) ចាក់ទឹកថ្នាំជក់កន្លះកែវបន្ទាប់មកដាក់ត្រីចូលក្នុងកែវនោះ ហើយទុករយៈពេល ១០នាទី រួចសង្កេតមើល។ | សិស្សសង្កេត គិតរួចឆ្លើយ<br>- ត្រីនៅក្នុងកែវAនៅរស់<br>- ត្រីនៅក្នុងកែវBសន្លប់ ឬងាប់<br>- យើងត្រូវធ្វើពិសោធន៍<br>-សិស្សចូលតាមក្រុម និងអានដំណើរការពិសោធន៍ក្នុងសន្លឹកកិច្ចការ រួចធ្វើពិសោធន៍។ |

| | | |
|---|---|---|
| ចូរសង្កេតមើលត្រីក្នុងកែវទាំងពីររួច ធ្វើការផ្ទៀងផ្ទាត់លទ្ធផលពិសោធន៍ ដែលទទួលបាន ទៅនឹងសម្មតិកម្ម របស់អ្នក ។<br>តើត្រីនៅក្នុងកែវទាំងពីរមានសភាព ខុសគ្នាយ៉ាងដូចម្តេច ?<br><br>- តាមរយៈលទ្ធផលខាងលើ ចូរទាញសេចក្តីសន្និដ្ឋាន :<br>- គ្រូសម្របសម្រួល និងសំយោគ ចម្លើយក្រុមសិស្ស។ | **៤-លទ្ធផល** :<br><br>**៥-សន្និដ្ឋាន** :<br>ត្រីដែលនៅក្នុងកែវទឹកដែលមាន សារធាតុក្នុងបារីវានឹងពុលអាចស្លាប់ ឬ សន្លប់មិនសូវមានសកម្មភាពទេ ។ ដូច្នេះសារធាតុក្នុងបារីពិតជាមានឥទ្ធិពលទៅលើសត្វ ឬមនុស្សមែន ។ | សិស្សសង្កេត :<br><br>សេចក្តីសន្និដ្ឋាន :<br>- ត្រីក្នុងកែវទឹកថ្នាំជក់ មិនសូវមាន សកម្មភាព ឬសន្លប់ ឬអាចស្លាប់។<br>- ត្រីក្នុងកែវទឹកធម្មតាមានសភាព ហែលលេងធម្មតា។ |
| - តើបារីគ្រប់ប្រភេទទាំងអស់មាន សារធាតុពុលដែរ ឬទេ ? | ជំហានទី៤<br>មានជាតិពុលនៅគ្រប់ប្រភេទបារី ទោះជាមានឬ គ្មានតម្រងស្នោក៏ដោយ ។ | - សិស្សគិតហើយឆ្លើយ មានជាតិពុលនៅគ្រប់ប្រភេទបារីទាំងអស់ ។ |
| - ចូរប្អូនធ្វើពិសោធន៍នេះដដែល ដោយយកបារីថ្នាំខ្លាំងដែលគ្មាន តម្រងម្តងទៀត តើលទ្ធផលដូចគ្នា ឬទេ ?<br>- សូមជៀសវាងកុំប្រើគ្រឿងញៀនរួមមាន៖<br>បារីជាដើមដើម្បីកុំឲ្យខូចសុខភាព ។ | ជំហានទី៥<br>កិច្ចការផ្ទះ | - សិស្សកត់ត្រា :<br><br>- សិស្សអនុវត្តន៍តាម : |

# សន្លឹកកិច្ចការ

១. សំណួរគន្លឹះ ៖

| តើសារធាតុនៅក្នុងបារីមានឥទ្ធិពលទៅលើសត្វយ៉ាងដូចម្ដេច? |
|---|

២. សម្មតិកម្មៈ



កែវ A (ទឹកធម្មតា) ..........................................................................

កែវ B (ទឹកថ្នាំជក់) .......................................................................

៣. ដំណើរការពិសោធ

- បកបារីយកថ្នាំជក់៦ដើមលាយទឹក៥០០ml កូរឲ្យសព្វរួចទុក រយៈពេល២០នាទី
- យកកែវជ័រ (A) ចាក់ទឹកធម្មតាកន្លះកែវ។ រួចដាក់ត្រីចូលក្នុង កែវនោះ។
- យកកែវជ័រមួយទៀត(B) ចាក់ទឹកថ្នាំជក់កន្លះកែវ។ បន្ទាប់មកដាក់ត្រីចូលក្នុងនោះ។
- សង្កេតពីលក្ខណៈ និងសកម្មភាពរបស់ត្រីក្នុងរយៈពេល៣នាទីម្ដង ហើយបំពេញ លទ្ធផលក្នុងតារាងខាងក្រោម។

៤. លទ្ធផលៈ

សូមបំពេញលទ្ធផលសង្កេតក្នុងតារាង

| រយៈពេលបន្ទាប់ពីដាក់ត្រីចូល | លក្ខណៈ និងសកម្មភាពត្រី | | | |
|---|---|---|---|---|
| | ៣នាទីក្រោយ | ៦នាទីក្រោយ | ៩នាទីក្រោយ | ១២នាទីក្រោយ |
| កែវ A (ទឹកធម្មតា) | | | | |
| កែវ B (ទឹកថ្នាំជក់) | | | | |

៥. សន្និដ្ឋានៈ

ចូរទាញសេចក្ដីសន្និដ្ឋានតាមរយៈលទ្ធផលពិសោធន៍របស់អ្នកៈ

លក្ខណវិនិច្ឆ័យទៅលើការវាយតម្លៃ

| លក្ខណៈវិនិច្ឆ័យ | ពិន្ទុផ្ដល់ដោយ គ្រូឧទ្ទេសថ្នាក់ជាតិ | | | | យោបល់របស់គ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| ទំនាក់ទំនងរវាគោលបំណងមេរៀន និងលទ្ធផលនៃអ្នកសិក្សា | | | | | វត្ថុបំណងច្បាស់ តែតាមរយៈសម្មភាព នៅក្នុងមេរៀននេះបង្ហាញតែពីឥទ្ធិពល របស់បារីលើសុខភាពមនុស្ស និងសត្វ តែប៉ុណ្ណោះ។ យើងមិនអាចកំណត់ពីប្រភេទនៃសារធាតុពុល (នីកូទីន) បានទេនៅក្នុងពិសោធនេះ។ |
| ដំណើរការនៃការរៀនមេរៀនវិទ្យាសាស្រ្ត | | | | | អនុវត្តតាមលំនាំវិទ្យាសាស្រ្ត ហើយសិស្សរៀនដោយធ្វើសកម្មភាព (ពិសោធ) ដើម្បីបង្ហាញពីឥទ្ធិពលរបស់បារីលើសុខភាពមនុស្ស និងសត្វ។ |
| ឱកាសនៃការសិក្សា | | | | | សិស្សមានឱកាសគិតពីឥទ្ធិពលរបស់ បារីលើសុខភាពប៉ុន្តែសកម្មភាពគិត និងធ្វើសកម្មភាពនៅមានកំរិត។ |

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ ជីវវិទ្យា, ថ្នាក់ទី៩

២. ប្រធានបទ៖ ផ្តាសាយបក្សី (ការឆ្លងពីសត្វទៅមនុស្ស)

៣. វត្ថុបំណង៖

- រៀបរាប់បានត្រឹមត្រូវពីការឆ្លងជំងឺផ្តាសាយបក្សីតាមរយៈសំណួរបំផុស។
- វិភាគបានល្អិតល្អន់ពីមូលហេតុនៃការឆ្លងជំងឺផ្តាសាយបក្សីពីសត្វទៅមនុស្ស តាមរយៈរូបភាព និងពិភាក្សាតាមក្រុម
- មានអនាម័យក្នុងការរស់នៅ ជៀសផុតពីជំងឺឆ្លងផ្សេងៗ។

៤. រយៈពេល៖ ៦០នាទី

៥.សម្ភារៈឧបទ្ទេស៖

- ការអប់រំសុខភាពសម្រាប់ ម.គ.ភ (VVOB)។
- ផ្ទាំងរូបភាពស្តីពីការឆ្លងជំងឺពីសត្វទៅមនុស្ស។
- ក្រដាស, ហ្វឺត, ស្កុត, សន្លឹកកិច្ចការ។

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យ ៖<br>• អវត្តមាន<br>• អនាម័យថ្នាក់រៀន<br>• សណ្តាប់ធ្នាប់ និងវិន័យ | ជំហានទី១<br>រដ្ឋបាលថ្នាក់ | – សិស្សក្រោកឈរស្វាគមន៍<br>– ប្រធាន, អនុប្រធាន រឺតំណាងថ្នាក់រាយការណ៍ និងឡើងសរសេរនៅជ្រុងក្តារខៀន ។ |
| – តើជំងឺអ្វីខ្លះដែលកំពុងរាតត្បាតទូទាំងសកល ?<br>– ក្នុងចំណោមជំងឺទាំងនោះ តើជំងឺ | ជំហានទី ២<br>រំលឹកមេរៀនចាស់<br>**ការឆ្លងជម្ងឺផ្តាសាយបក្សីពីសត្វទៅសត្វ** | – ជំងឺផ្តាសាយជ្រូក, ជំងឺជ្រូកត្រចៀកខៀវ, ជំងឺផ្តាសាយបក្សី...<br>– ជំងឺផ្តាសាយបក្សី |

| | | |
|---|---|---|
| ណាមួយ បង្កដោយវីរុស $H_5N_1$ ?<br><br>– តើជំងឺផ្តាសាយបក្សី ជាជំងឺដែលកើតឡើងនៅលើសត្វអ្វី ?<br><br>– តើវីរុសនេះឆ្លងពីសត្វទៅសត្វតាមរយៈអ្វីខ្លះ ?<br><br>– ក្រៅពីឆ្លងពីសត្វទៅសត្វ តើវីរុសនេះអាចឆ្លងទៅមនុស្សបានដែរឬទេ?<br>☞ ថ្ងៃនេះយើងនឹងសិក្សាបន្តពី មេរៀនជំងឺផ្តាសាយបក្សី ត្រង់ចំនុច ខ. ការឆ្លងផ្តាសាយបក្សីពីសត្វទៅមនុស្ស។ | | – ជាជំងឺមួយដែលកើតឡើងនៅ លើសត្វស្លាបគ្រប់ប្រភេទ<br><br>– តាមរយៈ<br>• ការផ្លាស់ប្តូរទីកន្លែងរបស់បក្សី<br>• ការជួបគ្នារវាងបក្សីស្រុក និងបក្សីព្រៃ<br>• ការចិញ្ចឹមបក្សីស្រុកជា លក្ខណៈសេរី<br>• តាមទឹកមាត់, ទឹករំអិល, ឈាម, សំបោរ..........<br><br>– បាន |
| – គ្រូបង្ហាញរូបភាពមួយទាក់ទងនឹងជីវភាពប្រចាំថ្ងៃ។<br>តើបុរសទាំងពីរកំពុងធ្វើអ្វី ?<br><br>– ហេតុអ្វីបានជាគាត់ទាំងពីរ ចាំបាច់ពាក់ម៉ាស ស្រោមដៃ និងស្បែកជើងកវែង ?<br><br>– គ្រូផ្តល់ឱកាសអោយសិស្សសាកល្បងបង្កើតសំណួរគន្លឹះ (២នាទី) | ជំហានទី ៣<br><br>ជំងឺផ្តាសាយបក្សី (ត)<br><br>***ខ. ការឆ្លងផ្តាសាយបក្សីពីសត្វ ទៅមនុស្ស***<br><br> | – សង្កេត ហើយឆ្លើយជាបុគ្គល។<br><br>– បុរសពាក់អាវពណ៌បៃតងកំពុងទទួលមាន់ពីបុរសពាក់អាវខៀវ។<br><br>– ដើម្បីការពារពីជំងឺឆ្លងផ្តាសាយបក្សី។ |

| សំណួរគន្លឹះ៖ តើវីរុសផ្ដាសាយបក្សីឆ្លងពីសត្វទៅមនុស្សតាមរបៀបណាខ្លះ ? | | |
|---|---|---|
| – អោយសិស្សសាកល្បងរកសម្មតិកម្ម ។ | ***សម្មតិកម្ម*** | – ការប៉ះពាល់បក្សីមានជំងឺ<br>– ការប៉ះពាល់លាមក ស៊ុត ដែលផ្ទុកវីរុស |
| – ចែកសិស្សជា ៤ក្រុម រួចចែករូបភាព និងសន្លឹកកិច្ចការ<br>– ណែនាំអោយសិស្សបំពេញសន្លឹកកិច្ចការ និងការពិភាក្សាតាមក្រុម | | – ចូលតាមក្រុមពិភាក្សា<br>– សង្កេតរូបភាព<br>– បំពេញចម្លើយក្នុងសន្លឹកកិច្ចការ និងក្រដាសផ្ទាំងធំ |
| ***ក្រុមទី១ ៖***<br>*(ចូរសរសេរអំពីរបៀបឆ្លងវីរុសផ្ដាសាយបក្សីពីសត្វទៅមនុស្សតាមរយៈរូបភាព)* | <br>•ជំងឺផ្ដាសាយបក្សីឆ្លងពីសត្វមកមនុស្សតាមរយៈ ៖<br>– ការប៉ះពាល់លាមកសត្វដែលមានជំងឺ<br>– ការប៉ះពាល់បក្សីងាប់<br>– ការប៉ះពាល់លាមក ឈាម ពោះវៀន<br>– ការប៉ះពាល់ស៊ុតដែលប្រឡាក់ ជាប់វីរុស អាចឆ្លងចូលទៅក្នុងខ្លួនមនុស្ស | •ជំងឺផ្ដាសាយបក្សីឆ្លងពីសត្វមកមនុស្សតាមរយៈ ៖<br>– ការប៉ះពាល់លាមកសត្វដែលមានជំងឺ<br>– ការប៉ះពាល់បក្សីងាប់<br>– ការប៉ះពាល់លាមក ឈាម ពោះវៀន<br>– ការប៉ះពាល់ស៊ុតដែលប្រឡាក់ជាប់វីរុស អាចឆ្លងចូលទៅក្នុងខ្លួនមនុស្ស |
| ***ក្រុមទី២ ៖***<br>*(ចូរសរសេរអំពីរបៀបឆ្លងវីរុស ផ្ដាសាយបក្សីពីសត្វទៅមនុស្ស តាមរ* | <br>•ជំងឺផ្ដាសាយបក្សីឆ្លងពីសត្វមកមនុស្សតាមរយៈ ៖ | •ជំងឺផ្ដាសាយបក្សីឆ្លងពីសត្វមកមនុស្សតាមរយៈ ៖<br>– ការជល់មាន់ ការបាញ់សត្វ |

| | | |
|---|---|---|
| *យៈរូបភាព)*<br><br>*ក្រុមទី៣ ៖*<br><br>*(ចូរសរសេរអំពីរបៀបឆ្លងវីរុស ផ្កាសាយបក្សីពីសត្វទៅមនុស្ស តាមរយៈរូបភាព*<br><br>*ក្រុមទី៤ ៖*<br><br>*(ចូរសរសេរអំពីរបៀបឆ្លងវីរុស ផ្កាសាយបក្សីពីសត្វទៅមនុស្ស តាមរយៈរូបភាព)* | – ការជល់មាន់ ការបាញ់សត្វ<br><br>– ការបរិភោគសាច់ រឺម្ហូបធ្វើពីសាច់បក្សីដែលចម្អិនមិនបានឆ្អិនល្អ<br><br>– ការសម្លាប់សត្វបក្សីដោយការប៉ះពាល់នឹងសារធាតុដែលផ្ទុកវីរុស<br><br> <br><br>• ជំងឺផ្តាសាយបក្សីឆ្លងពីសត្វមកមនុស្សតាមរយៈ ៖<br><br>– ការប៉ះពាល់ពេលអោយចំណី រឺ ការប្រមូលស៊ុតមាន់ ទា ក្ងាន ដែលមានផ្ទុកវីរុស។<br><br><br><br>• ជំងឺផ្តាសាយបក្សីឆ្លងពីសត្វមកមនុស្សតាមរយៈ ៖<br><br>– ការប្រើប្រាស់ទឹកមិនស្អាត ( បឹង ត្រពាំង ថ្លុក)ដែលមានបក្សីហែលលេង<br><br>– សត្វបក្សីដែលមានជំងឺបញ្ចេញ វីរុសតាមរយៈទឹករំអិល, សំបោរ, លាមកទៅក្នុងបរិស្ថាន | – ការបរិភោគសាច់ រឺម្ហូបធ្វើពីសាច់បក្សីដែលចម្អិនមិនបានឆ្អិនល្អ<br><br>– ការសម្លាប់សត្វបក្សីដោយការប៉ះពាល់នឹងសារធាតុដែលផ្ទុកវីរុស<br><br>• ជំងឺផ្តាសាយបក្សីឆ្លងពីសត្វមកមនុស្សតាមរយៈ ៖<br><br>– ការប៉ះពាល់ពេលអោយចំណី រឺ ការប្រមូលស៊ុតមាន់ ទា ក្ងាន ដែលមានផ្ទុកវីរុស។<br><br>• ជំងឺផ្តាសាយបក្សីឆ្លងពីសត្វមកមនុស្សតាមរយៈ ៖<br><br>– ការប្រើប្រាស់ទឹកមិនស្អាត (បឹង ត្រពាំង ថ្លុក)ដែលមានបក្សីហែលលេង<br><br>– សត្វបក្សីដែលមានជំងឺបញ្ចេញ វីរុសតាមរយៈទឹករំអិល, សំបោរ, លាមកទៅក្នុងបរិស្ថាន<br><br>– ឡើងបិត និងបកស្រាយចម្លើយតាមក្រុម<br><br>– ទាញសេចក្តីសន្និដ្ឋាន |

| | | |
|---|---|---|
| – អោយសិស្សឡើងបិតលទ្ធផល និងបកស្រាយចម្លើយតាមក្រុម<br>– សំយោគចម្លើយតាមក្រុម និង អោយសិស្សទាញសេចក្តីសន្និដ្ឋាន។ | សន្និដ្ឋាន<br>វីរុសផ្តាសាយបក្សីក៏អាចឆ្លង និង រាលដាលដល់មនុស្សបានយ៉ាង ងាយ តាមសកម្មភាពប្រចាំថ្ងៃ របស់ពួកគាត់ ដូចជា ៖ ការប៉ះពាល់បក្សីដែលមានផ្ទុកវីរុស ប្រសិនបើគាត់ខ្វះអនាម័យ ។ | |
| – អោយនិយមន័យផ្តាសាយបក្សី ?<br><br>– តើការឆ្លងជំងឺនេះមានប៉ុន្មានយ៉ាង?<br><br>– ដើម្បីបង្ការកុំអោយឆ្លងជម្ងឺផ្តាសាយបក្សី ពីសត្វទៅមនុស្ស តើ ត្រូវអនុវត្តដូចម្តេច? | ជំហានទី ៤<br>ពង្រឹងពុទ្ធិ<br>– ផ្តាសាយបក្សី ជាជម្ងឺដែលកើត ឡើងនៅលើសត្វស្លាបគ្រប់ប្រភេទ ដែលបង្កឡើងដោយវីរុស $H_5N_1$<br>– មាន ២យ៉ាង គឺ ៖ ការឆ្លង ផ្តាសាយបក្សីពីសត្វទៅសត្វ និង ពីសត្វទៅមនុស្ស<br>– ត្រូវអនុវត្តតាមក្បួនអនាម័យជាប្រចាំដូចជា ៖<br>• លាងដៃជាមួយទឹកស្អាត និង សាប៊ូ ពិសេសមុននឹងក្រោយចាប់ កាន់ មាន់ ទា។<br>• ត្រូវចម្អិនសាច់ ស៊ុតបក្សី អោយបានឆ្អិនល្អ។<br>• ពាក់ម៉ាស់ ស្បែកជើងកវែង និង ស្រោមដៃ ក្នុងពេលចេញ និង ចូលកសិដ្ឋានចិញ្ចឹមបក្សី។<br>• រាយការណ៍ជាបន្ទាន់ ក្នុង ករណីមានបក្សីឈឺ រឺងាប់ដល់ ពេទ្យសត្វ រឺ អាជ្ញាធរមូលដ្ឋាន។ | – ផ្តាសាយបក្សី ជាជម្ងឺដែលកើតឡើងនៅលើសត្វស្លាបគ្រប់ប្រភេទ ដែលបង្កឡើងដោយវីរុស $H_5N_1$<br>– មាន ២យ៉ាង គឺ ៖ ការឆ្លង ផ្តាសាយបក្សីពីសត្វទៅសត្វ និង ពីសត្វទៅមនុស្ស<br>– ត្រូវអនុវត្តតាមក្បួនអនាម័យជាប្រចាំដូចជា ៖<br>• លាងដៃជាមួយទឹកស្អាត និង សាប៊ូ ពិសេសមុននឹងក្រោយចាប់ កាន់ មាន់ ទា។<br>• ត្រូវចម្អិនសាច់ ស៊ុតបក្សី អោយបានឆ្អិនល្អ។<br>• ពាក់ម៉ាស់ ស្បែកជើងកវែង និងស្រោមដៃ ក្នុងពេលចេញ និង ចូលកសិដ្ឋានចិញ្ចឹមបក្សី។<br>• រាយការណ៍ជាបន្ទាន់ ក្នុង ករណីមានបក្សីឈឺ រឺងាប់ដល់ ពេទ្យសត្វ រឺអាជ្ញាធរមូលដ្ឋាន។ |

| | | |
|---|---|---|
| | - ធ្វើលំហាត់ប្រាណទៀងទាត់។<br>- បរិភោគទឹកអោយបានច្រើន។ | - ធ្វើលំហាត់ប្រាណទៀងទាត់។<br>- បរិភោគទឹកអោយបានច្រើន។ |
| - ពេលទៅផ្ទះវិញប្អូនៗត្រូវមើលមេរៀនឡើងវិញ និងឆ្លើយសំណួរកិច្ចការផ្ទះ។<br>- ត្រូវការពារខ្លួនអោយបានពីជម្ងឺផ្ដាសាយបក្សី និងជម្ងឺឆ្លងផ្សេង។ | ជំហានទី ៥<br>បណ្ដាំផ្ញើ និងកិច្ចការផ្ទះ<br>ដើម្បីបង្ការពេលមានការរាតត្បាត ពីជម្ងឺផ្ដាសាយបក្សីជាសកល តើយើងត្រូវអនុវត្តដូចម្ដេចខ្លះ ? | - ស្ដាប់ និងកត់ត្រាតាមបណ្ដាំផ្ញើ។ |

# សន្លឹកកិច្ចការ

សំណួរគន្លឹះ ៖

សម្មតិកម្ម៖

--------------------------------------------------------------------------------

--------------------------------------------------------------------------------

ការងារក្រុម៖

សង្កេតរូបភាព ហើយឆ្លើយសំណួរខាងក្រោម៖

តើវីរុសផ្តាសាយបក្សីឆ្លងពីសត្វមកមនុស្សបានតាមរបៀបណា?

លទ្ធផល៖

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

សន្និដ្ឋាន៖

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

សំណួរត្រិះរិះ៖

ដើម្បីបង្ការការរាតត្បាតជម្ងឺផ្តាសាយបក្សីមនុស្សជាំសកល តើយើងត្រូវអនុវត្តដូចម្តេចខ្លះ?

# ប្លង់ក្តារខៀន

សំណួរគន្លឹះ ៖

| |
|---|
| តើវីរុសផ្តាសាយបក្សីឆ្លងពីសត្វទៅមនុស្សតាមរបៀបណាខ្លះ ? |

សម្មតិកម្មៈ

------------------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------------------------

សំណួរពិភាក្សាក្រុមៈ

. ចូរសរសេរអំពីរបៀបឆ្លងវីរុសផ្តាសាយបក្សីពីសត្វទៅមនុស្ស តាមរយៈរូបភាព។

លទ្ធផល ៖

- ជំងឺផ្តាសាយបក្សីឆ្លងពីសត្វមកមនុស្សតាមរយៈ ៖

ក្រុមទី១ ៖

- ការប៉ះពាល់លាមកសត្វដែលមានជំងឺ
- ការប៉ះពាល់បក្សីងាប់
- ការប៉ះពាល់លាមក ឈាម ពោះវៀន
- ការប៉ះពាល់ស៊ុតដែលប្រឡាក់ជាប់វីរុស អាចឆ្លងចូលទៅក្នុងខ្លួនមនុស្ស។

ក្រុមទី២ ៖

- ការជល់មាន់ ការបាញ់សត្វ
- ការបរិភោគសាច់ រឺម្ហូបធ្វើពីសាច់ បក្សីដែលចម្អិនមិនបានឆ្អិនល្អ
- ការសម្លាប់សត្វបក្សីដោយការប៉ះពាល់នឹងសារធាតុដែលផ្ទុកវីរុស។

ក្រុមទី៣ ៖

- ការប៉ះពាល់ពេលអោយចំណី រឺ ការប្រមូលស៊ុតមាន់ ទា ក្ងាន ដែលមានផ្ទុកវីរុស។

ក្រុមទី៤ ៖

- ការប្រើប្រាស់ទឹកមិនស្អាត (បឹង ត្រពាំង ថ្លុក)ដែលមានបក្សីហែល លេង
- សត្វបក្សីដែលមានជំងឺបញ្ចេញ វីរុសតាមរយៈទឹករំអិល, សំបោរ, លាមកទៅក្នុងបរិស្ថាន។

សន្និដ្ឋាន ៖ វីរុសផ្តាសាយបក្សីក៏អាចឆ្លង និង រាលដាលដល់មនុស្សបានយ៉ាង ងាយតាមសកម្មភាពប្រចាំថ្ងៃរបស់ពួកគាត់ ដូចជា ៖ ការប៉ះពាល់បក្សីដែលមានផ្ទុកវីរុស ប្រសិនបើគាត់ខ្វះអនាម័យ ។

លក្ខណវិនិច្ឆ័យទៅលើការវាយតម្លៃ

<table>
<tr><th rowspan="2">លក្ខណៈវិនិច្ឆ័យ</th><th colspan="4">ពិន្ទុផ្តល់ដោយ<br>គ្រូឧទ្ទេសថ្នាក់ជាតិ</th><th rowspan="2">យោបល់របស់គ្រូឧទ្ទេសថ្នាក់ជាតិ</th></tr>
<tr><th>១</th><th>២</th><th>៣</th><th>៤</th></tr>
<tr><td>ទំនាក់ទំនងរវាគោលបំណងមេរៀន និងលទ្ធផលនៃអ្នកសិក្សា</td><td></td><td></td><td></td><td></td><td>វត្ថុបំណងច្បាស់លាស់ ប៉ុន្តែសកម្មភាព ពុំបានផ្តល់ឱកាសឲ្យសិស្សគិតច្រើន ដើម្បីសម្រេចវត្ថុបំណងទេ។ សិស្ស សម្រេចវត្ថុបំណងតាមរយៈចំណេះដឹងដែលគេមានស្រាប់។</td></tr>
<tr><td>ដំណើរការនៃការរៀនមេរៀនវិទ្យាសាស្ត្រ</td><td></td><td></td><td></td><td></td><td>បានអនុវត្តតាមលំនាំវិទ្យាសាស្ត្រតាម បែបរិះរកសិស្សធ្វើសកម្មភាពដោយផ្អែកលើចំណេះដឹងមូលដ្ឋានដែលពួកគេមានស្រាប់ជាងអ្វីដែលគេរកឃើញតាមរយៈសកម្មភាព។</td></tr>
<tr><td>ឱកាសនៃការសិក្សា</td><td></td><td></td><td></td><td></td><td>សិស្សមានឱកាសគិតពីបុព្វហេតុ បណ្តាលឲ្យឆ្លងផ្កាសាយបក្សីតាមរយៈការពិនិត្យរូបភាព និងពិភាក្សាតាមក្រុម។</td></tr>
</table>

## ២.៤. ផែនដីវិទ្យា

### ២.៤.១ វដ្តទឹក

### ២.៤.២ ថាមពលកម្ដៅ

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ ផែនដីវិទ្យា, ថ្នាក់ទី៩

២. ប្រធានបទ៖ វដ្តទឹក

៣. វត្ថុបំណង៖

- ពិពណ៌នាអំពីវដ្តទឹកបានច្បាស់លាស់តាមរយៈការធ្វើពិសោធ។
- ពន្យល់ពីវដ្តទឹក បានត្រឹមត្រូវតាមរយៈការបង្ហាញរូបភាព និងលទ្ធផលពិសោធន៍។
- បណ្ដុះស្មារតីសិស្សឲ្យចូលរួមថែរក្សាបរិស្ថាននៅក្នុងសហគមន៍របស់គេដើម្បីទទួលបានបរិមាណទឹកភ្លៀងច្រើន។

៤. រយៈពេល៖ ៥០នាទី

៥.សម្ភារៈឧបទ្ទេស៖

- កែវទឹក ចង្កៀងអាល់កុល ទឹកកក ថង់ប្លាស្ទិចថ្លា កៅស៊ូកង។

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យសណ្ដាប់ធ្នាប់ វិន័យ និងអវត្តមានសិស្ស។ | ជំហានទី១ (រដ្ឋបាលថ្នាក់) | ប្រធានថ្នាក់ឡើងរាយការណ៍។ |
| . ក្រោយពេលហាត់ប្រាណ តើប្អូនមានអារម្មណ៍បាត់បង់អ្វី។<br>. ដើម្បីឲ្យមានថាមពលឡើងវិញ តើយើងត្រូវធ្វើដូចម្ដេច?<br>. តើទឹកមាននៅកន្លែងណាខ្លះ?<br>. តើទឹកនៅលើផ្ទៃដីមានប៉ុន្មានប្រភេទ? អ្វីខ្លះ?<br>. សព្វថ្ងៃយើងប្រើប្រាស់ទឹកប្រភេទណា?<br>. ដូច្នេះថ្ងៃនេះយើងសិក្សាមេរៀនថ្មីមួយគឺទឹកសាបនៅលើផ្ទៃដី។ | ជំហានទី២ (រំលឹកមេរៀន) | . បាត់បង់ថាមពល។<br>. សម្រាប ផឹកទឹក.....។<br>. ទឹកមាននៅលើផ្ទៃដី ក្នុងដី ក្នុងបរិយាកាស។<br>. ទឹកនៅលើផ្ទៃដីមាន ២ប្រភេទគឺ ៖ ទឹកសាប និងទឹកប្រៃ។<br>. ប្រើប្រាស់ទឹកសាប។ |
| | ជំហានទី៣ (មេរៀនប្រចាំថ្ងៃ | |

| | | |
|---|---|---|
| សរសេរចំណងជើងមេរៀនថ្មីនៅលើក្តារខៀន។ | ជំពូកទី២ ទឹកសាប<br>មេរៀនទី១<br><u>ទឹកសាបនៅលើផ្ទៃដី</u> | |
| . ចែកសិស្សជាក្រុម ចែកសន្លឹកកិច្ចការដល់សិស្ស។<br>. ឲ្យសិស្សសង្កេតរូបភាព<br>. បង្ហាញរូបភាពវដ្តទឹក<br>. ណែនាំសិស្សអោយសង្កេតរូបភាពរួចបំពេញក្នុងសន្លឹកកិច្ចការ។ | I. វដ្តទឹក<br><br> | សង្កេតរូបភាពរួចបំពេញសន្លឹកកិច្ចការ។ |
| . ដើរពិនិត្យមើលសិស្សបំពេញចម្លើយរួចហៅឲ្យឡើងឆ្លើយ។<br>. ទឹកស្ថិតក្នុងភាពជាអ្វីខ្លះ?<br>. តើដំណើរផ្លាស់ប្តូរនេះហៅថាអ្វី? | ១. វដ្តទឹក<br>. តើទឹកអាចស្ថិតក្នុងភាពជាអ្វីខ្លះ? (រាវ, ឧស្ម័ន,...)<br>. តើដំណើរបំលាស់ប្តូរនេះហៅថាអ្វី? (វដ្តទឹក)។ | ឡើងឆ្លើយ នឹងសំណួរ។<br>. រាវ, ឧស្ម័ន (ចំហាយទឹក)<br>. វដ្តទឹក។ |
| បំផុសសិស្សឲ្យបង្កើតសំណួរដែលទាក់ទងទៅនឹងវដ្តទឹក។<br>ប្រមូលចម្លើយរបស់សិស្សរួចទាញជាសំណួរគន្លឹះ។ | ២. សំណួរគន្លឹះ<br>តើវដ្តទឹកកើតឡើងដូចម្តេចខ្លះ? | . ចម្លើយអាស្រ័យតាមគំនិតរបស់សិស្សម្នាក់ៗ។ |
| បិតក្រដាសទស្សន៍ទាយសម្មតិកម្មលើក្តារខៀន ឲ្យសិស្សគិត ទស្សន៍ទាយ និងពន្យល់។ | ៣.ទស្សន៍ទាយសម្មតិកម្ម<br>ទឹកធម្មតា —កម្តៅ→ ................<br>................ —ត្រជាក់→ ................<br>................ —ផ្តុំគ្នា→ ................ | គិត និងទស្សន៍ទាយលទ្ធផល។ |
| . ដើម្បីបង្ហាញថាសម្មតិកម្មនេះត្រូវឬខុសយើងត្រូវធ្វើពិសោធន៍ទាំងអស់គ្នា។<br>. ណែនាំសិស្សតាមក្រុមនិមួយៗ បន្ទាប់មកឲ្យពួកគេ គូពីគំនិតរបស់ពួកគេលើក្រដាស់ផ្ទាំងធំដែលបានចែកឲ្យ។<br>ចែកសិស្សជាក្រុម៖<br>. ចែកសម្ភារៈពិសោធន៍<br>. បិទដំណើរការពិសោធន៍<br>. ឲ្យសិស្សមួយឬពីនាក់អានដំណើរការ។<br>. ណែនាំសិស្សពីបម្រុងប្រយ័ត្ន<br>. ឲ្យសិស្សធ្វើពិសោធ | ៤. តេស្តសម្មតិកម្ម<br>ប្លង់ពិសោធន៍ (៥នាទី)<br>គ្របថង់ប្លាស្ទិច និងចងកៅស៊ូ<br><br><br>កែវទី១ កែវទី២<br><u>ដំណើរការពិសោធន៍</u><br>ចាក់ទឹកត្រជាក់ធម្មតាចូលទៅក្នុងកែវ ២ (ប្រហែល ១Cm ឬ ២Cm ពីបាតកែវ) គ្របថង់ប្លាស្ទិច ចងឲ្យជាប់។ | ស្តាប់ការណែនាំ។<br>យកសម្ភារៈ<br>. សិស្សធ្វើពិសោធតាមក្រុម។ |

<table>
<tr>
<td>. ណែនាំឲ្យសិស្សសង្កេតលទ្ធផលពិសោធន៍។<br><br>បំពេញលទ្ធផលពិសោធន៍ក្នុងតារាង និងទាញសេចក្ដីសន្និដ្ឋាន។<br>. តំណាងក្រុមឡើងបិទ និងពន្យល់ឲ្យមិត្តភក្ដិដឹងពីគំនិតរបស់ក្រុមខ្លួន។ ឆ្លើយបំពេញតារាង<br>(១ក្រុម ១ប្រលោះ)។<br><br>សន្និដ្ឋានលទ្ធផល និងផ្ទៀងផ្ទាត់។</td>
<td>.កែវទី១៖ ទុកធម្មតា<br>.កែវទី២៖ យកទឹកទៅដាំរហូតដល់ពុះ<br><u>សង្កេត៖</u><br>. នៅក្នុងកែវទី១៖ តើមានអ្វីកើតឡើង?<br>. នៅក្នុងកែវទី២៖ ពេលកំពុងដាំ<br>. តើមានអ្វីកើតឡើងនៅបាតកែវ?<br>. តើមានអ្វីកើតឡើងនៅជាប់និងគម្របកែវ?<br>*បន្ទាប់មកចូរដាក់ទឹកកកមួយដុំនៅលើគម្របកែវ រួចសង្កេត (ក្រោយពេលដាំ)។<br>
<table>
<tr><th rowspan="2">ក្រុម</th><th rowspan="2">មុនដាំ</th><th rowspan="2">ពេលដាំ</th><th colspan="2">ក្រោយពេលដាំ</th></tr>
<tr><th>គ្មានទឹកកក</th><th>ដាក់ទឹកកក</th></tr>
<tr><td>១</td><td></td><td></td><td></td><td></td></tr>
<tr><td>២</td><td></td><td></td><td></td><td></td></tr>
<tr><td>៣</td><td></td><td></td><td></td><td></td></tr>
<tr><td>...</td><td></td><td></td><td></td><td></td></tr>
</table>
<br>៥. សន្និដ្ឋាន៖<br>វដ្ដទឹកកើតឡើង៣ដំណាក់៖<br>ទឹកធម្មតា —កម្ដៅ→ ចំហាយទឹក<br>ចំហាយទឹក —ត្រជាក់→ ញើស(ពពក)<br>ញើស(ពពក) —ផ្តុំគ្នា→ ទឹកភ្លៀង</td>
<td>. សិស្សសង្កេតតាមក្រុមនិមួយៗ។<br><br>. បំពេញលទ្ធផលតាមក្រុម។<br><br>. សិស្សសន្និដ្ឋានតាមក្រុម។</td>
</tr>
<tr>
<td>. បង្ហាញកែវ២ឲ្យសិស្សសង្កេត<br>កែវទី១៖ ដាក់ទឹកក្ដៅ<br>កែវទី២៖ ដាក់ទឹកកក<br>តើប្អូនសង្កេតឃើញអ្វីខ្លះក្នុងកែវទី១?<br>. តើផ្សែងជាអ្វី<br>. តើផ្សែងបានមកពីណា?<br>តើប្អូនសង្កេតឃើញអ្វីខ្លះក្នុងកែវទី២?<br><br>. តើតំណក់ទឹកតូចៗជុំវិញកែវទី២បាន</td>
<td>ជំហានទី៤ (ពង្រឹងពុទ្ធិ)<br><br>កែវទឹកទី១ កែវទឹកទី២<br>
</td>
<td>. ឃើញមានផ្សែង (កែវទឹកក្ដៅ)<br>. ផ្សែងជាភាគល្អិតតូចៗនៃទឹក<br>. ផ្សែងកើតឡើងពីការចុះត្រជាក់នៃចំហាយទឹក។<br>. តំណក់ទឹក (ញើស)នៅព័ទ្ធជុំវិញកែវទឹក។<br>. បានមកពីការផ្តុំគ្នារវាងចំហាយទឹកអ</td>
</tr>
</table>

| | | |
|---|---|---|
| មកពីណា? | | ល្អែតនៅក្នុងបរិយាកាស។ |
| . ចូរគូគំនូរវដ្តទឹក ដោយបញ្ជាក់ពីដំណាក់កាលនិមួយៗ។<br>. ពេលត្រឡប់ទៅផ្ទះវិញប្អូនត្រូវជួយសំអាតបរិស្ថានជុំវិញផ្ទះរបស់ប្អូន, ដាំដើមឈើបន្ថែម ព្រោះដើមឈើជាប្រភពទឹកភ្លៀងយ៉ាងសំខាន់។<br>. មើលមេរៀនឡើងវិញ និងធ្វើលំហាត់ផង។ | ជំហានទី៥<br>កិច្ចការផ្ទះ<br>ចូលប្អូនសរសេរមេរៀនរៀបរាប់អំពីវដ្តទឹក ដោយប្រើជាមួយ និងពាក្យវដ្តទឹក, ទឹកភ្លៀង, កំណក, បរិយាកាស, កំណកអាកាស, សមុទ្រ, ចំហាយទឹក, បឹងបួរ, រំហួត, ពពក អោយបានយ៉ាងតិចបំផុត ៥ បន្ទាត់។ | . គូសគំនូតាងនៅក្នុងសន្លឹកកិច្ចការ។ |

# សន្លឹកកិច្ចការ

១. សង្កេតៈ រូបភាព

. តើទឹកអាចស្ថិតក្នុងភាពជាអ្វីខ្លះ? ............................................

. តើដំណើរនៃបំលាស់ប្តូរនេះហៅថាអ្វី? ............................................

២. សំណួរគន្លឹះ៖

| |
|---|
| |

៣. ទស្សន៍ទាយសម្មតិកម្ម៖

. ទឹកធម្មតា —រងនូវកំដៅ→ ..............................

................................. —ចុះត្រជាក់→ ...............................

................................. —ផ្តុំគ្នា→ ...............................

៤. តេស្តសម្មតិកម្ម ៖ (ប្លង់ពិសោធ)

| |
|---|
| |

ដំណើរការពិសោធ (តារាងលទ្ធផល)

| ក្រុម | មុនពេលដាំ | ពេលដាំ | ក្រោយពេលដាំ | |
|---|---|---|---|---|
| | | | គ្មានទឹកកក | ដាក់ទឹកកក |
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| …….. | | | | |

៥. សន្និដ្ឋាន៖

វដ្តទឹកកើតឡើង ៣ ដំណាក់កាល៖

. ទឹកធម្មតា —រងនូវកំដៅ→ .................................

. ..................... —ចុះត្រជាក់→ .................................

. ..................... —ផ្តុំគ្នា→ .................................

សំណួរ.

ចូរគូសគំនូសតាងអំពីវដ្តទឹក ដោយបញ្ជាក់ពីដំណាក់កាលនីមួយៗផង។

| |
|---|
| |

# ប្លង់ក្តារខៀន

១. សង្កេត៖ រូបភាព

. តើទឹកអាចស្ថិតក្នុងភាពជាអ្វីខ្លះ? ............................................

. តើដំណើរនៃបំលាស់ប្តូរនេះហៅថាអ្វី? ............................................

២. សំណួរគន្លឹះ៖

|  |
|---|
|  |

៣. ទស្សន៍ទាយសម្មតិកម្ម៖

. ទឹកធម្មតា —ក្តៅ→ ..............................

................................. —ចុះត្រជាក់→ ...............................

................................. —ផ្តុំគ្នា→ ...............................

៤. តេស្តសម្មតិកម្ម ៖ (ប្លង់ពិសោធ)

|  |
|---|
|  |

ដំណើរការពិសោធ (តារាងលទ្ធផល)

| ក្រុម | មុនពេលដាំ | ពេលដាំ | ក្រោយពេលដាំ | |
|---|---|---|---|---|
| | | | គ្មានទឹកកក | ដាក់ទឹកកក |
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| …….. | | | | |

៥. សន្និដ្ឋាន៖

វដ្តទឹកកើតឡើង ៣ ដំណាក់កាល៖

. ទឹកធម្មតា —រងនូវកំដៅ→ ចំហាយទឹក

. ចំហាយទឹក —ចុះត្រជាក់→ តំណក់តូចៗនៃទឹក (ញើស)

. តំណក់ទឹកតូចៗ —ផ្តុំគ្នា→ ទឹកភ្លៀងធ្លាក់ចុះ

សំណួរ.

ចូរគូសគំនូសតាងអំពីវដ្តទឹក ដោយបញ្ជាក់ពីដំណាក់កាលនីមួយៗផង។

|  |
|---|
|  |

លក្ខណវិនិច្ឆ័យទៅលើការវាយតម្លៃ

| លក្ខណវិនិច្ឆ័យ | ពិន្ទុពីគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក | | | | យោបល់ពីគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| ទំនាក់ទំនងរវាគោលបំណងមេរៀន និងលទ្ធផលនៃអ្នកសិក្សា | | | | | វត្ថុបំណងច្បាស់លាស់ |
| ដំណើរការនៃការរៀនមេរៀនវិទ្យាសាស្ត្រ | | | | | សកម្មភាពបង្រៀន-រៀនល្អ តែមានខ្លឹមសារ និងសកម្មភាពច្រើនពេកសម្រាប់រយៈពេលបង្រៀន ៥០ នាទី |
| ឱកាសនៃការសិក្សា | | | | | ល្អ |

# កិច្ចតែងការបង្រៀន

១. មុខវិជ្ជា៖ ផែនដីវិទ្យា, ថ្នាក់ទី១០

២. ប្រធានបទ៖ ថាមពលកម្តៅ

៣. វត្ថុបំណង៖

- ប្រាប់ពីមូលហេតុដែលធ្វើឲ្យមានបប្រែបម្រួលសីតុណ្ហភាពនៅលើភពផែនដីបានត្រឹមត្រូវតាមរយៈការពិសោធន៍។
- ធ្វើពិសោធន៍អំពីបប្រែបម្រួលសីតុណ្ហភាពនៅលើផែនដីឲ្យឃើញជាក់ស្តែងតាមរយៈក្រុម។
- មានការចូលរួមធ្វើពិសោធបានទាំងអស់គ្នា។

៤. រយៈពេល៖ ៦០នាទី

៥.សម្ភារៈឧបទ្ទេស៖

- ពិល, ក្រដាសស, បង់ស្អិត, ក្រដាសសំបកឡាំង, បន្ទាត់ ខ្មៅដៃ កន្ត្រៃ, រ៉ាប់ព័រទ័រ។

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . ពិនិត្យរដ្ឋបាលថ្នាក់ | ជំហានទី១<br>រដ្ឋបាលថ្នាក់ | . ប្រធានថ្នាក់ឡើងរាយការណ៍ |
| ១. មធ្យោបាយអ្វីខ្លះដែលធ្វើឲ្យថាមពលកម្តៅបាចសាចពាសពេញបរិយាកាស?<br>២. កម្តៅដែលបាចសាចមក តើភពផែនដីយើងទទួលបានស្មើគ្នាដែរឬទេ? | ជំហានទី២<br>រំលឹកមេរៀនចាស់<br>. មធ្យោបាយមាន៣ គឺ៖ ចម្លង, រង្វល់, រំភាយ។<br><br>. ទទួលបានមិនស្មើគ្នាទេ | . សិស្សឆ្លើយបានត្រឹមត្រូវតាមរយៈការចងចាំ។<br><br>. សិស្សកត់ចំណាងជើងដាក់សៀវភៅទៅ។ |
| . ថ្ងៃនេះយើងរៀនមេរៀនបន្តគឺ | ជំហានទី៣<br>មេរៀនថ្មី<br>ចំណុចទី៣<br>បប្រែបម្រួលសីតុណ្ហភាព<br>នៅលើផែនដី | . សិស្សកត់ចំណាងជើងដាក់សៀវភៅ |
| តើកម្តៅនៅលើភពផែនដីយើងមិនស្មើគ្នាបណ្តាលមកពីមូលហេតុអ្វី? | | |
| | សម្មតិកម្ម<br>. បណ្តាលមកពីផែនដីមានរាងមូល | |

ចែកសិស្សជាបីក្រុម

១. កំរិតមុំ $90^0$ វាមានអង្កត់ផ្ចិតរង្វង់ពន្លឺប៉ុន្មាន? សីតុណ្ហភាពប៉ុន្មាន?

ធ្វើតេសសម្មតិកម្ម




រូបទី១ $90^0$

D = 5,3 cm

សីតុណ្ហភាព (៣៣ $^0$C)

២. កំរិតមុំ $45^0$ វាមានអង្កត់ផ្ចិតរង្វង់ពន្លឺប៉ុន្មាន? សីតុណ្ហភាពប៉ុន្មាន?



$45^0$

រូបទី២

D = 7,7 cm

សីតុណ្ហភាព (៣២$^0$៥)

៣. កំរិតមុំ $15^0$ វាមានអង្កត់ផ្ចិតរង្វង់ពន្លឺប៉ុន្មាន? សីតុណ្ហភាពប៉ុន្មាន?



រូបទី៣ $15^0$

| ក្រុម | ៩០$^0$ | | ៤៥$^0$ | | ១៥$^0$ | |
|---|---|---|---|---|---|---|
| | អ.ពន្លឺ | សី/តុ | អ.ពន្លឺ | សី/តុ | អ.ពន្លឺ | សី/តុ |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |

D = 17,4 cm

សីតុណ្ហភាព (៣១$^0$៥)

សន្និដ្ឋាន

តាមការពិសោធន៍ បានបង្ហាញឲ្យឃើញថាកម្ដៅនៅលើផែនដីមិនស្មើគ្នា បណ្ដាលមកពីផែនដីមានរាងមូលមែន ព្រោះបាច់ពន្លឺដែលនាំមកប៉ះផ្ទៃក្រដាសគឺ ខុសគ្នាទៅតាមមុំនិមួយៗ ហើយកម្ដៅក៏ខុសគ្នាទៅតាមបាច់ពន្លឺ មានន័យថាបាច់ពន្លឺកាន់តែតូចកម្ដៅកាន់តែខ្លាំង បាច់ពន្លឺកាន់តែធំកម្ដៅកាន់តែខ្សោយ។

សិស្សសន្និដ្ឋានតាមក្រុមពីលទ្ធផលដែលធ្វើបាន។

| | | |
|---|---|---|
| . សិស្សសង្កេតរូបឲ្យសិស្សឡើងវាស់មុខកាត់នៃពន្លឺទាំងបី។<br><br>១. ចូរនិយាយពីមុខកាត់នៃបាច់ពន្លឺទាំងបី?<br><br>២. មុខកាត់នៃបាច់ពន្លឺទាំងបីវាបញ្ជាក់ដូចម្ដេចអំពីសីតុណ្ហភាពលើផែនដី? | ជំហានទី៤<br>ពង្រឹងចំណេះដឹង<br>រូបផែនដីទទួលកាំរស្មីព្រះអាទិត្យ<br><br>កាំរស្មី<br><br><br>. មុខកាត់បាច់ពន្លឺនៅតំបន់អេក្វាទ័រមានទំហំតូចជាងតំបន់ត្រជាក់បង្គួរ ហើយមុខកាត់តំបន់ត្រជាក់តូចជាងមុខកាត់តំបន់ប៉ូល។<br>. បញ្ជាក់ថាតំបន់អេក្វាទ័រមានកម្ដៅខ្លាំងជាងតំបន់ត្រជាក់បង្គួរហើយតំបន់ត្រជាក់បង្គួរកម្ដៅខ្លាំងជាងតំបន់ប៉ូល។ | . សិស្សសង្កេត<br><br>. សិស្សឡើងវាស់។<br><br>. សិស្សរៀបរាប់បានយ៉ាងក្បោះក្បាយ។<br><br>. សិស្សឆ្លើយ។ |
| តើប្អូនចូលចិត្តរស់នៅតំបន់ណា ក្នុងចំណោមតំបន់ទាំងបី? ហេតុអ្វី? | ជំហានទី៥<br>បណ្ដាំផ្ញើ | សិស្សកត់ដាក់សៀវភៅ។ |

# សន្លឹកកិច្ចការ

ប្រធានបទ: បម្រែបម្រួលសីតុណ្ហភាពនៃផែនដី

១. វត្ថុបំណង:

ចំណេះដឹង:

- ប្រាប់ពីមូលហេតុដែលធ្វើឲ្យមានបម្រែបម្រួលសីតុណ្ហភាពនៅលើភពផែនដីបានត្រឹមត្រូវតាមរយៈការពិសោធន៍។

ចំណេះធ្វើ:

- ធ្វើពិសោធន៍អំពីបម្រែបម្រួលសីតុណ្ហភាពនៅលើផែនដីឲ្យឃើញជាក់ស្តែងតាមរយៈក្រុម។

ឥរិយាបថ:

- មានការចូលរួមធ្វើពិសោធបានទាំងអស់គ្នា។

២. សំណួរគន្លឹះ ៖

បង្កើតសម្មតិកម្ម៖

ដំណើរការពិសោធន៍៖

លទ្ធផល៖

| ក្រុម | ៩០$^0$ | | ៤៥$^0$ | | ១៥$^0$ | |
|---|---|---|---|---|---|---|
| | អ.ពន្លឺ | សី/តុ | អ.ពន្លឺ | សី/តុ | អ.ពន្លឺ | សី/តុ |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |

សន្និដ្ឋាន៖

# ប្លង់ក្តារខៀន

## កំណត់បញ្ហា

តើកម្តៅនៅលើភពផែនដីមិនស្មើគ្នាបណ្តាលមកពីមូលហេតុអ្វី?

## បង្កើតសម្មតិកម្ម

កម្តៅមិនស្មើគ្នាបណ្តាលមកពីផែនដីមានរាងមូល។

## ដំណើរការពិសោធន៍

. បិទក្រដាសរាបនៅលើសម្ភារ

. ដាក់ពិលចម្ងាយ២៥ cm ពីក្រដាស

. បញ្ចាំងពិលទៅលើក្រដាសយ៉ាងណាធ្វើឲ្យចាំងប៉ះផ្ទៃក្រដាសតាមមុំ ៩០$^0$ ៤៥$^0$ ១៥$^0$ ។

. យកខ្មៅដៃគូសរង្វង់ពន្លឺ

. វាស់អង្កត់ផ្ចិតពន្លឺរួចដាក់ទែម៉ូម៉ែតចំពន្លឺ

. ស្រង់លទ្ធផលចូលក្នុងតារាង។



រូបទី១



រូបទី២



រូបទី៣

## លទ្ធផលពិសោធន៍

| ក្រុម | ៩០$^0$ | | ៤៥$^0$ | | ១៥$^0$ | |
|---|---|---|---|---|---|---|
| | បាច់ពន្លឺ | សី.តុ | បាច់ពន្លឺ | សី.តុ | បាច់ពន្លឺ | សី.តុ |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |

## សន្និដ្ឋាន

តាមការពិសោធន៍បានបង្ហាញឲ្យឃើញថាកម្តៅនៅលើផែនដី មិនស្មើគ្នា បណ្តាលមកពីផែនដីមានរាងមូលមែន ព្រោះបាច់ពន្លឺដែលនាំមកប៉ះផ្ទៃក្រដាស គឺខុសគ្នាទៅតាមមុំនិមួយៗ ហើយកម្តៅក៏ខុសគ្នាទៅតាមបាច់ពន្លឺ មានន័យថា បាច់ពន្លឺកាន់តែតូចកម្តៅកាន់តែខ្លាំង បាច់ពន្លឺកាន់តែធំកម្តៅកាន់តែខ្សោយ។

លក្ខណវិនិច្ឆ័យទៅលើការវាយតម្លៃ

| លក្ខណវិនិច្ឆ័យ | ពិន្ទុពីគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក | | | | យោបល់ពីគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុក |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| ទំនាក់ទំនងរវាគោលបំណងមេរៀន និងលទ្ធផលនៃអ្នកសិក្សា | | | | | វត្ថុបំណងច្បាស់លាស់ សកម្មភាព លទ្ធផល និងសន្និដ្ឋានសម្រេចបាននូវវត្ថុបំណងនេះ។ |
| ដំណើរការនៃការរៀនមេរៀនវិទ្យាសាស្ត្រ | | | | | អនុវត្តបានតាមលំនាំវិទ្យាសាស្ត្រ មានបង្កើតបញ្ហា ចម្លើយប៉ាន់ស្មាន ទទួលបានលទ្ធផល ហើយទាញរកសេចក្ដីសន្និដ្ឋាន។ |
| ឱកាសនៃការសិក្សា | | | | | ផ្ដល់ឱកាសឲ្យសិស្សគិត តែលទ្ធផលមិនបាន ១០០% ដោយការណែនាំរបស់គ្រូនៅមានចំណុចខ្វះខាត។ |

# ៣. ផែនការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន

# នៅក្នុង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

*ក្រុមសិក្សាស្រាវជ្រាវមេរៀន (ក្រដាស A4)*

**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ បាត់ដំបង**

| រ.ល | ឈ្មោះ | តួនាទី/មុខវិជ្ជា |
|---|---|---|
| ១ | លោកស្រី ផាវ៉ាន់ សាគឿត | នាយិកា |
| ២ | លោក សុខ ហ៊ីង | នាយករង |
| ៣ | លោកស្រី អន សុមាវាចា | ជីវវិទ្យា |
| ៤ | លោកស្រី សារី ម៉ូនីកា | ជីវវិទ្យា |
| ៥ | លោក ទុយ វ៉េត | រូបវិទ្យា |
| ៦ | លោកស្រី ម៉េះ ចាន់ថេត | រូបវិទ្យា |
| ៧ | លោក រឿង វ៉ារិន | រូបវិទ្យា |
| ៨ | លោក យុន មុនី | ជីវវិទ្យា |
| ៩ | លោកស្រី សោ គឹមហៀក | ជីវវិទ្យា |
| ១០ | លោក មាស សាទុំ | គីមី |
| ១១ | លោក សំ អឿត | រូបវិទ្យា |
| ១២ | លោក ជាប ឈាងរិត | ផែនដីវិទ្យា |
| ១៣ | លោកស្រី ទេស សុផាវ៉ាន់ | ផែនដីវិទ្យា |
| ១៤ | លោក ខែម សារិត | គីមី |
| ១៥ | លោក អាសាមុីហ៊្សូ ស៊ីនស៊្វូកេ | អ្នកស្ម័គ្រចិត្ត JICA |
| ១៦ | លោកស្រី សេង ហឿង | គីមី |

ហត្ថលេខា

_______________

លោកស្រី នាយិកា ផាវ៉ាន សាគឿត

*អាចរៀបចំឲ្យបានច្រើនក្រុមកាន់ប្រសើរ។

**កាលវិភាគអនុវត្តការសិក្សាស្រាវជ្រាវមេរៀន**

**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ បាត់ដំបង**

| សប្តាហ៍ | ២០១០ | | | ២០១១ | | |
|---|---|---|---|---|---|---|
| | ១០ | ១១ | ១២ | ១ | ២ | ៣ |
| ១ | | | | | គ្រូវិទ្យាសាស្ត្រ RTTC បំប៉នគរុកោសល្យដល់គ្រូសាលាអនុវត្ត | |
| ២ | ប្រជុំបច្ចេកទេសរួមគ្រូឧទ្ទេស+គ្រូសាលាអនុវត្ត (ចាត់តាំងគ្រូ) | ប្រជុំបច្ចេកទេសរួមគ្រូ RTTC + អនុវត្តបង្រៀនរូបវិទ្យាសាកល្បងជាមួយ LS | -ប្រជុំបច្ចេកទេសរួម (គ្រូសាលាអនុវត្ត + RTTC)<br>-ឆ្លងកិច្ចតែងការបង្រៀន(ផែនដី វិទ្យា) | បង្រៀនជាមួយគរុសិស្ស (ផែនដី) | ប្រជុំបច្ចេកទេសរួម គ្រូRTTC + គ្រូសាលាអនុវត្ត | |
| ៣ | ឆ្លងកិច្ចតែងការបង្រៀន ២១/២០/២០១០ | | | រៀបចំរបាយការណ៍ឆមាសទី ១ STEPSAM2 | នាយិកាRTTC បំប៉នដល់ POE | |
| ៤ | | បង្រៀនជាមួយគរុសិស្ស ២៥/១១/២០១០ ចាត់តាំងបន្ត | បង្រៀនសាកល្បង ផែនដីវិទ្យាជាមួយក្រុម LS | | | |
| មុខវិជ្ជា៖<br>ប្រធានបទ៖<br>អ្នកទទួលប្រធានបទ៖ | (រូបវិទ្យា)<br><br>អ.ស ម៉េះ ចាន់ថេត | (ផែនដីវិទ្យា)<br><br>អ.ស ទេស សុផារ៉ាន់ | | | | |

| សប្តាហ៍ | ២០១១ | | | | |
|---|---|---|---|---|---|
| | ៤ | ៥ | ៦ | ៧ | ៨ |
| ១ | | | | | |
| ២ | | | របាយការណ៍ឆមាសទី២<br>STEPSAM2 | | |
| ៣ | | បង្រៀនជាមួយគរុសិស្ស | | | |
| ៤ | -ប្រជុំបច្ចេកទេសរួម RTTC + គ្រូសាលាអនុវត្ត<br>-ចាត់តាំងគ្រូបន្ត | | | | |
| មុខវិជ្ជា៖<br><br>ប្រធានបទ៖<br><br>អ្នកទទួលប្រធានបទ៖ | | អ្នកស្រី សារី ម៉ូនីកា (ជីវវិទ្យា)<br><br><br>លោក មាស សាទុំ (គីមី) | | | |

## មជ្ឈមណ្ឌលគរុកោសល្យតូមិភាគ កំពង់ចាម

| រ.ល | ឈ្មោះ | តួនាទី/មុខវិជ្ជា |
|---|---|---|
| ១ | លោក វ៉ែន ស៊ីថាន | ប្រធាន |
| ២ | ហ៊ូ រ៉ូន្នី | អនុប្រធាន |
| ៣ | អ៊ាង វិបុល | គ្រូឧទ្ទេស ជីវវិទ្យា |
| ៤ | ស៊ិន ឈុនឡេង | គ្រូឧទ្ទេស ជីវវិទ្យា |
| ៥ | ហេង ណាលីន | គ្រូឧទ្ទេស ផែនដីវិទ្យា |
| ៦ | ហេង ឌីណា | គ្រូឧទ្ទេស គីមីវិទ្យា |
| ៧ | លី សុខហៃ | គ្រូឧទ្ទេស គីមីវិទ្យា |
| ៨ | ហ៊ឹង សុខចាន់ | គ្រូឧទ្ទេស រូបវិទ្យា |
| ៩ | លី ពិសិដ្ឋ | គ្រូឧទ្ទេស រូបវិទ្យា |
| ១០ | | |
| ១១ | | |
| ១២ | | |

ហត្ថលេខា

_______________

លោកនាយករង វ៉ែន ស៊ីវ៉ាន

*អាចរៀបចំឲ្យបានច្រើនក្រុមកាន់ប្រសើរ។

**ការវិភាគអនុវត្តការសិក្សាស្រាវជ្រាវមេរៀន**
**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ កំពង់ចាម**

| សប្តាហ៍ | ២០១០ | | | ២០១១ | | |
|---|---|---|---|---|---|---|
| | ១០ | ១១ | ១២ | ១ | ២ | ៣ |
| ១ | | កែលម្អកិច្ចតែងការ<br>បង្រៀនរូបវិទ្យា | បង្រៀនគរុសិស្សនិងកែលម្អ | បង្រៀនសាកល្បងនិងកែលម្អ | កែលម្អកិច្ចតែងការ | បង្រៀនគរុសិស្សនិងកែលម្អ |
| ២ | | | | | | |
| ៣ | | បង្រៀនសាកល្បងនិងកែលម្អ | កែលម្អកិច្ចតែងការ<br>បង្រៀនផែនដី | បង្រៀនគរុសិស្សនិងកែលម្អ | បង្រៀនសាកល្បងនិងកែលម្អ | |
| ៤ | | | | | | |
| មុខវិជ្ជា៖<br>ប្រធានបទ៖<br>អ្នកទទួលប្រធានបទ៖ | | | រូបវិទ្យា<br><br>លោក ហ៊ីង សុខចាន់ | ផែនដីវិទ្យា<br><br>អ.ស ហេង ណាលីន | | គីមីវិទ្យា<br><br>កញ្ញា ហេង ឌីណា |

| សប្តាហ៍ | ២០១១ | | | | |
|---|---|---|---|---|---|
| | ៤ | ៥ | ៦ | ៧ | ៨ |
| ១ | | កែលម្អកិច្ចតែងការបង្រៀនគីមី | កែលម្អកិច្ចតែងការបង្រៀនគីមី | | |
| ២ | | បង្រៀនសាកល្បងនិងកែលម្អ | | | |
| ៣ | | | បង្រៀនសាកល្បងនិងកែលម្អ | | |
| ៤ | | បង្រៀនដល់គរុសិស្សនិងកែលម្អ | បង្រៀនគរុសិស្សនិងកែលម្អ | | |
| មុខវិជ្ជា៖<br>ប្រធានបទ៖<br>អ្នកទទួលប្រធានបទ៖ | | គីមី<br><br>អ.ស លី សុខណៃ | ជីវវិទ្យា<br><br>លោក អ៊ាង វិបុល | | |

*ក្រុមសិក្សាស្រាវជ្រាវមេរៀន* (*ក្រដាស* A4)

**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ កណ្ដាល**

| រ.ល | ឈ្មោះ | តួនាទី/មុខវិជ្ជា |
|---|---|---|
| ១ | លោក អៀ សុខម៉េង | នាយករង |
| ២ | លោក ថាក់ សុភា | ប្រធានក្រុម គីមី |
| ៣ | លោក បេ ប្រា | គ្រូឧទ្ទេស គីមី |
| ៤ | លោក ជួន ភា | គ្រូឧទ្ទេស គីមី |
| ៥ | លោក ម៉េង ភិរុណ | គ្រូឧទ្ទេស រូបវិទ្យា |
| ៦ | លោក ស៊ាង សីហា | គ្រូឧទ្ទេស រូបវិទ្យា |
| ៧ | លោក សៀង ប៊ុនធឿន | គ្រូឧទ្ទេស រូបវិទ្យា |
| ៨ | កញ្ញា ហ៊ូ ច័ន្ទសារ៉ា | ប្រធានក្រុម ជីវវិទ្យា |
| ៩ | លោកស្រី ឡុង ពន្ធិនី | គ្រូឧទ្ទេស ជីវវិទ្យា |
| ១០ | លោកស្រី សោម ដានី | គ្រូឧទ្ទេស ជីវវិទ្យា |
| ១១ | លោកស្រី ច័ន្ទសោភា | ប្រធានក្រុម ផែនដីវិទ្យា |
| ១២ | កញ្ញា វ៉េង ស្រីម៉ន | គ្រូឧទ្ទេស ជីវវិទ្យា និងផែនដីវិទ្យា |
| ១៣ | កញ្ញា វ៉ីកុ កាម្ញូរ៉ា | អ្នកស្ម័គ្រចិត្ត (JOCV) ជីវវិទ្យា |

ហត្ថលេខា

_______________

លោកនាយករង សាន់នី សារ៉ូម

*អាចរៀបចំឲ្យបានច្រើនក្រុមកាន់ប្រសើរ។

**ការវិភាគអនុវត្តការសិក្សាស្រាវជ្រាវមេរៀន**
**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ កណ្តាល**

| សប្តាហ៍ | ២០១០ | | | ២០១១ | | |
|---|---|---|---|---|---|---|
| | ១០ | ១១ | ១២ | ១ | ២ | ៣ |
| ១ | | | បង្រៀនសាកល្បង និង កែលម្អ | | -រៀបចំសម្ភារ<br>-ពិសោធសាកល្បង | សរសេរកិច្ចតែងការបង្រៀន |
| ២ | សរសេរកិច្ចតែងការ បង្រៀន | រៀបចំសម្ភារ | | សរសេរកិច្ចតែងការ បង្រៀន | -បង្រៀនសាកល្បង<br>-កែលម្អ | កែលម្អកិច្ចតែងការបង្រៀន |
| ៣ | កែលម្អកិច្ចតែងការ | | | -កែលម្អនិងពិភាក្សា<br>-រៀបចំសម្ភារ | | |
| ៤ | | | បង្រៀនសិស្សនិងកែលម្អ | | -បង្រៀនគរុសិស្ស<br>-កែលម្អ | -រៀបចំសម្ភារ<br>-ពិសោធសាកល្បង |
| មុខវិជ្ជា៖<br>ប្រធានបទ៖<br>អ្នកទទួលប្រធានបទ៖ | គីមីវិទ្យា<br><br>ថាក់ សោភា | | | ជីវវិទ្យា<br><br>សោម ដានី | | ផែនដីវិទ្យា<br><br>ស្រី ចន្ទ័សោភា |

| សប្ដាហ៍ | ២០១១ | | | | |
|---|---|---|---|---|---|
| | ៤ | ៥ | ៦ | ៧ | ៨ |
| ១ | | សរសេរកិច្ចតែងការបង្រៀន | -រៀបចំសម្ភារ<br>-ពិសោធសាកល្បង | | |
| ២ | | | -បង្រៀនសាកល្បង<br>-កែលម្អ | | |
| ៣ | -បង្រៀនសាកល្បង<br>-កែលម្អ | កែលម្អកិច្ចតែងការបង្រៀន | | | |
| ៤ | -បង្រៀនគរុសិស្ស<br>-កែលម្អ | | -បង្រៀនគរុសិស្ស<br>-កែលម្អ | | |
| មុខវិជ្ជា៖<br>ប្រធានបទ៖<br>អ្នកទទួលប្រធានបទ៖ | | រូបវិទ្យា<br><br>សៀង សីហា | | | |

**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ រាជធានីភ្នំពេញ**

| រ.ល | ឈ្មោះ | តួនាទី/មុខវិជ្ជា |
|---|---|---|
| ១ | លោក ស្រី វុធ | ប្រធាន |
| ២ | លោកស្រី វណ្ណលី វឌ្ឍធានី | អនុប្រធាន |
| ៣ | លោកស្រី ហ៊ូ សៅម៉ូលីន | អនុប្រធាន |
| ៤ | លោក សាំង ឆុម | គ្រូឧទ្ទេស រូបវិទ្យា |
| ៥ | លោក ឯក លីម | គ្រូឧទ្ទេស រូបវិទ្យា |
| ៦ | លោក ស្រ៊ុន សៀងហួរ | គ្រូឧទ្ទេស រូបវិទ្យា |
| ៧ | លោក សុខា ត្រាយ | គ្រូឧទ្ទេស គីមី |
| ៨ | លោកស្រី សៀន ស្រីដេត | គ្រូឧទ្ទេស ជីវវិទ្យា |
| ៩ | លោកស្រី គីម បុរីផល | គ្រូឧទ្ទេស ផែនដីវិទ្យា |
| ១០ | លោក កួន ប៊ួយ | គ្រូឧទ្ទេស ផែនដីវិទ្យា |
| ១១ | កញ្ញា លុក សូលីនដា | គ្រូឧទ្ទេស ផែនដីវិទ្យា |
| ១២ | កញ្ញា Takenouchi Kaoru (បុប្ផា) | អ្នកស្ម័គ្រចិត្ត JOCV |

ហត្ថលេខា

_______________

លោកនាយក ដោក ជា

* អាចរៀបចំឲ្យបានច្រើនក្រុមកាន់ប្រសើរ។

**កាលវិភាគអនុវត្តការសិក្សាស្រាវជ្រាវមេរៀន**
**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ រាជធានីភ្នំពេញ**

| សប្តាហ៍ | ២០១០ | | | ២០១១ | | |
|---|---|---|---|---|---|---|
| | ១០ | ១១ | ១២ | ១ | ២ | ៣ |
| ១ | | | | | | |
| ២ | | ប្រជុំកែលម្អកិច្ចតែងការ | | ធ្វើកិច្ចតែងការបង្រៀនហើយចែកTool ១ ដល់ក្រុម LS | | អនុវត្តការបង្រៀនជាមួយគរុសិស្ស |
| ៣ | | | អនុវត្តជាមួយគរុសិស្ស | | បង្រៀនសាកល្បងនិងកែលម្អការបង្រៀន | |
| ៤ | ធ្វើកិច្ចតែងការបង្រៀនហើយចែកដល់ក្រុមLS ជាមួយ Tool ១ | បង្រៀនសាកល្បងនិងកែលម្អការបង្រៀន | | ប្រជុំកែលម្អកិច្ចតែងការបង្រៀន | | |
| មុខវិជ្ជា៖<br><br>ប្រធានបទ៖<br><br>អ្នកទទួលប្រធានបទ៖ | រូបវិទ្យា<br><br>សីតុណ្ហភាព<br><br>លោក សាំង ឆុម | | | គីមី<br><br>ប្រតិកម្មលោហៈជាមួយអាស៊ីត<br><br>លោក សុខ ត្រាយ | | |

| សប្តាហ៍ | ២០១១ | | | | |
|---|---|---|---|---|---|
| | ៤ | ៥ | ៦ | ៧ | ៨ |
| ១ | | | | | |
| ២ | | ប្រជុំកែលម្អកិច្ចតែងការបង្រៀន | អនុវត្តការបង្រៀនជាមួយគរុសិស្ស | | |
| ៣ | | | | | |
| ៤ | ធ្វើកិច្ចតែងការបង្រៀន | បង្រៀនសាកល្បងនិងប្រជុំកែលម្អការបង្រៀន | | | |
| មុខវិជ្ជា៖<br>ប្រធានបទ៖<br>អ្នកទទួលប្រធានបទ៖ | ផែនដីវិទ្យា<br>ភពក្នុងប្រព័ន្ធព្រះអាទិត្យ<br>លោក កួន ប៊ូយ | | | | |

**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ព្រៃវែង (ជីវ និងផែនដី)**

| រ.ល | ឈ្មោះ | តួនាទី/មុខវិជ្ជា |
|---|---|---|
| ១ | កញ្ញា ឈូក ណាស្រស់ | ប្រធានក្រុម (ជីវវិទ្យា) |
| ២ | កញ្ញា កែវ សេរី | អនុប្រធាន (ផែនដីវិទ្យា) |
| ៣ | លោក ហែម វន់ | សមាជិក (ផែនដីវិទ្យា) |
| ៤ | លោក មឿន សឿន | សមាជិក (ផែនដីវិទ្យា) |
| ៥ | លោក នាក់ វិចិត្រ | សមាជិក (ជីវវិទ្យា) |
| ៦ | កញ្ញា សាន សុធា | សមាជិក (ជីវវិទ្យា) |
| ៧ | | |
| ៨ | | |
| ៩ | | |
| ១០ | | |
| ១១ | | |
| ១២ | | |

ហត្ថលេខា

_______________

លោកនាយករង ប៊ួយ វុទ្ធី

* អាចរៀបចំឲ្យបានច្រើនក្រុមកាន់ប្រសើរ។

**កាលវិភាគអនុវត្តការសិក្សាស្រាវជ្រាវមេរៀន**
**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ព្រៃវែង** (**ជីវ និង ផែនដី**)

| សប្តាហ៍ | ២០១០ | | | ២០១១ | | |
|---|---|---|---|---|---|---|
| | ១០ | ១១ | ១២ | ១ | ២ | ៣ |
| ១ | | គ្រូគពិនិត្យកិច្ចតែងការបង្រៀន (check) (លោក មឿន សឿន) មុខវិជ្ជា៖ ផែនដីវិទ្យា មេរៀន៖ ជម្រាបទឹក ៦/១១/២០១០ | រៀបចំកិច្ចតែងការ (លោក នាក់ វិចិត្រ) មុខវិជ្ជា៖ ជីវវិទ្យា មេរៀន៖ ជំងឺ និងជំហៃទាំ ចំណាងជើងរង៖ ជម្ងឺទល់លាមក ៣/១២/២០១០ | | រៀបចំកិច្ចតែងការបង្រៀន កញ្ញា កែវ សេរី មុខវិជ្ជា៖ ផែនដីវិទ្យា មេរៀន៖ ផែនទីហានលេខ ០១/០២/២០១១ | |
| ២ | | រៀបចំកិច្ចតែងការបង្រៀន (លោក នាក់វិចិត្រ) មុខវិជ្ជា៖ ជីវវិទ្យា ១០/១១/២០១០ | | | | |
| ៣ | | | | | | |
| ៤ | | បង្រៀន(action) (លោក មឿន សឿន) មុខវិជ្ជា៖ ផែនដីវិទ្យា មេរៀន៖ ជម្រាបទឹក ៣០/១១/២០១០ | គ្រូគពិនិត្យ និងសាកល្បង (លោក នាក់វិចិត្រ) មុខវិជ្ជា៖ ជីវវិទ្យា មេរៀន៖ ជំងឺ និងតំហែទាំ ចំណាងជើងរង៖ ជម្ងឺទល់លាមក ៣១/១២/២០១០ | អនុវត្តការបង្រៀន (លោក នាក់វិចិត្រ) មុខវិជ្ជា៖ ជីវវិទ្យា មេរៀន៖ ជំងឺ និងតំហែទាំ ចំណាងជើងរង៖ ជម្ងឺទល់លាមក ២៩/០១/២០១១ | គ្រូគពិនិត្យ និងសាកល្បង កញ្ញា កែវ សេរី មុខវិជ្ជា៖ ផែនដីវិទ្យា មេរៀន៖ ផែនទីហានលេខ ២៨/០២/២០១១ | អនុវត្តការបង្រៀន កញ្ញា កែវ សេរី មុខវិជ្ជា៖ ផែនដីវិទ្យា មេរៀន៖ ផែនទីហានលេខ ៣១/០៣/២០១១ |
| មុខវិជ្ជា៖ ប្រធានបទ៖ អ្នកទទួលប្រធានបទ៖ | | | | | | |

| សប្តាហ៍ | ២០១១ | | | | |
|---|---|---|---|---|---|
| | ៤ | ៥ | ៦ | ៧ | ៨ |
| ១ | | រៀបចំកិច្ចតែងការបង្រៀន<br>(កញ្ញា ឈូក ណាស្រស់)<br>មុខវិជ្ជាៈ ជីវវិទ្យា<br>មេរៀនៈ ថាមពលសារពាង្គកាយក្នុងបរិស្ថាន។<br>០៣/០៥/២០១១ | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | កែលម្អ និងសាកល្បង<br>(កញ្ញា ឈូក ណាស្រស់)<br>មុខវិជ្ជាៈ ជីវវិទ្យា<br>មេរៀនៈ ថាមពលសារពាង្គកាយក្នុងបរិស្ថាន។<br>៣០/០៥/២០១១ | អនុវត្តការបង្រៀន<br>(កញ្ញា ឈូក ណាស្រស់)<br>មុខវិជ្ជាៈ ជីវវិទ្យា<br>មេរៀនៈ ថាមពលសារពាង្គកាយក្នុងបរិស្ថាន។<br>៣០/០៦/២០១១ | | |
| មុខវិជ្ជាៈ<br>ប្រធានបទៈ<br>អ្នកទទួលប្រធានបទៈ | | | | | |

**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ព្រៃវែង (រូប និងគីមី)**

| រ.ល | ឈ្មោះ | តួនាទី/មុខវិជ្ជា |
|---|---|---|
| ១ | លោក តឹក សុម៉ាលី | ប្រធានក្រុម (រូបវិទ្យា) |
| ២ | លោក ឈិត វ៉ាន់នី | អនុប្រធានក្រុម (គីមី) |
| ៣ | លោក អ៊ុន ណុល | សមាជិក (រូបវិទ្យា) |
| ៤ | លោកស្រី វណ្ណី ផល្លា | សមាជិក (រូបវិទ្យា) |
| ៥ | លោក ទាវ វឌ្ឍី | សមាជិក (រូបវិទ្យា) |
| ៦ | លោក មឿង វណ្ណា | សមាជិក (គីមី) |
| ៧ | | |
| ៨ | | |
| ៩ | | |
| ១០ | | |
| ១១ | | |
| ១២ | | |

ហត្ថលេខា

________________

លោកនាយករង ប៊ួយ វុទ្ធី

* អាចរៀបចំឲ្យបានច្រើនក្រុមកាន់ប្រសើរ។

**កាលវិភាគអនុវត្តការសិក្សាស្រាវជ្រាវមេរៀន**
**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ព្រៃវែង ( រូប និងគីមី )**

| សប្តាហ៍ | ២០១០ | | | ២០១១ | | |
|---|---|---|---|---|---|---|
| | ១០ | ១១ | ១២ | ១ | ២ | ៣ |
| ១ | | | រៀបចំកិច្ចតែងការបង្រៀន<br>(លោកស្រី វណ្ណី ផល្លា)<br>មុខវិជ្ជះ រូបវិទ្យា(ថ្នាក់ទី៨)<br>មេរៀនះ ចំណាំងបែ<br>០៦/១២/២០១០ | | រៀបចំកិច្ចតែងការ<br>(លោក ឈិត វ៉ាន់នី)<br>មុខវិជ្ជះ គីមីវិទ្យា<br>មេរៀនះ បម្លែងភាពរូប<br>នៃទឹក<br>០៣/០២/២០១១ | រៀបចំកិច្ចតែងការបង្រៀន<br>(លោក អ៊ុន ណុល)<br>មុខវិជ្ជះ រូបវិទ្យា<br>មេរៀនះ<br>០៤/០៣/២០១១ |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | ត្រួតពិនិត្យ និងបង្រៀន<br>សាកល្បង<br>(លោកស្រី វណ្ណី ផល្លា)<br>មុខវិជ្ជះ រូបវិទ្យា(ថ្នាក់ទី៨)<br>មេរៀនះ ចំណាំងបែ<br>២៩/០១/២០១១ | ១)អនុវត្តការបង្រៀន<br>(លោកស្រី វណ្ណី ផល្លា)<br>២) ត្រួតពិនិត្យកិច្ចតែងការ<br>(លោក ឈិត វ៉ាន់នី)<br>២៨/០២/២០១១ | ១)ត្រួតពិនិត្យកិច្ចតែងការ<br>(លោក អ៊ុន ណុល)<br>២) បង្រៀនសាកល្បង<br>(លោក ឈិត វ៉ាន់នី)<br>៣១/០៣/២០១១ |
| មុខវិជ្ជាះ<br><br>ប្រធានបទះ<br><br>អ្នកទទួលប្រធានបទះ | | | | | | |

| សប្តាហ៍ | ២០១១ | | | | |
|---|---|---|---|---|---|
| | ៤ | ៥ | ៦ | ៧ | ៨ |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | បង្រៀនសាកល្បង<br>(លោក អ៊ុន ណុល)<br>៣១/០៥/២០១១ | | | |
| មុខវិជ្ជា៖<br>ប្រធានបទ៖<br>អ្នកទទួលប្រធានបទ៖ | | | | | |

*ក្រុមសិក្សាស្រាវជ្រាវមេរៀន (ក្រដាស A4)*

**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ តាកែវ ក្រុមទី១ រូប-គីមី**

| រ.ល | ឈ្មោះ | តួនាទី/មុខវិជ្ជា |
|---|---|---|
| ១ | លោក គូ សុផា | ប្រធានៈ គីមី |
| ២ | លោក ឱម ចន្ទសុខា | អនុប្រធានៈ រូបវិទ្យា |
| ៣ | លោក សៀន ផេង | សមាជិកៈ រូបវិទ្យា |
| ៤ | លោក ប៉ុក ពៅ | សមាជិកៈ គីមី |
| ៥ | លោក អោម ភាព | សមាជិកៈ រូបវិទ្យា |
| ៦ | លោក ទេព យ៉ុត | សមាជិកៈ រូបវិទ្យា |
| ៧ | | |
| ៨ | | |
| ៩ | | |
| ១០ | | |
| ១១ | | |
| ១២ | | |

ហត្ថលេខា

____________________

លោកនាយក សោ សារេត

* អាចរៀបចំឲ្យបានច្រើនក្រុមកាន់ប្រសើរ។

**មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ តាកែវ ក្រុមទី២ ជីវៈ-ផែនដី**

| រ.ល | ឈ្មោះ | តួនាទី/មុខវិជ្ជា |
|---|---|---|
| ១ | លោក ប៉ែន រិទ្ធី | ប្រធាន៖ ជីវវិទ្យា |
| ២ | លោក ង៉ែត សុដា | អនុប្រធាន៖ ផែនដីវិទ្យា |
| ៣ | លោក សោ សារេត | សមាជិក៖ ជីវវិទ្យា |
| ៤ | លោក ចាន់ វណ្ណរី | សមាជិក៖ ជីវវិទ្យា |
| ៥ | លោក ប៉ុក ស្រីទូច | សមាជិក៖ ផែនដីវិទ្យា |
| ៦ | លោក ម៉ក់ ចន្ទី | សមាជិក៖ ផែនដីវិទ្យា |
| ៧ | | |
| ៨ | | |
| ៩ | | |
| ១០ | | |
| ១១ | | |
| ១២ | | |

ហត្ថលេខា

______________________

លោកនាយក សោ សារេត

* អាចរៀបចំឲ្យបានច្រើនក្រុមកាន់ប្រសើរ។

## កាលវិភាគអនុវត្តការសិក្សាស្រាវជ្រាវមេរៀន
## មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ តាកែវ

| សប្តាហ៍ | ២០១០ | | | ២០១១ | | |
|---|---|---|---|---|---|---|
| | ១០ | ១១ | ១២ | ១ | ២ | ៣ |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | យកកិច្ចតែងការបង្រៀនមកពិភាក្សាកែលម្អតាមក្រុមនីមួយៗនិងត្រៀមសម្ភារឧបទេស<br>២១/១០/២០១០ | បង្រៀនសាកល្បងតាមក្រុមនីមួយៗ និងពិភាក្សាពង្រាងកិច្ចតែងការបង្រៀនលើកទី២<br>១៨/១១/២០១០ | អនុវត្តនិងសង្កេតមេរៀនក្នុងថ្នាក់រៀននិងពិភាក្សា<br>១៦/១២/២០១០ | យកកិច្ចតែងការបង្រៀនមកពិភាក្សាកែលម្អតាមក្រុមនីមួយៗនិងត្រៀមសម្ភារឧបទេស<br>២០/០១/២០១១ | បង្រៀនសាកល្បងតាមក្រុមនីមួយៗ និងពិភាក្សាពង្រាងកិច្ចតែងការបង្រៀនលើកទី២<br>១៧/០២/២០១១ | អនុវត្តនិងសង្កេតមេរៀនក្នុងថ្នាក់រៀននិងពិភាក្សា<br>១៧/០២/២០១១ |
| ៤ | | | | | | |
| មុខវិជ្ជា៖<br>ប្រធានបទ៖<br>អ្នកទទួលប្រធានបទ៖ | (រូបវិទ្យា-ជីវវិទ្យា)<br>លោក ឱម ចន្ទសុខា<br>លោក ប៉ែន រឹទ្ធី | លោក ឱម ចន្ទសុខា<br>លោក ប៉ែន រឹទ្ធី | លោក ឱម ចន្ទសុខា<br>លោក ប៉ែន រឹទ្ធី | (គីមី -ផែនដីវិទ្យា)<br>លោក គួ សុផា<br>លោក ង៉ែត សូដា | លោក គួ សុផា<br>លោក ង៉ែត សូដា | លោក គួ សុផា<br>លោក ង៉ែត សូដា |

| សប្តាហ៍ | ២០១១ | | | | |
|---|---|---|---|---|---|
| | ៤ | ៥ | ៦ | ៧ | ៨ |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | អនុវត្តនិងសង្កេតមេរៀនក្នុងថ្នាក់រៀននិងពិភាក្សា ១៦/០៦/២០១១ | | |
| ៤ | យកកិច្ចតែងការបង្រៀនមកពិភាក្សាកែលម្អតាមក្រុមនីមួយៗ និងត្រៀមសម្ភារឧបទ្ទេស ២១/០៤/២០១១ | បង្រៀនសាកល្បងតាមក្រុមនីមួយៗ និងពិភាក្សាពង្រាងកិច្ចតែងការបង្រៀនលើកទី២ ២៦/០៥/២០១១ | | | |
| មុខវិជ្ជា៖<br>ប្រធានបទ៖<br>អ្នកទទួលប្រធានបទ៖ | (គីមី –ផែនដីវិទ្យា)<br>លោក ប៉ុក ពៅ<br>កញ្ញា ប៉ុក ស្រីទូច | <br>លោក ប៉ុក ពៅ<br>កញ្ញា ប៉ុក ស្រីទូច | <br>លោក ប៉ុក ពៅ<br>កញ្ញា ប៉ុក ស្រីទូច | | |